00291923

**Declassified to Public**
**28 October 2021**

D1

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
**នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត**

| | |
|---|---|
| **សំណុំរឿង៖** | ០០៣/២០-១១-២០០៨/អវតក/កសចស |
| **ដាក់ជូន៖** | សហចៅក្រមស៊ើបអង្កេត |
| **កាលបរិច្ឆេទឯកសារ៖** | ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ |
| **ភាគីដាក់ឯកសារ៖** | ការិយាល័យសហព្រះរាជអាជ្ញា |
| **ភាសាដើម៖** | អង់គ្លេស |
| **ប្រភេទឯកសារ៖** | **សម្ងាត់** |

---

# ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ លើកទី ២ របស់សហព្រះរាជអាជ្ញា ទាក់ទងទៅនឹងកងទ័ពបដិវត្តកម្ពុជា

---

| **ដាក់ដោយ៖** | **បញ្ជូនទៅ៖** |
|---|---|
| **ការិ. សហព្រះរាជអាជ្ញា៖** | **ការិ. សហចៅក្រមស៊ើបអង្កេត៖** |
| លោកស្រី ជា លាង | ចៅក្រម យូ ប៊ុនឡេង |
| លោក Robert PETIT | ចៅក្រម Marcel LEMONDE |
| លោក យ៉ែត ចរិយា | |
| លោក William SMITH | |
| លោក Stuart FORD | |

ឯកសារទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception): 21 / 04 / 2010
ម៉ោង (Time/Heure) : 14 : 55
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 22 / 04 / 2010
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

# មាតិកា

សេចក្តីផ្តើម

ប្រវត្តិនៃការស៊ើបអង្កេត

សេចក្តីសង្ខេបអង្គហេតុ

សេចក្តីសង្ខេបអំពីសម័យកម្ពុជាប្រជាធិបតេយ្យ.................................................

រចនាសម្ព័ន្ធកងទ័ពបដិវត្តន៍កម្ពុជា...............................................................

អគ្គសេនាធិការ.............................................................................................

កងស្រួច កងតំបន់ និង កងឈ្លប...............................................................

កងពល "ស្រួច" និង កងវរសេនាធំឯករាជ្យ..................................................

ជម្លោះប្រដាប់អាវុធ.......................................................................................

ជាមួយវៀតណាម........................................................................................

ជាមួយថៃ....................................................................................................

ផែនការឧក្រិដ្ឋកម្មរួម....................................................................................

បទឧក្រិដ្ឋ.........................................................................................................

មន្ទីរសន្តិសុខស-២១......................................................................................

កងពល៥០២.................................................................................................

សេចក្តីសង្ខេបនៃបទឧក្រិដ្ឋ............................................................................

មន្ទីរសន្តិសុខស-២២.................................................................................

ការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង................................................

កងពល១៦៤.................................................................................................

សេចក្តីសង្ខេបនៃបទឧក្រិដ្ឋ............................................................................

មន្ទីរសន្តិសុខវត្តអង្គតាញាណ.........................................................................

ការដ្ឋានវាយថ្មស្ទឹងហាវ.................................................................................

កងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យ...........................................................

វៀតណាម......................................................................................
កងពល៨០១....................................................................................
គុក៨១០.......................................................................................
មន្ទីរសន្តិសុខរបស់កងទ័ពបដិវត្តន៍កម្ពុជា និង ទីតាំងសម្លាប់ផ្សេងទៀត..............................
ជនសង្ស័យ......................................................................................
ស៊ូ ម៉េត........................................................................................
ព័ត៌មានផ្ទាល់ខ្លួន..........................................................................
អំណាចតែងតាំង និងអំណាចជាក់ស្តែង............................................
ការចូលរួម និងការដឹងឮ.................................................................
មាស មុត......................................................................................
ព័ត៌មានផ្ទាល់ខ្លួន.........................................................................
អំណាចតែងតាំង និងអំណាចជាក់ស្តែង............................................
ការចូលរួម និងការដឹងឮ.................................................................
បទល្មើសដែលបានចោទប្រកាន់.......................................................
ឯកសារយោងផ្នែកភស្តុតាង និងផ្នែកច្បាប់.........................................

# សេចក្តីផ្តើម

១. យើង សហព្រះរាជអាជ្ញានៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក)៖

ក) បានឃើញវិធាន៥៣ និង ៦៣ (៣) (ក) នៃវិធានផ្ទៃក្នុង អ.វ.ត.ក ("វិធានផ្ទៃក្នុង") និងនិយមន័យនៃ"ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម"ដែលមានចែងនៅក្នុង សទ្ទានុក្រមនៃវិធានផ្ទៃក្នុង ។

ខ) ដោយបានដឹកនាំធ្វើការស៊ើបសួរបឋម និងដោយបានធ្វើសេចក្តីសន្និដ្ឋានថា ឧក្រិដ្ឋកម្មផ្សេងៗ ដែលស្ថិតនៅក្នុងយុត្តាធិការរបស់អ.វ.ត.ក ត្រូវបានប្រព្រឹត្ត។

គ) ស្នើឱ្យសហចៅក្រមស៊ើបអង្កេត បើកធ្វើការស៊ើបសួរថ្មី១ ទៅលើអង្គហេតុដូចខាងក្រោមនេះ ទាក់ទងទៅនឹងការទទួលខុសត្រូវរបស់ជនសង្ស័យ **ស៊ូ ម៉េត** និង **មាស មុត** និងស្នើសហចៅក្រមស៊ើបអង្កេតចាប់និងឃុំខ្លួនជាបណ្តោះអាសន្ន ជនទាំងពីររូបនេះនៅក្នុងដំណាក់កាលនៃកិច្ចស៊ើបសួរ ។

២. ពីខែមិថុនា ឆ្នាំ១៩៧៥ ដល់ខែមករា ឆ្នាំ១៩៧៩ **ស៊ូ ម៉េត** មានតួនាទីជាលេខាកងពល៥០២ នៃកងទ័ពបដិវត្តន៍កម្ពុជា (ក.ប.ក) និងជាមេបញ្ជាការកងទ័ពអាកាសរបស់ ក.ប.ក។ ស៊ូ ម៉េត ក៏ជាសមាជិកនៃគណៈជំនួយការនៃគណៈមជ្ឈិមរបស់បក្សកុម្មុយនីស្តកម្ពុជា (ប.ក.ក) ដែលជាតំណែងដ៏ខ្ពស់មួយនៅក្នុងឋានានុក្រម ប.ក.ក។ លើសពីនេះ គាត់ក៏មានឥទ្ធិពលខ្លាំងនៅក្នុងអគ្គសេនាធិការ ដែលជាអង្គភាពខ្ពស់បំផុតរបស់ ក.ប.ក ។

៣. ពីខែមេសា ឆ្នាំ១៩៧៥ ដល់ខែមករា ឆ្នាំ១៩៧៩ **មាស មុត** គឺជាលេខាកងពល១៦៤ នៃ ក.ប.ក និងជាមេបញ្ជាការកងទ័ពជើងទឹករបស់ ក.ប.ក ។ មាស មុត អាចជាសមាជិកគណៈមជ្ឈិម ឬជាសមាជិកគណៈជំនួយការនៃគណៈមជ្ឈិម ។ បន្ថែមលើតួនាទីផ្នែកយោធា និងផ្នែកបក្ស មាស មុត បានកាន់កាប់ក្រុងកំពង់សោម តំបន់ជុំវិញ និង បណ្តាកោះនានា ។

៤. សហព្រះរាជអាជ្ញាមានហេតុផលនឹងជឿជាក់ថា **ស៊ូ ម៉េត** និង **មាស មុត** បានរួមចំណែកនៅក្នុងបទឧក្រិដ្ឋដែលបានរៀបរាប់នៅក្នុងកថាខណ្ឌទី៤៣ ដល់ ៦៦នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី២ដែលរួមមាន ការបង្ខំឱ្យធ្វើការបាក់កម្លាំង លក្ខខណ្ឌរស់នៅអមនុស្សធម៌ ការចាប់

និងឃុំខ្លួនមិនស្របច្បាប់ ការធ្វើទុកបុកម្នេញផ្នែករាងកាយ និងផ្នែកសតិបញ្ញា ការធ្វើទារុណកម្ម និងការសម្លាប់ ។ ជាពិសេស **ស៊ូ ម៉េត** និង **មាស មុត** បានរួមចំណែកនៅក្នុងផែនការឧក្រិដ្ឋកម្ម ដើម្បីកម្ចាត់ សមាសភាពអាក្រក់នៅក្នុង ក.ប.ក ដែលបង្កឱ្យមានមនុស្សស្លាប់បាត់បង់ជីវិតជាច្រើនពាន់នាក់ ហើយអាចរហូតដល់រាប់ម៉ឺននាក់ ។ លើសពីនេះ មនុស្សរាប់ម៉ឺននាក់ត្រូវបានឃុំខ្លួនមិនត្រឹមត្រូវ តាមច្បាប់ ហើយបង្ខំឱ្យធ្វើការបាក់កម្លាំង ។ **ស៊ូ ម៉េត** និង **មាស មុត** បានប្រើប្រាស់អំណាច និងឥទ្ធិពលរបស់ខ្លួនដើម្បីអនុវត្តផែនការឧក្រិដ្ឋកម្ម ហើយចូលរួមយ៉ាងសកម្មក្នុងការប្រព្រឹត្តិ បទឧក្រិដ្ឋទាំងឡាយរៀបរាប់ខាងក្រោម ។

៥. សំណើនេះទាក់ទិនទៅនឹងការចូលរួមរបស់ជនចុងចោទនៅក្នុងអំពើឧក្រិដ្ឋជាក់លាក់ ដែលបានបញ្ជាក់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ (ដីកាសន្និដ្ឋានឱ្យស៊ើបសួរលើកទី១) ដីកាសន្និដ្ឋានឱ្យស៊ើបសួរបន្ថែម ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០០៨ និងអំពើឧក្រិដ្ឋជាក់លាក់ផ្សេងទៀតដែលមិនបានបញ្ជាក់នៅក្នុងដីកាសន្និដ្ឋានមុនៗ ។ ឧក្រិដ្ឋកម្មទាំងឡាយដែលបានរួមបញ្ចូលនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី២នេះ ដែលជាន់គ្នានិងឧក្រិដ្ឋកម្មនានាដែលបានលើកឡើងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកមុន និងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម គឺបានកើតឡើងនៅក្នុងទីកន្លែងផ្សេងៗដូចមានខាងក្រោម៖

ក) មន្ទីរសន្តិសុខស-២១ ។

ខ) ទីតាំងសម្លាប់ស្ទឹងតូច ។

គ) ការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង ។

ឃ) ភូមិភាគកណ្តាល ។

ង) ភូមិភាគឧត្តរថ្មី ។

ច) ភូមិភាគបូព៌ា ។ និង

ឆ) ប្រទេសវៀតណាម ។

៦. ឧក្រិដ្ឋកម្មដែលស្ថិតនៅក្រៅដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី១និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម បានកើតឡើងនៅទីទីកន្លែងនានាដូចខាងក្រោម៖

ក) មន្ទីរសន្តិសុខស-២២ ។

ខ) មន្ទីរសន្តិសុខវត្តឥន្ទញាណ ។

គ) ការដ្ឋានវាយថ្មស្ទឹងហាវ ។

ឃ) កងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យ។

ង) មន្ទីរសន្តិសុខកងពល៨១០ ។ និង

ច) មន្ទីរសន្តិសុខផ្សេងៗទៀតដែលមិនមានឈ្មោះដែលគ្រប់គ្រងដោយកងពលធំទាំងឡាយនៃកងទ័ពបដិវត្តន៍កម្ពុជា (ក.ប.ក) ។

## ប្រវត្តិនៃការស៊ើបអង្កេត

៧. នៅខែទី១០ ខែកញ្ញា ឆ្នាំ២០០៦ សហព្រះរាជអាជ្ញាបានចាប់ផ្តើមស៊ើបអង្កេតទៅលើបទឧក្រិដ្ឋដែលស្ថិតក្រោមច្បាប់របស់ អ.វ.ត.ក ។ ក្រោយពីបានទទួលបណ្តឹងពីសាក្សី សហព្រះរាជអាជ្ញាបានសម្ភាសសាក្សី និងចុះស៊ើបអង្កេត ហើយបានប្រមែប្រមូលឯកសារជាភស្តុតាងមួយចំនួនធំ ។ នៅថ្ងៃ ទី១៨ ខែកញ្ញា ឆ្នាំ២០០៧ លទ្ធផលនៃការស៊ើបអង្កេតបឋមនេះ ត្រូវបានបញ្ចូលទៅក្នុងដីកាសន្និដ្ឋានឱ្យស៊ើបសួរមួយ ដែលស្នើឡើងថា ចៅក្រមស៊ើបអង្កេតគួរតែបង្កើតឱ្យមានការស៊ើបសួរទៅលើអំពើឧក្រិដ្ឋមួយចំនួន រួចចាប់ និងឃុំខ្លួនជាបណ្តោះអាសន្នជនសង្ស័យចំនួន ៥ រូប[1] ។

៨. ការសម្ភាសសាក្សី ឬការចុះស៊ើបអង្កេតបន្ថែមមិនត្រូវបានធ្វើឡើងទៅលើបទឧក្រិដ្ឋដែលបានរៀបរាប់ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី១ទេ ទោះបីជាសហព្រះរាជអាជ្ញាបន្តវិភាគភស្តុតាងដែលបានប្រមែប្រមូល ដើម្បីកំណត់ឧក្រិដ្ឋកម្មផ្សេងៗបន្ថែមទៀត និងស្វែងរកជនសង្ស័យផ្សេងៗទៀត ដែលស្ថិតនៅក្រោមយុត្តាធិការរបស់ អ.វ.ត.ក ។ សហព្រះរាជអាជ្ញា បានបន្តធ្វើការស៊ើបអង្កេតបឋម រួមទាំងការស៊ើបអង្កេតតាមមូលដ្ឋាន និងការសម្ភាសសាក្សីនៅខែសីហា ឆ្នាំ២០០៨ ទាក់ទងតែទៅលើ៖ ទី១) កន្លែងកើតហេតុផ្សេងទៀតដែលបានរៀបរាប់ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី២ ហើយដែលមិនបានលើកឡើងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី១ ។ ទី២) តួនាទី និងការទទួលខុសត្រូវខាងព្រហ្មទណ្ឌរបស់ជនសង្ស័យ **ស៊ូ ម៉េត** និង **មាស មុត** ចំពោះបទឧក្រិដ្ឋទាំងឡាយក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី២នេះ ។

## សេចក្តីសង្ខេបនៃអង្គហេតុ

៩. យើង សហព្រះរាជអាជ្ញានៃ អ.វ.ត.ក ក្រោយពីបានពិនិត្យអង្គហេតុចាំបាច់ នៅក្នុងសំណុំរឿង និងភស្តុតាងបន្ថែមនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី២នេះ សន្និដ្ឋានថា ការចូលរួមរបស់ **ស៊ូ ម៉េត** និង **មាស មុត** នៅក្នុងទង្វើទាំងឡាយដូចបានរៀបរាប់ក្នុងដីកាបញ្ជូនសន្និដ្ឋានរឿងឱ្យស៊ើបសួរនេះបានធ្វើឱ្យជនទាំងពីរទទួលខុសត្រូវទៅលើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ និងឧក្រិដ្ឋកម្ម មនុស្សឃាត និង ការធ្វើទារុណកម្មនៅ ក្រោមក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦របស់កម្ពុជា ដែលត្រូវផ្តន្ទាទោសក្រោមមាត្រា ៣, ៥, ៦, ២៩ (ថ្មី) និង៣៩ (ថ្មី) នៃច្បាប់របស់ អ.វ.ត.ក ទៅតាម ហេតុផលដូចរៀបរាប់ខាងក្រោម ។

## សេចក្តីសង្ខេបសម័យកម្ពុជាប្រជាធិបតេយ្យ

១០. រវាងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ប.ក.ក មានបំណងចង់កែប្រែសង្គមកម្ពុជាតាមបន្ទាត់មនោគមន៍វិជ្ជាដោយប្រើប្រាស់វិធីសាស្ត្រកែប្រែសង្គម និងសេដ្ឋកិច្ច ។ ដើម្បីសម្រេចបំណាស់ប្តូរនេះ មេដឹកនាំ ប.ក.ក បានអនុវត្តគោលនយោបាយដែលបង្កឱ្យមានការអត់ឃ្លានទូទាំងប្រទេស អំពើឃោរឃៅជាប្រព័ន្ធ លក្ខខណ្ឌរស់នៅមិនសមជាមនុស្ស និង ការស្លាប់បាត់បង់ជីវិតមនុស្សពី ១.៧ ទៅ ២.២ លាននាក់ ។ ទីក្រុងទាំងឡាយត្រូវបានជម្លៀស ហើយប្រជាជនស្ទើរតែទាំងអស់នៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ បានក្លាយទៅជាទាសករបម្រើការងារនៅក្នុងសហករណ៍ រោងចក្រ ការដ្ឋានការងារ កងពលយោធា និងអង្គភាពផ្សេងទៀតរបស់អង្គការ ដែលបង្ខិតបង្ខំឱ្យប្រជាជនធ្វើការបាក់កម្លាំង គ្មានម្ហូបអាហារគ្រប់គ្រាន់ ។ ប.ក.ក បានបង្កើតមន្ទីរសន្តិសុខ ទូទាំងប្រទេស ដែលឃុំឃាំង ធ្វើទារុណកម្ម និងសម្លាប់យ៉ាងខុសច្បាប់ និងប្រជាជនកម្ពុជាជាច្រើននាក់ ។ ប.ក.ក ក៏បានសម្លាប់កម្មាភិបាលរបស់ខ្លួនរាប់ម៉ឺន សែននាក់ ដោយយល់ថា កម្មាភិបាលទាំងនេះជា “ខ្មាំង” បង្កប់នៅក្នុងគ្រប់អង្គភាពរដ្ឋបាល នយោបាយ និងយោធាទាំងអស់ ។

១១. ប.ក.ក បានអនុវត្តការបោសសម្អាតជាច្រើនលើកនូវកម្មាភិបាលរបស់ខ្លួន ដែលក្នុងនោះ មនុស្សត្រូវបានដកពីតំណែង ហើយយកទៅសម្លាប់ (កម្ទេច)[2] ដោយសារអ្នកទាំងនោះត្រូវគេយល់ថាប្រឆាំងនឹង ប.ក.ក ។ កម្មាភិបាលសំខាន់ៗ បុគ្គលិកសន្តិសុខ យុទ្ធជន និងប្រជាជននៅគ្រប់កម្រិត

ក្នុងសង្គមត្រូវបានបង្គាប់ឱ្យប្រុងប្រយ័ត្នជានិច្ចចំពោះសត្រូវ "ស៊ីរូងផ្ទៃក្នុង" ហើយវាយប្រហារ និង "កម្ចាត់ជាបន្តបន្ទាប់" នូវសមាភាពអាក្រក់[3] ។ ការបោសសម្អាតក្នុង ក.ប.ក ដែលបានរៀបរាប់នៅខាងក្រោម ជាការបោសសម្អាតមួយក្នុងចំណោមជាច្រើនដែលបានកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ឧក្រិដ្ឋទាំងនេះ បានកើតឡើងតាមរយៈការសម្រេចចិត្តយ៉ាងច្បាស់លាស់ដែលគ្រោងនឹងអនុវត្តដោយថ្នាក់ដឹកនាំរបស់ ប.ក.ក ហើយបង្កឱ្យមានការកាប់សម្លាប់ជាទូទៅ និងជាប្រព័ន្ធទៅលើប្រជាជនកម្ពុជាស្ទើរតែទាំងអស់ ។

## រចនាសម្ព័ន្ធ ក.ប.ក

១២. ច្បាប់រដ្ឋធម្មនុញ្ញរបស់កម្ពុជាប្រជាធិបតេយ្យបានផ្តល់ ក.ប.ក នូវភារកិច្ច "ការពារអំណាចរដ្ឋ" និង "ជួយកសាងប្រទេស"[4] ។ ក.ប.ក មានការទទួលខុសត្រូវទូទៅខាងផ្នែកសន្តិសុខខាងក្រៅ និងផ្នែកខាងក្នុង[5] ។ ក.ប.ក ត្រូវបានបែងចែកជាបីសាខាគឺ៖ ស្រួច តំបន់ ឈ្លប[6] ។ សាខាទាំងបីនេះ "ស្ថិតនៅក្រោមការដឹកនាំផ្តាច់មុខដាច់ខាត" របស់ ប.ក.ក[7] ។

១៣. ក.ប.ក ស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់គណៈយោធា ដែលជាគណៈកម្មាធិការក្រោមចំណុះគណៈមជ្ឈិម[8] របស់ ប.ក.ក ដែលទទួលខុសត្រូវផ្នែកយោធា និងសន្តិសុខ[9] ។ គណៈយោធាមានសមាជិកគណៈអចិន្ត្រៃយ៍[10] ប៉ុល ពត[11], នួន ជា និង សុន សេន[12] (ហៅ ខៀវ ឬ បង៨៩) ក៏ដូចជាកម្មាភិបាលជាន់ ខ្ពស់ផ្សេងទៀតរបស់ ប.ក.ក[13] ។

## អគ្គសេនាធិការ

១៤. អគ្គសេនាធិការរបស់ ក.ប.ក ដើរតួជាទីបញ្ជាការកណ្តាលរបស់កងទ័ព ហើយបំពេញមុខងារជាច្រើនដូចជា រៀបចំគម្រោង ធ្វើបេសកកម្ម ស៊ើបការណ៍សម្ងាត់ និងភ័ស្តុភារ ។ សុន សេន មានតំណែងជាប្រធានអគ្គសេនាធិការ[14] ។ សុន សេន ត្រូវបានជួយក្នុងការងារ ដោយកម្មាភិបាល ប.ក.ក ដែលបានបញ្ជូនទៅធ្វើការនៅក្នុងអគ្គសេនាធិការ ។ ក្នុងនោះមាន វ៉ែន[15] និង ទាញ[16] ។ ជារួម អគ្គសេនាធិការ និងមន្ទីរក្រោមចំណុះនានា មន្ទីរ៦២ និង មន្ទីរ៦៣ មានបុគ្គលិក ចំនួន ៤,៥០០ នាក់[17] ។

១៥. តួនាទីសំខាន់មួយរបស់អគ្គសេនាធិការ គឺរក្សាសន្តិសុខផ្ទៃក្នុង ដែលរាប់បញ្ចូលទាំងការឃ្លាំមើល "ខ្មាំងផ្ទៃក្នុង" និងចាត់វិធានការកម្ទេចខ្មាំង[18] ។ ពិសេសគណៈមជ្ឈិមរបស់ ប.ក.ក ផ្តល់អំណាចឱ្យអគ្គសេនាធិការជាអ្នកកំណត់ថាតើបុគ្គលិក ក.ប.ក ណាខ្លះដែលត្រូវយកទៅសម្លាប់ ដើម្បីបម្រើនយោបាយ ប.ក.ក[19] ។ អគ្គសេនាធិការបានប្រើប្រាស់អំណាចនេះ ហើយកម្មាភិបាលអគ្គសេនាធិការ ជាច្រើនត្រូវបានបញ្ជូនទៅមន្ទីរស-២១[20] ដែលនៅទីនោះពួកគេត្រូវបានសម្លាប់ចោល[21] ។

១៦. ក្នុងការប្រើប្រាស់អំណាចកម្ទេចបុគ្គលិក ក.ប.ក ពេលខ្លះអគ្គសេនាធិការបានបញ្ជូនកម្មាភិបាលខ្លះទៅតាមមូលដ្ឋាន ដើម្បីដោះស្រាយបញ្ហាសន្តិសុខផ្ទៃក្នុងនៅតាមកងរបស់ ក.ប.ក[22] ។ ប៉ុន្តែតាមការសង្កេតបានឱ្យដឹងថា សិទ្ធិកម្ទេច តែងតាំង ត្រូវបានប្រគល់ទៅឱ្យកងពលរបស់ ក.ប.ក ពិសេសក្រោយពីបានពិគ្រោះយោបល់ជាមួយមន្ទីរស-២១[23] ។ កម្មាភិបាលខ្លះទៀត ត្រូវបានបញ្ជូនទៅអប់រំ[24] ។

១៧. អគ្គសេនាធិការជាអ្នកធ្វើរបាយការណ៍ស្តីអំពីសន្តិសុខខាងក្នុង និងខាងក្រៅ[25] ហើយមានអំណាចដាក់បញ្ហាទាក់ទងទៅនឹងសន្តិសុខខាងក្នុង រួមទាំងបញ្ហាទាក់ទងទៅនឹងឯកសណ្ឋានរបស់កម្មាភិបាល ការយាមកាម ការតាមដាន និងលិខិតអនុញ្ញាតឱ្យកាន់អាវុធ[26] ។ វាហាក់ដូចជាថាអគ្គសេនាធិការមានមន្ទីរសន្តិសុខផ្ទាល់ខ្លួន[27] ។

១៨. អគ្គសេនាធិការសម្របសម្រួលការអនុវត្តន៍ផែនការរបស់ ប.ក.ក នៅក្នុងកងរបស់ ក.ប.ក ដែលស្ថិតនៅក្រោមចំណុះរបស់អគ្គសេនាធិការ ។ ដើម្បីសម្រេចគោលដៅនេះ អគ្គសេនាធិការទំទាក់ទំនងជាមួយកងពល និងកងវរសេនាធំឯករាជ្យ តាមរយៈការប្រជុំជាប្រចាំរវាងប្រធានអគ្គសេនាធិការ និងកម្មាភិបាលជាន់ខ្ពស់របស់កងពល និងកងវរសេនាធំឯករាជ្យ[28] ។ នៅក្នុងអង្គប្រជុំទាំងនេះ មេបញ្ជាការកងពលតែងតែរាយការណ៍អំពីសកម្មភាពនៅក្នុងកងពល ផ្តោតទៅលើស្ថានភាពរបស់សត្រូវខាងក្នុង និងខាងក្រៅ និងវិធានការដែលត្រូវចាប់ ដើម្បីរក្សាសន្តិសុខ ។ បន្ទាប់មកប្រធានអគ្គសេនាធិការ សុន សេន សង្ខេបអំពីស្ថានភាពនៅក្នុងប្រទេស និងចេញបញ្ជា ។

១៩. អគ្គសេនាធិការ និងមេបញ្ជាការកងពលនីមួយៗក៏បានប្រជុំដែរ[29] ។ ការប្រជុំខ្លះបានធ្វើឡើងស្របពេលជាមួយការប្រជុំរវាងមេបញ្ជាការកងពល និងកងវរសេនាធំទាំងអស់[30] ។ លើសពីនេះ

មានការប្រជុំផ្សេងទៀតទាក់ទងទៅនឹងអង្គការបក្ស ដូចជាការជ្រើសរើសសមាជិកកងទ័ពអាកាស ការពង្រាយទ័ពជើងទឹក ការបង្កើនផលិតកម្មអាហារ ការសហការជាមួយអ្នកជំនាញការយោធាចិន និងការបង្កើនការការពារភ្នំពេញ[31] ។

២០. អគ្គសេនាធិការ បានជួយផ្នែកភស្តុភារដល់ ក.ប.ក ។ ឧទាហរណ៍៖ អគ្គសេនាធិការមានគណៈភស្តុភារមួយដែលមានតួនាទីជួសជុលគ្រឿងយន្តជួសជុលអាវុធ ការសាងសង់ ការទុកដាក់សព្វាវុធ និងការដឹកជញ្ជូន[32] ។ អគ្គសេនាធិការឃ្លាំមើលស្ថិតិទាក់ទងនឹងផ្នែកយោធា ដូចជាការប្រើប្រាស់ស្បៀងអាហារ ការចែកអាវុធ និងឧបករណ៍យោធា[33] ។ អគ្គសេនាធិការផ្តល់យោបល់ទាក់ទងទៅនឹងផលិតកម្មអាហារ[34] ។ ជាចុងក្រោយ អគ្គសេនាធិការទទួលខុសត្រូវលើការអប់រំនយោបាយនៅតាមកងពល និងកម្មាភិបាលក្នុងកងវរសេនាធំ ហើយបង្កើតកម្មវិធីហ្វឹកហាត់ម្តងម្កាល ដែលត្រូវបានចូលរួមដោយបុគ្គលិក ក.ប.ក រាប់រយនាក់មកពីទូទាំងប្រទេស[35] ។

## កងស្រួច កងតំបន់ និង កងឈ្លប

២១. ក.ប.ក ត្រូវបានបែងចែកជាបីសាខា៖“ស្រួច តំបន់ និងឈ្លប”[36] ។ កងទ័ព “ស្រួច” មានកងពលធំ និងកងវរសេនាធំឯករាជ្យ ដែលរាយការណ៍ផ្ទាល់ទៅអគ្គសេនាធិការ ។ កងពលធំ “តំបន់” រាយការណ៍ទៅគណៈភូមិភាគ ហើយកងវរសេនាធំ “តំបន់” រាយការណ៍ទៅគណៈកម្មាធិការផ្នែក ។ កង “ឈ្លប” នៃ ក.ប.ក មាន “ឈ្លប” ឬកងជីវពលតាមមូលដ្ឋាន ដែលរាយការណ៍ទៅកាន់គណៈស្រុក[37] ។ គ្រប់កម្រិតនៃយោធារបស់កម្ពុជាប្រជាធិបតេយ្យ ត្រូវស្ថិតនៅក្រោមបញ្ជាការរបស់កម្មាភិបាល ប.ក.កគ្រប់ពេល[38] ។ មេដឹកនាំ ប.ក.ក បានពោលថា “មានតែបក្សទេ ដែលដឹកនាំកងទ័ព គ្មានអ្នកណាផ្សេងអាចដឹកនាំជំនួសឡើយ”[39] ។

២២. កងស្រួចនៃ ក.ប.ក ពេលខ្លះមានកងពលចំនួនពី៩ទៅ១០ (កងពលលេខ ១៦៤, ១៧០, ២៩០, ៣១០, ៤៥០, ៥០២, ៦៩០, ៧០៣, ៨០១, ៩០០ និង ៩២០) និងកងវរសេនាធំឯករាជ្យចំនួនបី (កងវរសេនាធំលេខ ១៥២, ៣៧៧ និង ៤៨៨) ព្រមទាំងមន្ទីរជាច្រើនទៀត (ស-២១, ម-៦២ និងម-៦៣)[40] ។ មន្ទីរស-២១ ជាអង្គភាពមួយដែលមានតួនាទីចម្បងក្នុងការពង្រឹងសន្តិសុខផ្ទៃក្នុង ត្រូវបានចាត់ទុកថាជាផ្នែកមួយរបស់ ក.ប.ក ក្នុងគោលបំណងមួយចំនួន[41]។ បើតាមរបាយការណ៍

ពីអគ្គសេនាធិការ កង"ស្រួច" របស់អគ្គសេនាធិការមានបុគ្គលិកចំនួនពី ៦០,០០០ ទៅ ៦៥,០០០ នាក់[42] ។

២៣. មានកងពល "តំបន់" មួយចំនួនតាំងនៅពាសពេញកម្ពុជាប្រជាធិបតេយ្យ ។ កងពលតំបន់ទំនងជារាប់បញ្ចូល៖ កងពលលេខ១នៅភូមិភាគពាយ័ព្យ[43] កងពលលេខ២[44] កងពលមួយនៅភូមិភាគឧត្តរ[45] កងពលលេខ៣ នៅភូមិភាគបូព៌ា[46] កងពលលេខ៤ នៅភូមិភាគបូព៌ា[47] កងពលលេខ៥ នៅភូមិភាគបូព៌ា[48] កងពលលេខ១១[49] កងពលលេខ១២[50] កងពលលេខ១១៧ នៅភូមិភាគឧត្តរ[51] កងពលលេខ១៧៤ នៅភូមិភាគកណ្ដាល[52] កងពលមួយនៅកំពង់ចាម[53] និង កងពលលេខ៣៣៥[54] ។ ក្រៅពីនេះអាចនៅមានកងពលថ្នាក់តំបន់ផ្សេងៗទៀត[55] ។

២៤. នៅក្នុងកង "ឈ្លប" របស់ ក.ប.ក ពួក "ឈ្លប" ឬកងជីវពលមូលដ្ឋានផ្ដល់សន្តិសុខជូនស្រុក ឃុំ ភូមិ និងសហករណ៍[56] ។ កងឈ្លបទាំងនេះដើរល្បាតតាមឃុំ និងតំបន់ជុំវិញឃុំ ដើម្បីស្វែងរកប្រជាជនដែលអាចរត់គេចខ្លួន[57] ធ្វើគេញសម្ងាត់ និងស៊ើបការណ៍លើសមាជិកសហករណ៍ ដើម្បីធានាថាគ្មានជំងឺសតិអារម្មណ៍ ឬសកម្មភាពសត្រូវ[58] ហើយឈ្លប ដើរតួនាទីជាកងការពារប្រធានសហករណ៍[59] ។ "ឈ្លប" មានតួនាទីជាពេជ្ឈឃាតហើយតែងតែត្រូវកោះហៅ ដោយអ្នករដ្ឋបាលស៊ីវិល និងប្រធានសហករណ៍ឱ្យយកមនុស្សទៅសម្លាប់[60] ។ មនុស្សមានកំហុសតូចតាច ឬជាខ្សែរយៈនៃជនណាម្នាក់ដែលគេចោទថាក្បត់ក៏អាចគេយកទៅសម្លាប់ចោលដែរ[61] ។

## កងពល "ស្រួច" និងកងវរសេនាធំឯករាជ

២៥. កងពល"ស្រួច" របស់ ក.ប.ក និងកងវរសេនាធំឯករាជ្យរាយការណ៍ផ្ទាល់ទៅអគ្គសេនាធិការ ។ ដូចបានរៀបរាប់ខាងលើ កម្មាភិបាលកងពលជាន់ខ្ពស់ជួបគ្នាជាប្រចាំជាមួយនឹងបុគ្គលិកមកពីអគ្គសេនាធិការ រួមទាំង សុន សេន ដើម្បីរាយការណ៍លើសកម្មភាពដែលបានកើតឡើងនៅក្នុងកងរបស់ខ្លួន និងដើម្បីទទួលបញ្ជាបន្ថែមពីអគ្គសេនាធិការ ។ ការប្រជុំទាំងនេះ តែងផ្តោតទៅលើស្ថានភាពសត្រូវផ្ទៃក្នុង និងខាងក្រៅ ។

២៦. ជាទូទៅកងពលមួយរបស់ ក.ប.ក តែងតែមានកងវរសេនាធំចំនួនបី ហើយកងវរសេនាធំនីមួយៗមានកងវរសេនាតូចចំនួនបី[62] ។ កងវរសេនាធំឯករាជ្យមួយតែងតែមានកងវរសេនាតូចចំនួនបី ។

ភាគច្រើនកងពលរបស់ ក.ប.ក មានបុគ្គលិកចំនួនពី ៨០០ ទៅ ១,៨០០ នាក់[63] ។ កងពលស្រួចរបស់ ក.ប.ក មានកងនិរសារ កងវិទ្យុ និងកងទូរស័ព្ទ ដើម្បីជាជំនួយដល់ទំនាក់ទំនងនៅក្នុងកងពល ទំនាក់ទំនងជាមួយកងពលផ្សេង និង ជាមួយមជ្ឈិមបក្ស[64] ។

២៧. កងពលរបស់ ក.ប.ក ទទួលខុសត្រូវលើសន្តិសុខខាងក្រៅ ដែលមានន័យថាការពារព្រំដែនខ្មែរ[65] ។ ការធានាសន្តិសុខខាងក្រៅ ក៏មានន័យថាធ្វើជម្លោះប្រដាប់អាវុធអន្តរជាតិជាមួយប្រទេសវៀតណាម[66] និងថៃ[67] ផងដែរ ។ កងពលរបស់ ក.ប.ក ក៏បានទទួលខុសត្រូវចំពោះសន្តិសុខផ្ទៃក្នុង ដែលមានន័យថាកំណត់សម្គាល់ "សត្រូវ" "ជនក្បត់" និង សមាសភាពមិនល្អ[68] ។ ភាគច្រើនមនុស្សទាំងនេះត្រូវបានបញ្ជូនទៅមន្ទីរស-២១[69] ដើម្បីសម្លាប់ ។ គណៈមជ្ឈិមបានផ្តល់សិទ្ធិជាផ្លូវការឱ្យអគ្គសេនាធិការជាអ្នកសម្រេចថាតើត្រូវ "កម្ទេច" អ្នកណានៅក្នុង ក.ប.ក ប៉ុន្តែនៅក្នុងការអនុវត្តន៍ជាក់ស្តែង កម្មាភិបាលជាន់ខ្ពស់នៅតាមកងពលតែងតែជាអ្នកសម្រេចថាតើត្រូវចាប់ និងកម្ទេចអ្នកណានៅក្នុងកងពលរបស់ខ្លួន[70] ។ ជាចុងក្រោយ កងពលរបស់ ក.ប.ក ទទួលខុសត្រូវខាងផលិតកម្មអាហារ[71] ។

## ជម្លោះប្រដាប់អាវុធ
## ជាមួយវៀតណាម

២៨. ចាប់ពីខែមេសា ឆ្នាំ១៩៧៥ កងទ័ពកម្ពុជា និងវៀតណាម មានជម្លោះប្រដាប់អាវុធ[72] ។ ជម្លោះនេះបានកកើតឡើងពីទំនាស់ព្រំដែនរវាងកម្ពុជាប្រជាធិបតេយ្យនិងវៀតណាម (ក្រោយថ្ងៃទី២ ខែកក្កដា ឆ្នាំ១៩៧៦ គេហៅថា សាធារណរដ្ឋសង្គមនិយមវៀតណាម)[73] និងការយល់ឃើញរបស់មេដឹកនាំកម្ពុជាប្រជាធិបតេយ្យថា វៀតណាមចង់កាន់កាប់កម្ពុជា និងបង្កើតសហព័ន្ធឥណ្ឌូចិនមួយដែលដឹកនាំដោយវៀតណាមផ្ទាល់[74] ។ ការឃោសនាយ៉ាងមមាញឹកតាមរយៈទស្សនាវដ្តីបក្ស និងសុន្ទរកថារបស់ថ្នាក់ដឹកនាំបក្សត្រូវបានធ្វើឡើងនៅក្នុងពេលមានជម្លោះ[75] ។ វិសាលភាព និងភាពធ្ងន់ធ្ងរនៃជម្លោះនេះ បានរាលដាលយ៉ាងឆាប់រហ័សនៅក្នុងឆ្នាំបន្តបន្ទាប់[76] ហើយនៅទីបញ្ចប់បានឈានដល់ការឈ្លានពានទ្រង់ទ្រាយធំរបស់វៀតណាមមកលើកម្ពុជានៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ ១៩៧៨[77] ដែលបង្កឱ្យរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យដួលរលំ ។

២៩. ព្រំដែនកម្ពុជា និងវៀតណាមជាមូលហេតុជម្លោះ[78] ចាប់តាំងពីមានការកំណត់ខ្សែបន្ទាត់ប្រេវីយ៉េនៅឆ្នាំ១៩៣៩[79] ។ លើសពីនេះ កងទ័ពវៀតណាមរាប់ពាន់នាក់បានដាក់មូលដ្ឋាននៅកម្ពុជាតាំងពីទសវត្សរ៍៦០ និង៧០[80] ។ នៅខែមេសា ឆ្នាំ១៩៧៥ កងទ័ពវៀតណាមប្រមាណ ២០,០០០ នាក់ស្ថិតនៅក្នុងទឹកដីកម្ពុជា[81] ។ រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យបានបញ្ជាឱ្យទាហានទាំងនេះចាកចេញពីកម្ពុជានៅចុងខែ មេសា ឆ្នាំ១៩៧៥[82] ។ រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យបានបញ្ជូនកងទ័ពទៅតំបន់ព្រំដែនដើម្បីធានាថាកងទ័ពវៀតណាមបានចាកចេញពីកម្ពុជា ហើយការផ្ទុះអាវុធដំបូងបានកើតឡើងនៅក្នុងបរិបទនេះ[83] ។

៣០. ជម្លោះប្រដាប់អាវុធជាមួយវៀតណាម បានកើតឡើងក្នុងដំណាក់កាលសំខាន់ៗចំនួន ៦ ។ ដំណាក់កាលទី១ បានចាប់ផ្តើមនៅពាក់កណ្តាលឆ្នាំ១៩៧៥ និងបន្តដល់ឆ្នាំ១៩៧៦[84] ហើយក្នុងនោះមានការច្បាំងគ្នា ពីតំបន់រតនគីរី និងមណ្ឌលគីរីចុះទៅដល់កោះប៉ូឡូវ៉ៃ[85] និងជម្លោះដណ្តើមកោះត្រល់ (ភូគួក)[86] ។ នៅក្នុងដំណាក់កាលទី២ ដែលបានកើតកាលពីខែមីនា ដល់ខែសីហា ឆ្នាំ១៩៧៧ ជម្លោះបានរាល ដាលពីខេត្តមណ្ឌលគីរីចុះទៅខេត្តតាកែវ[87] ដោយមានកម្រិតខ្លាំងនៅម្តុំខេត្តស្វាយរៀង[88] ដែលបាន រាលដាលដោយការវាយលុករបស់កម្ពុជាប្រជាធិបតេយ្យទៅលើខេត្តតាយនិញនៅខែសីហា[89] ។ ដំណាក់កាលទី៣ ពីខែកញ្ញា ដល់ខែវិច្ឆិកា ឆ្នាំ១៩៧៧ មានកងទ័ពវៀតណាមវាយប្រហារនៅតាម ព្រំដែននៅខេត្តកំពង់ចាម ព្រៃវែង[90] ស្វាយរៀង និងតាកែវ ដោយប្រើប្រាស់អាវុធធុនធ្ងន់ និង កម្លាំងទ័ពប្រហែល ២០,០០០ នាក់[91] ។

៣១. ដំណាក់កាលទី៤ បានកើតឡើងតាំងពីខែធ្នូ ឆ្នាំ១៩៧៧ ដល់ខែមករា ឆ្នាំ១៩៧៨[92] នៅពេលដែលកងពលវៀតណាម[93] ចំនួន ១១ កងពលបានជ្រៀតចូលចម្ងាយ ២៥ ម៉ាយទៅក្នុងទឹកដីកម្ពុជា[94] មុនពេលត្រូវរុញចេញវិញដោយ ក.ប.ក[95] ។ នៅក្នុងដំណាក់កាលទី៥ ពីខែកុម្ភៈ ដល់ខែកញ្ញា ឆ្នាំ១៩៧៨[96] មានការវាយលុកជាញឹកញយពីវៀតណាមចូលមកខេត្តតាកែវ ខេត្តព្រៃវែង និង កំពង់ចាម[97] និងការវាយលុករបស់កម្ពុជាប្រជាធិបតេយ្យចូលទៅខេត្តចូវឌុក អានយ៉ាង កៀនយ៉ាង និងតាយនិញ[98] ។ ដំណាក់កាលទី៦ បានចាប់ផ្តើមពីខែកញ្ញា ឆ្នាំ១៩៧៨[99] ដោយមានការវាយលុកទ្រង់ទ្រាយធំពីវៀតណាមនៅដើមខែធ្នូ ឆ្នាំ១៩៧៨[100] ហើយបញ្ចប់ដោយការឈ្លានពានយ៉ាងធំប្រើប្រាស់កងទ័ពវៀតណាម ១៥០,០០០ នាក់[101] នៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៧៨[102] និងការវាយកាន់កាប់ទីក្រុងភ្នំពេញថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩[103] ។

## ជាមួយថៃ

៣២. យ៉ាងហោចនៅអំឡុងខែមិថុនា ឆ្នាំ១៩៧៥[104] និងបន្តរហូតដល់ខែកក្កដា ឆ្នាំ១៩៧៨ (យ៉ាងឆាប់)[105] កងទ័ពកម្ពុជា និងថៃបានប្រឡូកក្នុងជម្លោះ ។ ជម្លោះប្រដាប់អាវុធនេះមានវិសាលភាពតូចជាងជម្លោះរវាងខ្មែរ និងវៀតណាម ប៉ុន្តែក្នុងនោះមានការប្រើប្រាស់កងប្រដាប់អាវុធ នៅលើតំបន់ភូមិសាស្ត្រធំទូលាយ ហើយជម្លោះបន្តក្នុងរយៈពេល ៥ ឆ្នាំ ។ ក្នុងជម្លោះនេះ មានការវាយឆ្មក់ជាទ្រង់ទ្រាយតូចរវាងទ័ពថៃ និងកម្ពុជានៅតាមបណ្តោយព្រំដែនប្រទេសទាំងពីរ[106] និងការប៉ះទង្គិចគ្នារវាងកងទ័ពជើងទឹកថៃ និងកម្ពុជានៅក្នុងផ្ទៃទឹកកម្ពុជា-ថៃ[107] ។ នៅពេលខ្លះ ការប៉ះទង្គិចតូចតាចតាមព្រំដែនបានកើតឡើងស្ទើររាល់ថ្ងៃ[108] ។ នៅពេលខ្លះទៀត ការប្រយុទ្ធគ្នាមានលក្ខណៈស៊ីសាច់ហុតឈាម និងប្រើកងទ័ពមួយចំនួនធំ រថក្រោះ កាំភ្លើងធំ យន្តហោះ និងអាវុធធុនធ្ងន់ផ្សេងៗទៀត[109] ។

## ផែនការឧក្រិដ្ឋកម្មរួម

៣៣. ផែនការឧក្រិដ្ឋកម្មរួម ឬសហកម្មឧក្រិដ្ឋកម្មរួមមួយបានកើតឡើងនៅ ឬមុនថ្ងៃទី១៨ ខែសីហា ឆ្នាំ១៩៧៦[110] ហើយបានបន្តយ៉ាងឆាប់ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ។ គោលបំណងនៃផែនការឧក្រិដ្ឋកម្មរួមនេះ គឺកំណត់សម្គាល់សមាជិក ក.ប.ក ដែលត្រូវបានចោទប្រកាន់ថាជាខ្មាំង ឬជនក្បត់ ហើយដើម្បីចាប់ និងដាក់ឃុំដោយខុសច្បាប់ ធ្វើបាបដោយអមនុស្សធម៌ ធ្វើទារុណកម្ម និងសម្លាប់ ។ គោលដៅនៃផែនការឧក្រិដ្ឋកម្មរួមនេះ រួមបញ្ចូលការបដិសេធមិនឱ្យមានសិទ្ធិជាមូលដ្ឋាន ដូចជាសិទ្ធិមានសេរីភាព សន្តិសុខបុគ្គល និងទ្រព្យសម្បត្តិ សិទ្ធិការពារដោយផ្លូវច្បាប់ និងសិទ្ធិបញ្ចេញយោបល់ និយាយស្តី គិតគូរ និង សតិសម្បជញ្ញៈ ។ ផែនការឧក្រិដ្ឋកម្មនេះត្រូវបានអនុវត្តតាមរយៈការបោសសម្អាតជាច្រើនលើក ដែលបានគ្រោងនឹងធ្វើឡើងដោយអគ្គសេនាធិការ ក.ប.ក និងមន្ត្រីជាន់ខ្ពស់នៃកងពល និងវរសេនាធំឯករាជ្យ ។

៣៤. ចាប់ពី ឬមុនថ្ងៃទី១៨ ខែសីហា ឆ្នាំ១៩៧៦[111] គោលនយោបាយដោយចេតនាមួយនៃ ប.ក.ក និង ក.ប.ក ត្រូវបានបង្កើតឡើង ដែលក្រោមនយោបាយនេះ ការរើសអើងជាប្រព័ន្ធត្រូវបានធ្វើឡើងប្រឆាំងនឹងជនទាំងអស់ក្នុង ក.ប.ក ដែលត្រូវកំណត់ថា "មិនស្អាត" "មិនស្មោះ" ឬ "ក្បត់" ដោយមូលហេតុពិតប្រាកដ ឬយល់ឃើញថាប្រឆាំងនឹង ប.ក.ក ឬ ក.ប.ក ។ រាល់សមាសភាពមិនល្អ

ទាំងអស់ត្រូវកម្ចាត់ចោល[112] ដើម្បីធានាឱ្យបាននូវភាពបរិសុទ្ធ និងស្អាតស្អំនៃកងទ័ព និងដើម្បីការពារបដិវត្តន៍[113] ។ លេខា និងអនុលេខាកងពលត្រូវបានបញ្ជាឱ្យខំប្រឹងពិនិត្យកងពលរបស់ខ្លួនជានិច្ច និងប្រុងប្រយ័ត្នចំពោះសត្រូវ "ស៊ីរូងផ្ទៃក្នុង"[114] ។ ពួកវាត្រូវបានបញ្ជាឱ្យខំប្រឹងស្វែងរក "ប្រវត្តិរូប" បុគ្គលិកដើម្បីកំណត់សម្គាល់បុគ្គលិកដែលត្រូវកម្ទេច[115] ។

៣៥. បុគ្គលិកត្រូវបានចាត់ទុកថាជាជនក្បត់ និងចាប់ចងតាមរយៈកំហុសតូចតាចដូចជា ការលួច ការធ្វើវិទ្ធង្សនា ការមិនបំពេញកាតព្វកិច្ចយោធា ការមិនស្តាប់បញ្ជា ឬមាននិន្នាការសេរី[116] ។ អ្នកខ្លះទៀតត្រូវបានចោទថាជនក្បត់ សម្រាប់សកម្មភាពដែលប្រឆាំងនឹងមនោគមន៍វិជ្ជា និងនយោបាយបក្សដូចជា សួរនាំនឹងបញ្ជា មិនដើរតាមគោលដៅបដិវត្តន៍ និងផ្សព្វផ្សាយសតិអារម្មណ៍មិនល្អ[117] ។ កម្មាភិបាលខ្លះទៀត ត្រូវបានចាត់ជាជនសង្ស័យដោយសារមាន "ជាប់ខ្សែរយៈ" ជាមួយបងប្អូនដែល ប.ក.ក បានបោសសម្អាតរួចហើយ[118] ។

៣៦. បុគ្គលិកដែលត្រូវចាត់ថាមិនសូវមានគ្រោះថ្នាក់[119] ត្រូវបានដកហូតចេញពីកងពល[120] ហើយផ្ទេរទៅមន្ទីរអប់រំខ្លួន[121] ឬកងផលិតកម្ម និងការដ្ឋានការងារ[122] ។ ដល់ទីនោះ បុគ្គលិកតែងដាក់ឱ្យរស់នៅក្នុងលក្ខខណ្ឌបែបអមនុស្សធម៌ បង្អត់អាហារ និងបង្ខំឱ្យធ្វើការធ្ងន់[123] ។ អ្នកដែលគេយល់ថាមានគ្រោះថ្នាក់ខ្លាំង ឬមិនអាចអប់រំបាន[124] ត្រូវយកទៅ "កម្ទេច"[125] ។ អ្នកផ្សេងទៀតត្រូវបានឃុំឃាំងខុសច្បាប់នៅមន្ទីរស-២១ ឬមន្ទីរឃុំឃាំងផ្សេងទៀត[126] ដែលការធ្វើទារុណកម្ម លក្ខខណ្ឌរស់នៅបែបអមនុស្សធម៌ និងការកាប់សម្លាប់ជាលទ្ធផលយ៉ាងច្បាស់នៃការឃុំខ្លួន[127] ។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យគ្មានប្រព័ន្ធតុលាការ ឬយន្តការផ្លូវច្បាប់ណាមួយដែលអ្នកគេចាប់ឃុំខ្លួនតាមរយៈការសង្ស័យថាក្បត់ត្រូវបានផ្តល់នូវការកាត់ក្តីដ៏យុត្តិធម៌មួយទេ[128] ។ ការបោសសម្អាតនៅក្នុង ក.ប.ក ជាផ្នែកមួយមួយនៃសកម្មភាពបោសសម្អាតសត្រូវផ្ទៃក្នុងដែល ប.ក.ក បានអនុវត្តទូទាំងកម្ពុជាប្រជាធិបតេយ្យ[129] ។

៣៧. បុគ្គលដែលបានចូលរួមដោយដឹងខ្លួន និងពេញចិត្តនៅក្នុងផែនការឧក្រិដ្ឋកម្មរួម នៅក្នុងអំឡុងពេលនៃផែនការនេះ រួមបញ្ចូល តែមិនកំណត់ត្រឹម សុន សេន[130] **មាស មុត**[131] **ស៊ូ ម៉េត**[132] និងអ្នកផ្សេងទៀត ដូចជាលេខា និងអនុលេខាកងពល និងកងវរសេនាធំឯករាជ្យ ដែលរាយការណ៍ឱ្យអគ្គសេនាធិការ ។ បុគ្គលទាំងនេះបានចូលរួមក្នុងផែនការឧក្រិដ្ឋកម្មរួម ក្នុងនាមជាសហជនដែលដល់ដោយផ្ទាល់ ឬដោយប្រយោល ។ **ស៊ូ ម៉េត** និង **មាស មុត** បានដឹងឮ និងចូលរួមដោយចេតនា

នៅក្នុងផែនការជាប្រព័ន្ធ ដើម្បីឃុំដោយខុសច្បាប់ ជម្លៀសដោយបង្ខំ ធ្វើបាបដោយអមនុស្សធម៌ និងសម្លាប់បុគ្គលិក ក.ប.ក នៅតាមកងពលយោធាទាំងអស់ ដូចបានឆ្លុះបញ្ចាំងនៅក្នុងសកម្មភាពបោសសម្អាតជាបន្តបន្ទាប់ និងជាប្រព័ន្ធនូវសមាភាពមិនល្អនៅក្នុងជួរកងទ័ព ។ ជនសង្ស័យមានបំណង និងបានធ្វើ ឈានទៅសម្រេចផែនការជាប្រព័ន្ធនេះ តាមរយៈការបោសសម្អាតនៅក្នុងកងរបស់ខ្លួន ហេតុនេះពួកគេដឹង និងមានឆន្ទៈសម្រេចគោលដៅរួមរបស់ផែនការឧក្រិដ្ឋកម្មរួម ។

៣៨. ចាប់ផ្តើមនៅ ឬមុនថ្ងៃទី១៨ ខែសីហា ឆ្នាំ១៩៧៦ ផែនការឧក្រិដ្ឋកម្មរួមត្រូវបានពិភាក្សា ជំរុញ និងគ្រោងដោយ សុន សេន, **មាស មុត**, **ស៊ូ ម៉េត** និងអ្នកផ្សេងៗទៀតនៅក្នុងអង្គប្រជុំជាច្រើនរបស់អគ្គសេនាធិការ[133] ។ នៅក្នុងអង្គប្រជុំមួយចូលរួមដោយលេខា និងអនុលេខាកងពលនៃ ក.ប.ក នៅថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧៦ សុន សេន បានណែនាំសមាជិកអង្គប្រជុំអំពីភាពចាំបាច់ក្នុងការធានាថា ក.ប.ក "ស្អាតស្អំ" ហើយ "សត្រូវមិនអាចស៊ីរូងផ្ទៃក្នុង" បាន ។ កម្មាភិបាលត្រូវបានប្រាប់ឱ្យធ្វើអីដែលពួកគេគិតថាចាំបាច់ដើម្បីកម្ចាត់សត្រូវផ្ទៃក្នុងឱ្យអស់ពីក.ប.ក ។ សុន សេន បានបញ្ជាក់ម្តងហើយម្តងទៀត អំពីភាពចាំបាច់នៃការបោសសម្អាត "សមាភាពកខ្វក់" នៅក្នុងកងពលនីមួយៗ[134] ។

៣៩. ជាការឆ្លើយតប **ស៊ូ ម៉េត** បានប្រកាសថាគាត់ "សប្បាយចិត្ត" និងមាន "ជំនឿលើបក្ស" ក្នុងការកម្ចាត់ខ្សែរយៈក្បត់នៅក្នុង ក.ប.ក ហើយគាត់បានបញ្ជាក់ពីការយល់ស្របថាបក្សត្រូវតែ "ហ៊ានដាច់ខាត" ក្នុងការបន្តបោសសម្អាត ។ នៅក្នុងការប្រជុំដដែលនោះ **មាស មុត** បានបញ្ជាក់អំពីការបារម្ភរបស់គាត់ទាក់ទងទៅនឹងសកម្មភាពជនក្បត់នៅក្នុងបក្ស ហើយប្រកាសខ្លួនឯងថា "យល់ស្រប និងរួបរួមទាំងស្រុង" ជាមួយគោលដៅរួមនៃការបំបាត់សមាសភាពមិនល្អនៅក្នុងបក្ស ។ **មាស មុត** បានផ្តល់ការយល់ស្របរបស់គាត់ក្នុងការធ្វើអ្វីគ្រប់យ៉ាងដែលចាំបាច់ ដើម្បីគ្រប់គ្រងស្ថានភាពសត្រូវផ្ទៃក្នុង[135] ។ មេបញ្ជាការកងពល និងអនុមេបញ្ជាការដែលមានវត្តមាននៅក្នុងអង្គប្រជុំបានយល់ព្រមចូលរួមនៅក្នុងផែនការបោសសម្អាតអគ្គសេនាធិការ[136] ។

៤០. នៅក្នុងអង្គប្រជុំក្រោយៗរវាងលេខា និងអនុលេខាកងពល សុន សេន បានប្រមូលព័ត៌មានអំពីលទ្ធផលនៃការបោសសម្អាតផ្ទៃក្នុង និងបន្តជំរុញលេខា និងអនុលេខាកងពលឱ្យបោសសម្អាតជនក្បត់ពីក្នុងជួរកងទ័ព ឬអ្នកដែលមានប្រវត្តិរូបមិនល្អ[137] ។ **ស៊ូ ម៉េត** និង **មាស មុត** តែងតែមានវត្តមាននៅក្នុងអង្គប្រជុំទាំងនេះ ហើយបានរៀបរាប់អំពីជោគជ័យក្នុងការអនុវត្តផែនការបោស

សម្អាត[138] ។ នៅក្នុងទូរលេខក្រោយមួយទៅកាន់មន្ទីរ៨៧០ **មាស មុត** បានបញ្ជាក់អំពីចំណង់របស់គាត់ក្នុងការបោសសម្អាតសមាសភាពអាក្រក់ និងសត្រូវទាំងអស់[139] ។

៤១. សមាជិកនីមួយៗនៅក្នុងផែនការឧក្រិដ្ឋកម្មរួម បានធ្វើដោយឯកឯង ឬជាមួយសហជនដែលដល់មានឈ្មោះ ឬគ្មានឈ្មោះ ដើម្បីសម្រេចផែនការឧក្រិដ្ឋកម្មរួម តាមរយៈការប្រើប្រាស់ *អំណាចជាក់ស្តែង* ឬ *អំណាចតាមនីតិន័យ* ។ ជនសង្ស័យដឹងអំពី ហើយអនុវត្តការគ្រប់គ្រងទាំងស្រុងទៅលើបទឧក្រិដ្ឋដែលធ្វើឡើងដោយអ្នកនៅក្រោមបង្គាប់ ពីព្រោះជនសង្ស័យមានតំណែងខ្ពស់នៅក្នុង ក.ប.ក តួនាទីនៅក្នុងសង្វាក់បញ្ជាការយោធា ដែលមានដំណើរការតាមរយៈការចូលរួមអង្គប្រជុំជាន់ខ្ពស់របស់ ក.ប.ក និងតាមរយៈការសង្កេតការងាររបស់កូនចៅក្រោមបង្គាប់[140] ។ សុន សេន, **មាស មុត, ស៊ូ ម៉េត** និងអ្នកផ្សេងៗទៀតបានប្រព្រឹត្តទង្វើឧក្រិដ្ឋ ដែលបានរៀបរាប់នៅក្នុងកថាខណ្ឌទី៤៣ ដល់ ៦៦ តាមរយៈការរៀបចំ និងចូលរួមនៅក្នុងផែនការឧក្រិដ្ឋកម្មរួមតាមទម្រង់ផ្សេងៗដែលបានរៀបរាប់ ហើយធ្វើឡើងដោយចេតនាចាំបាច់ដូចរៀបរាប់ខាងលើ ។ ទង្វើរបស់ជនសង្ស័យបានបង្កឱ្យមានការស្លាប់មនុស្សរាប់ពាន់នាក់ក្នុងជួរ ក.ប.ក និងគ្រប់កងពលទាំងអស់ ។ បុគ្គលិកជាច្រើននាក់ទៀតបានទទួលរងការបង្ខំឱ្យធ្វើការធ្ងន់ ការដាក់ឃុំមិនស្របច្បាប់ និងការធ្វើបាបដោយអមនុស្សធម៌ ។

## បទឧក្រិដ្ឋ

៤២. កិច្ចស៊ើបសួរដែលបានស្នើឡើង មិនមែនកំណត់ត្រឹមតែអង្គហេតុទាំងឡាយ ដែលបានរៀបរាប់នៅក្នុងកថាខណ្ឌទី៤៣ ដល់ ៤៦ ខាងក្រោមតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងពង្រីកទៅដល់គ្រប់អង្គហេតុទាំងអស់ដែលបានរៀបរាប់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី២នេះទៀតផង ឱ្យតែអង្គហេតុទាំងនោះជួយដល់ការស៊ើបសួរ៖ ទី១) ធាតុផ្សំខាងយុត្តាធិការដែលចាំបាច់ដើម្បីសន្មតថាតើស្ថានភាពអង្គហេតុដែលបានរៀបរាប់ នៅក្នុងកថាខណ្ឌទី៤៣ ដល់ ៦៦ អាចបង្កបានជាបទឧក្រិដ្ឋដែលស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក ដែរ ឬទេ ។ ទី២) វិធីនៃការទទួលខុសត្រូវរបស់ជនសង្ស័យទាំងឡាយដែលមានឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនេះ ។

៤៣. ដូចបានរៀបរាប់ខាងលើអំពីសហកម្មឧក្រិដ្ឋកម្មរួម លេខានិងអនុលេខានៃកងពលរបស់ ក.ប.ក បានយល់ស្របទៅលើផែនការឧក្រិដ្ឋកម្ម ដើម្បីបោសសម្អាតនៅក្នុងកងពលរបស់ ក.ប.ក ដែលរាយការណ៍ជូនអគ្គសេនាធិការ ។ ការធ្វើបែបនេះ ធ្វើឱ្យបុគ្គលិក ក.ប.ក រាប់ពាន់នាក់ត្រូវបានបញ្ជូនទៅមន្ទីរស-២១ ដើម្បីសម្លាប់ ។ ការវិភាគមួយដែលបានធ្វើឡើងដោយការិយាល័យសហព្រះរាជអាជ្ញា ទៅលើបញ្ជីអ្នកទោសពីមន្ទីរស-២១ (បញ្ជីអ្នកទោសមន្ទីរស-២១ សរុប) បានបង្ហាញថា មានអ្នកទោសចំនួនជាង ១២,៣៨០ នាក់ ត្រូវបានឃុំឃាំង រួចសម្លាប់នៅមន្ទីរស-២១ ឬជើងឯក ។ យ៉ាងហោចណាស់មានមនុស្សចំនួន ៤,៥៥៧ នាក់ (៣៧ភាគរយ) ត្រូវបានចាប់ពីកងទ័ពកម្ពុជាប្រជាធិបតេយ្យ[141] ។ មានភ័ស្តុតាងបញ្ជាក់ថា បុគ្គលិក ក.ប.ក ត្រូវបានបញ្ជូនទៅមន្ទីរស-២១ ពីកងពល "ស្រួច" របស់ ក.ប.ក រួមទាំងកងពលធំលេខ ១៦៤[142] កងពលធំលេខ ១៧០[143] កងពលធំលេខ ២៩០[144] កងពលធំលេខ ៣១០[145] កងពលធំលេខ ៤៥០[146] កងពលធំលេខ ៥០២[147] កងពលធំលេខ៧០៣[148] កងពលធំលេខ ៨១០[149] និង កងពលធំលេខ ៩២០[150] និងកងវរសេនាធំឯករាជ្យទាំងអស់[151]៖ កងវរសេនាធំលេខ ១៥២[152] កងវរសេនាធំលេខ ៣៧៧[153] និង កងវរសេនាធំលេខ ៤៨៨[154] ។ បុគ្គលិកមកពីអគ្គសេនាធិការក៏ត្រូវបានបោសសម្អាតផងដែរ ដែលត្រូវបានបញ្ជូនទៅមន្ទីរស-២១[155] ។

## កងពលធំលេខ ៥០២
## សេចក្តីសង្ខេបនៃបទឧក្រិដ្ឋ

៤៤. កងពលធំលេខ ៥០២ ត្រូវបានបង្កើតឡើងភ្លាមៗ ក្រោយពីការដួលរលំនៃទីក្រុងភ្នំពេញ នៅខែមេសា ឆ្នាំ១៩៧៥ ដោយការបញ្ចូលបុគ្គលពីកងទាំងឡាយដែលមានស្រាប់[156] ។ ជាទូទៅ អ្នកដែលត្រូវបានបញ្ជូនទៅកងពលធំលេខ ៥០២ ត្រូវបានគេផ្លាស់ឱ្យទៅ ពីព្រោះអ្នកនោះមាន "ប្រវត្តិរូបល្អ" ឬមានប្រវត្តិការងារល្អ[157] ។ អ្នកដែលមាន "ប្រវត្តិរូបមិនល្អ" ឬអ្នកដែលគេយល់ថាមានខ្សែរយៈក្បត់ត្រូវ បានបញ្ជូនទៅធ្វើការនៅការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង[158] ។

៤៥. បុគ្គលិកកងពលធំលេខ ៥០២ ត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការភ័យខ្លាចជានិច្ចអំពីការចាប់ខ្លួន ឬយកទៅសម្លាប់[159] ។ ពួកគេត្រូវបានសួរនាំជាបន្តបន្ទាប់ដោយមេដឹកនាំកងពលអំពីវត្តមានបណ្តាញខ្សែក្បត់ ហើយពួកគេមិនត្រូវបានអនុញ្ញាតឱ្យចាកចេញពីកងរបស់ខ្លួន ឬទាក់ទងជាមួយនរណា

00291941



ម្នាក់នៅក្រៅកងទេ[160] ។ សមាជិកនៃកងពលធំលេខ ៥០២ ដែលត្រូវបានកំណត់អត្តសញ្ញាណថាជា "សមាភាពមិនល្អ" ឬឆ្លើយដាក់នៅក្នុងចម្លើយសារភាព ត្រូវបានតាមដានយ៉ាងប្រុងប្រយ័ត្ន[161] ។ កំហុសត្រូវបានរាយការណ៍តាមខ្សែសង្វាក់បញ្ជាការ ដែលក្រោយពីនេះមនុស្សដែលបានប្រព្រឹត្តកំហុសត្រូវបានចាប់ ។ មានកង "កម្លាំងពិសេស" ដែលរាយការណ៍ផ្ទាល់ទៅមេបញ្ជាការកងពលធំលេខ ៥០២ និងទទួលខុសត្រូវខាងសន្តិសុខ ។ កងនេះកំណត់អត្តសញ្ញាណអ្នកដែលបានធ្វើកំហុស និងចាប់អ្នកទាំងនោះ ។ អ្នកដែលត្រូវគេចាប់មិនដែលបានត្រឡប់មកវិញឡើយ[162] ។ បុគ្គលិកដែលត្រូវបានចោទប្រកាន់ថាជាប់ខ្សែក្បត់ត្រូវបានបញ្ជូនចេញ[163] ។ ជាច្រើននាក់ត្រូវបានបញ្ជូនទៅមន្ទីរស-២១ ដើម្បីសម្លាប់[164] ។ ខណៈដែលការបោសសម្អាតនៅក្នុងកងពលបន្ត បុគ្គលិកត្រូវបានបញ្ជូនឱ្យទៅធ្វើការនៅការដ្ឋានសាងសង់នៅព្រលានយន្តហោះខេត្តកំពង់ឆ្នាំង[165] ឬដីករណ្ដៅនៅមន្ទីរស-២៤[166] ។

## មន្ទីរសន្តិសុខស-២២

៤៦. កងពលធំលេខ ៥០២ មានមន្ទីរសន្តិសុខផ្ទាល់ខ្លួន ដែលគេស្គាល់ថាជាមន្ទីរស-២២ ។ បុគ្គលិកកងពលធំលេខ ៥០២ ថ្នាក់ទាបត្រូវបានបញ្ជូនទៅមន្ទីរស-២២ ប្រសិនបើត្រូវចោទប្រកាន់ថាមានទោសក្បត់[167] ។ ក្រោយពីមកដល់មន្ទីរស-២២ អ្នកទោសត្រូវបានដាក់ខ្នោះ និងដាក់ឃុំ ។ សូម្បីតែអ្នក "ទោសស្រាល" ក៏ត្រូវបានវាយដំក្នុងពេលសួរចម្លើយដែរ ។ របបអាហារមានកម្រិតតិចតួច[168] ។ វត្តមាននៃមន្ទីរសន្តិសុខមួយនៅក្នុងកងពលធំលេខ ៥០២ ត្រូវបានបញ្ជាក់ដោយសំបុត្ររវាងកម្មាភិបាលជាន់ខ្ពស់របស់កងពលធំលេខ ៥០២ និង កាំង ហ្គេកអ៊ាវ ហៅ ឌុច (*ចាប់ពីនេះទៅហៅថា* ឌុច) ប្រធានមន្ទីរស-២១ ។ សំបុត្រនេះនិយាយអំពីបុគ្គលិកកងពលធំលេខ ៥០២ ដែលត្រូវបានចាប់ដាក់ឃុំ និងសួរចម្លើយនៅកងពលធំលេខ ៥០២ មុននឹងបញ្ជូនទៅមន្ទីរស-២១[169] ។ ឌុច បានថ្លែងថា មន្ទីរសន្តិសុខទាំងអស់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យបានប្រើប្រាស់វិធីសាស្ត្រសួរចម្លើយ និងសម្លាប់ដូចនៅមន្ទីរស-២១[170] ។

## ការដ្ឋានសាងសង់ព្រលានយន្តហោះខេត្តកំពង់ឆ្នាំង

៤៧. កងពលធំលេខ ៥០២ ទទួលខុសត្រូវសាងសង់ព្រលានយន្តហោះយោធាមួយនៅក្បែរឃុំក្រាំងលាវ ស្រុករលៀប្អៀរ ខេត្តកំពង់ឆ្នាំង ក្នុងភូមិភាគបស្ចិម[171] ។ ការសាងសង់ព្រលានយន្តហោះដែលបាន

00291942



ធ្វើឡើងក្រោមបញ្ជាផ្ទាល់របស់គណៈអចិន្ត្រៃយ៍ ប.ក.ក[172] ។ កម្មាភិបាលនានា ដែលទទួលបន្ទុកមើលការខុសត្រូវការដ្ឋានមានប្រភពមកពីកងពលធំលេខ ៥០២[173] រួមទាំងមេបញ្ជាការការដ្ឋានដែលមានឈ្មោះ ល្វៃ[174] ។ ល្វៃ ដែលរាយការណ៍ផ្ទាល់ទៅ **ស៊ូ មេត**[175] ជាសមាជិកនៃគណៈកងពលធំលេខ ៥០២ និងជាកម្មាភិបាលដែលមានឋានៈខ្ពស់បំផុតទី៣ នៅក្នុងកងពលធំលេខ ៥០២[176] ។ ការដ្ឋានសាងសង់ព្រលានយន្តហោះមានតួនាទីជាកន្លែងអប់រំ ឬកន្លែងលត់ដំសម្រាប់កម្មាភិបាលកម្ពុជាប្រជាធិបតេយ្យ ហើយត្រូវបានប្រើប្រាស់ដើម្បីមើលការខុសត្រូវលើ "សមាសភាពអាក្រក់" មកពីកងផ្សេងៗក្នុង ក.ប.ក[177] ។

៤៨. ការសាងសង់ព្រលានយន្តហោះបានចាប់ផ្តើមពីឆ្នាំ១៩៧៧[178] ។ កម្មករនៅការដ្ឋានត្រូវ បានប្រមូលមកពីភូមិភាគទាំងអស់[179] ។ ទាហានកម្ពុជាប្រជាធិបតេយ្យម្នាក់បានសន្និដ្ឋានថា កម្មករចំនួន ២៧,០០០ នាក់ត្រូវបានប្រើប្រាស់ក្នុងការងារសំណង់[180] ។ សាក្សីម្នាក់ទៀតបានសន្និដ្ឋានថា កម្លាំងសរុបមានទំហំស្មើបីកងពលធំនៅក្នុងរយៈពេលណាមួយ[181] ។ អ្នកដែលបានបញ្ជូនទៅកំពង់ឆ្នាំងត្រូវបានដាក់ទណ្ឌកម្មសម្រាប់ការជាប់ពាក់ព័ន្ធសកម្មភាពក្បត់[182] ពិសេសមានទំនាក់ទំនងជាមួយវៀតណាម[183] ហើយពួកនេះត្រូវបានបញ្ជាឱ្យខំប្រឹងធ្វើការដើម្បី"កែប្រែ"ខ្លួនឯង[184] ។ កម្មាភិបាលថ្នាក់ក្រោមដែលត្រូវបានចាប់ ត្រូវបានបញ្ជូនទៅកំពង់ឆ្នាំងតាមរយៈគោលនយោបាយបក្សដែលថា "ដកស្មៅ ត្រូវដកទាំងឫស"[185] ។

៤៩. ជាពិសេស យ៉ាងហោចណាស់ក៏មានជនជាប់ឃុំជាច្រើននាក់ ដែលមកពីកងពលធំលេខ ១១, កងពលធំលេខ ៣១០ ភូមិភាគឧត្តរ និងភូមិភាគបូព៌ា ។ រយៈពេលបន្តិច មុនបង្កើតកងពលលេខ ៥០២ កម្មាភិបាលដឹកនាំជាន់ខ្ពស់នៃកងពលលេខ ១១ ត្រូវបានចាប់និងចោទពីបទក្បត់ជាតិ ។ យុទ្ធជនមកពីកងពលធំលេខ ១១ ដែលគ្មានភាពកខ្វក់នៅក្នុងប្រវត្តិរូប ត្រូវបានផ្ទេរទៅកងពលធំលេខ ៥០២ ។ អ្នកដែលមិនស្អាតស្អំត្រូវបានបញ្ជូនទៅកំពង់ឆ្នាំង[186] ។ សមាជិកជាច្រើននៃកងពលធំលេខ ៣១០ ត្រូវបានបញ្ជូនទៅធ្វើការនៅការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង[187] ក្រោយពីមានការបោសសម្អាតកងពលធំលេខ ៣១០ នៅដើមឆ្នាំ១៩៧៧[188] ។ ទាហានភូមិភាគឧត្តរមួយចំនួនធំដែលបានវាយជាមួយកងទ័ពវៀតណាមនៅភូមិភាគបូព៌ា ត្រូវបានបញ្ជូនទៅកំពង់ឆ្នាំងនៅពាក់កណ្តាលឆ្នាំ១៩៧៨ ដោយមូលហេតុថាអ្នកដែលនៅរស់ពីការប្រយុទ្ធជាមួយវៀតណាមច្បាស់ជាជនក្បត់[189] ។ ចុងបញ្ចប់ ទាហានភូមិភាគបូព៌ារាប់ពាន់នាក់ ត្រូវបានចាប់ក្រោយពីលេខាភូមិភាគបូព៌ាឈ្មោះ សោ ភឹម និងត្រូវបានដាក់ឃុំនៅការដ្ឋានសាងសង់

ព្រលានយន្តហោះកំពង់ឆ្នាំង ក្នុងខែមេសា ឆ្នាំ១៩៧៨[190] ។ ទាហានកងពលធំនៃភូមិភាគបូព៌ា នៅការដ្ឋានសាងសង់ព្រលានយន្តហោះ រួមមានទាំងកុមារផង[191] ។

៥០. កម្មករនៅការដ្ឋានសាងសង់ត្រូវបានបង្ខំឱ្យសម្អាតដី បំបែកថ្ម ដឹករំលើងគល់ឈើ ក្រាលថ្ម និងចាក់ស៊ីម៉ងត៍ នៅក្រោមការឃ្លាំមើលជានិច្ច[192] ។ ស្ត្រីត្រូវបានចាត់តាំងឱ្យធ្វើស្រែ[193] ។ ការងារទាំងអស់ ត្រូវធ្វើដោយដៃ[194] ។ ការងារចាប់ផ្តើមពីម៉ោង ៧ ព្រឹក រហូតដល់ម៉ោង ១១ យប់[195] ។ កម្មករស្លាប់រាល់ថ្ងៃដោយសារ "គ្រោះថ្នាក់" ដែលកើតចេញពីការងារពលកម្មហត់នឿយ និងមិនឈប់ឈរ[196] ។ របបអាហារមានកម្រិតតិចតួច[197] ។ កម្មករដែលមានសំណាងអាចទទួលបានរបបចំនួនពីរកំប៉ុងក្នុងមួយថ្ងៃ[198] តែភាគច្រើនទទួលបានតែមួយកំប៉ុង ហើយត្រូវរកគ្រាប់ល្ពៅតមកញ៉ាំបន្ថែម[199] ។ កម្មករមានរូបរាងស្គាំងស្គម និងសុខភាពទ្រុឌទ្រោម[200] ។ សាក្សីម្នាក់បានរៀបរាប់ថា កម្មករអត់អាហារមានក្បាលជង្គង់ធំជាងក្បាល[201] ។ កម្មករត្រូវគេដាក់សម្ពាធជានិច្ច នៅក្នុងអង្គប្រជុំ ហើយធ្វើការកាន់តែខ្លាំង[202] ។ កម្មករណាដែលមិនព្រម "កែប្រែ" ខ្លួនឯងមានកំហុស ឬមិនគោរពតាមបញ្ជា អ្នកយាមត្រូវចាប់ខ្លួនមួយរំពេច[203] ។ កម្មករថ្មីៗត្រូវបានបញ្ជូនមកដល់ជាបន្តបន្ទាប់ដើម្បីជំនួសអ្នកដែលគេដក[204] ។ កម្មករជាច្រើនបានស្លាប់នៅការដ្ឋានសាងសង់ ពីព្រោះពួកគេត្រូវគេធ្វើបាបដូច "ទាសករ"[205] ។

៥១. បើតាមសម្តីទាហានម្នាក់ដែលមានវត្តមាននៅការដ្ឋាន កម្មករត្រូវគេយកទៅសម្លាប់គ្រប់ពេល[206] ។ អ្នកដែលធ្វើមិនត្រូវចិត្តអ្នកយាម តែងត្រូវគេសម្លាប់នៅក្នុងព្រៃខាងលិចការដ្ឋានព្រលានយន្តហោះ[207] ។ កម្មកររាប់រយនាក់អាចត្រូវគេសម្លាប់នៅទីនោះ[208] ។ លើសពីនេះ កម្មករត្រូវបាន "បញ្ជូនទៅ" សម្លាប់ជាបន្តបន្ទាប់[209] ភាគច្រើនត្រូវគេដាក់ឡានទ្រុងទៅមន្ទីរស-២១ និងគុកផ្សេងៗទៀតដើម្បីសម្លាប់[210] ។ អ្នកដែលត្រូវគេសម្លាប់ជាច្រើនទៀត ត្រូវបានបញ្ជូនទៅមន្ទីរសន្តិសុខស្រុក ១៤ នៅស្រុកទឹកផុស ត្រង់កន្លែងមួយហៅក្រសាំងដុះឡើង ក្នុងភូមិក្បាលទឹក[211] ។ ទាហាននៅព្រៃស (មន្ទីរស-២៤) បានឃើញកម្មករសាងសង់ព្រលានយន្តហោះត្រូវគេ បញ្ជូនដាក់ឡានទៅមន្ទីរស-២១ ដើម្បីសម្លាប់[212] ។ ការសម្លាប់ទ្រង់ទ្រាយធំបានកើតឡើងនៅពេលដែលកងទ័ពវៀតណាមចូលក្បែរការដ្ឋានសាងសង់ព្រលានយន្តហោះនៅឆ្នាំ១៩៧៨[213] ហើយអ្នកទោសត្រូវបានដកចេញពីការដ្ឋានជាច្រើនឡាន[214] ។ ជាពិសេសកម្មករពីភូមិភាគបូព៌ាត្រូវបានសម្លាប់ទាំងក្រុមៗ នៅពេលវៀតណាមចូលដល់[215] ។

# កងពលធំលេខ ១៦៤
## សេចក្ដីសង្ខេបនៃបទឧក្រិដ្ឋ

៥២. មានភស្តុតាងបញ្ជាក់ថា បុគ្គលិកកងពលធំលេខ ១៦៤ ត្រូវទទួលរងការចាប់ដោយស្របច្បាប់ និងបង្ខំឱ្យធ្វើការធ្ងន់ជាញឹកញយ ។ ឧទាហរណ៍ មេបញ្ជាការកងពលធំលេខ ១៦៤ បានរាយការណ៍ជាច្រើនលើកថាសត្រូវផ្ទៃក្នុងត្រូវបានចាប់[216] ។ ជាងនេះទៀត បញ្ជីឈ្មោះអ្នកទោសពីមន្ទីរស-២១ បានបង្ហាញថាបុគ្គលិកកងពលលេខ ១៦៤ ជាច្រើនត្រូវបានចាប់នៅក្នុងកងពលមុនពេលត្រូវបញ្ជូនទៅសួរចម្លើយ និងសម្លាប់[217] ។

៥៣. យ៉ាងហោចណាស់មានការបោសសម្អាតដ៏ធំមួយនៅកងពលលេខ ១៦៤ ។ ទាហានមួយកងវរសេនាធំ មកពីភូមិភាគបូព៌ាត្រូវបានបញ្ជូនពីភ្នំពេញ ជាផ្នែកមួយនៃកងទ័ពជើងទឹករបស់កម្ពុជាប្រជាធិបតេយ្យ[218] ។ មួយកងនេះមានបុគ្គលិកចំនួន ៥០០ ឬ ៦០០ នាក់ ហើយត្រូវបានដឹកនាំដោយបុគ្គលម្នាក់ឈ្មោះ ឌឹម[219] ។ ចាប់ពីខែកក្កដា ដល់ខែកញ្ញា ឆ្នាំ១៩៧៧ មាន "បញ្ហា"មួយចំនួននៅក្នុងអង្គភាពមកពីភូមិភាគបូព៌ា[220] ។ បុគ្គលិកកងពលធំលេខ ១៦៤ ត្រូវបានប្រាប់នៅក្នុងការប្រជុំនានាថា កងវរៈសេនាធំភូមិភាគបូព៌ាមានចេតនាជ្រៀតចូលក្នុងកងពលនេះ[221] ។ កងវរសេនាធំរបស់ភូមិភាគបូព៌ាត្រូវបានបោសសម្អាត ហើយមនុស្សត្រូវបានដឹកចេញទាំងឡានៗ[222] ។ យ៉ាងហោចណាស់ មនុស្សខ្លះដែលត្រូវកម្ទេច ត្រូវបានបញ្ជូនទៅមន្ទីរសន្តិសុខវត្តឥន្ទញាណ[223] ។ ឌឹមដែលជាអនុលេខាកងពលបានបាត់ខ្លួន[224] ហើយការចាប់ខ្លួនផ្សេងទៀតបានកើតឡើង[225] ។

៥៤. បន្ថែមលើការបោសសម្អាតអ្នកមកពីភូមិភាគបូព៌ា អ្នកដែលត្រូវកំណត់ថាមានទំនាក់ទំនងជាមួយរបបមុនត្រូវបញ្ជូនចេញ ហើយអាចត្រូវបានសម្លាប់[226] ។ អ្នកខ្លះត្រូវកោះហៅឱ្យទៅប្រជុំ ហើយមិនដែលត្រឡប់មកវិញទេ[227] ។ ជាលទ្ធផល ទាហានភ័យខ្លាចគ្នាឯង ពិសេសនៅពេលដែលត្រូវគេហៅទៅប្រជុំជាមួយថ្នាក់លើរបស់ខ្លួន[228] ។ បរិយាកាសពោរពេញទៅដោយការមិនទុកចិត្តគ្នា និង មានការភ័យខ្លាចមិនសមហេតុផលហួសហេតុ (paranoia)[229] ។

## មន្ទីរសន្តិសុខវត្តឥន្ទញាណ

00291945



៥៥. ឯកសារ ក.ប.ក និងសំបុត្រឆ្លងឆ្លើយគ្នាបានបញ្ជាក់ថាកងពលធំលេខ ១៦៤ បានគ្រប់គ្រងមន្ទីរសន្តិសុខមួយ ។ ឯកសារជាច្រើនបញ្ជាក់ថាមានការចាប់ខ្លួននៅក្នុងកងពល[230] ហើយថាខ្មាំងដែលបានចាប់ខ្លួន ត្រូវបានសួរចម្លើយនៅក្នុងកងពល[231] ។ លើសពីនេះ មានឯកសារមួយនិយាយអំពីឧប្បត្តិហេតុមួយនៅថ្ងៃទី១១ ខែសីហា ឆ្នាំ១៩៧៦ ដែលក្នុងនោះ "យុទ្ធជនក្បត់" ចំនួនពីរនាក់បានសម្លាប់សមាជិកសន្តិបាលកងពលចំនួន បី-បួននាក់ ហើយបានដោះលែង "អ្នកជាប់ឃុំទាំងអស់ដែលមានបញ្ហា"[232] ។

៥៦. មន្ទីរសន្តិសុខកងពលធំលេខ ១៦៤ មានទីតាំង នៅកន្លែងមួយហៅវត្តឥន្ទញាណ[233] នៅក្រុងកំពង់សោម[234] ។ នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ អាគារខ្លះត្រូវបាក់បែក ហើយទីតាំងវត្តនេះត្រូវបានគេប្រើប្រាស់ជាមន្ទីរឃុំឃាំង[235] ។ គេបានសាងសង់របងនៅចម្ងាយ ៥០ ម៉ែត្រពីផ្លូវដើម្បីការពារកុំឱ្យមនុស្សចូលជិតទីតាំង[236] ។ គេប្រើប្រាស់មន្ទីរសន្តិសុខដើម្បីឃុំបុគ្គលិកកងពលធំលេខ ១៦៤ ដែលគេបានបោសសម្អាត[237] ។ នេះគឺរួមទាំងមនុស្ស មកពីកងវរសេនាធំភូមិភាគបូព៌ា ដែលត្រូវបានគេចោទថាចង់ជ្រៀតចូលទៅក្នុងកងពល ក៏ដូចជាអ្នកផ្សេងៗទៀតក្នុងកងពល ដែលត្រូវបានចោទពីបទក្បត់ជាតិ ឬ មិនស្មោះត្រង់[238] ។ អ្នកទោសត្រូវគេឃុំនៅក្នុងកុដិលោកមួយនៅទីកន្លែងនោះ[239] ។

៥៧. សាក្សីដែលបានទៅទស្សនាការដ្ឋាននៅឆ្នាំ ១៩៧៩ ក្រោយពីរបបកម្ពុជាប្រជាធិបតេយ្យត្រូវបានបញ្ចប់ បានឃើញខ្នោះចំនួន ៥០ ឬ ៦០ គូនៅក្នុងកុដិលោកមួយនៅភាគខាងត្បូងនៃវត្ត[240] ។ នៅទីនោះ មានដែកវែងៗជាច្រើន និងស្លាកស្នាមឈាមនៅលើជញ្ជាំងកុដិផងដែរ[241] ។ នៅដើមទសវត្សរ៍ឆ្នាំ ៨០ គេបានរកឃើញសំណល់សាកសពចំនួនប្រហែលជិត ២០០ នាក់ នៅទីតាំងកប់សពមួយកន្លែងចម្ងាយប្រមាណជា ១០០ ម៉ែត្រភាគខាងកើតនៃវត្ត[242] ។ សាកសពទាំងនោះត្រូវបានគេចងកដៃនិងចងកជើងជាប់នឹងខ្សែនីឡុង[243] ។ ភស្តុតាងអំពីមន្ទីរសន្តិសុខវត្តឥន្ទញាណ គឺត្រូវគ្នាទៅនឹងសក្ខីភាពរបស់ ឌុច ដែលថា មន្ទីរសន្តិសុខនៅទូទាំងកម្ពុជាប្រជាធិបតេយ្យ បានប្រើប្រាស់ប្រព័ន្ធសួរចម្លើយ និងសម្លាប់ដូចនៅមន្ទីរស-២១[244] ។

## ការដ្ឋានទំនប់ត្រពាំងធាប

៥៨. កងពលធំលេខ ១៦៤ បានគ្រប់គ្រងការដ្ឋានការងារបង្ខំឱ្យវាយថ្មមួយកន្លែង នៅជិតស្ទឹងហាវ ក្រុងកំពង់សោម[245] ។ ប្រជាជនដែលត្រូវគេគិតថាជា “សមាសភាពមិនល្អ” ឬមាន “និន្នាការ” ត្រូវបានបញ្ជូនទៅស្ទឹងហាវ[246] ។ ជនទាំងនេះរួមទាំងប្រជាជនដែលមានបងប្អូន ដែលធ្លាប់ជាសមាជិកនៃរបបមុន[247] ។ កម្មករ អ្នកនេសាទ និងសមាជិកនៃកងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យត្រូវបានបញ្ជូនទៅស្ទឹងហាវឱ្យទៅវែកថ្ម[248] ។ នៅការដ្ឋានវាយថ្មនេះមានកម្មករប្រមាណ ១០០ នាក់[249] ។

## កងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យ

៥៩. កងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យ ទទួលខុសត្រូវលើការការពារយ៉ាងមោះមុតនូវដែនទឹកអះអាងកាន់កាប់ដោយរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យប្រឆាំងនឹងការរំលោភព្រំដែន[250] ។ នៅក្នុងដំណើរការនេះ កងទ័ពជើងទឹកព្យាយាមចាប់ ឬកម្ទេចនាវាថៃ ឬវៀតណាមដែលចូលក្នុងផ្ទៃទឹកកាន់កាប់ដោយកម្ពុជាប្រជាធិបតេយ្យ[251] ដែលបង្កឱ្យមានការផ្ទុះអាវុធមួយចំនួនធំរវាងកងទ័ពជើងទឹកថៃ និងកម្ពុជាប្រជាធិបតេយ្យនៅក្នុងព្រំដែនទឹកប្រទេសទាំងពីរ[252] ។ កងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យក៏បានវាយប្រហារទៅលើនាវានេសាទថៃជាច្រើនដែរ ធ្វើឱ្យស្លាប់ ឬក៏ចាប់អ្នកនេសាទថៃ[253] ។

៦០. អ្នកនេសាទថៃមួយក្រុមតូចដែលចាប់បានត្រូវបានបញ្ជូនទៅប្រទេសថៃវិញ[254] ប៉ុន្តែរបាយការណ៍បានបញ្ជាក់ថាអ្នកនេសាទថៃជាច្រើននាក់ទៀតត្រូវបានឃុំខ្លួនដោយកងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យ[255] ។ ទង្វើនេះហាក់បីដូចជាផ្នែកមួយនៃគោលនយោបាយដ៏ធំមួយ ដែលមានបំណងចង់ចាប់ពលរដ្ឋថៃនៅតាមតំបន់ព្រំដែន[256] ។ អ្នកនេសាទថៃដែលចាប់បានខ្លះត្រូវបានបញ្ជូនទៅមន្ទីរស-២១ដើម្បីសម្លាប់ ។ បញ្ជីអ្នកទោសនៅមន្ទីរស-២១មួយបង្ហាញថា អ្នកនេសាទថៃចំនួន ៣១ នាក់ដែលគេចាប់នៅកំពង់សោម ត្រូវបានសម្លាប់នៅមន្ទីរស-២១ នៅថ្ងៃទី២៤ ខែឧសភា ឆ្នាំ ១៩៧៦[257] ។ អតីតអ្នកយាមគុកនៅមន្ទីរស-២១ ជាច្រើននាក់ក៏បានចងចាំអំពីការឃុំខ្លួនពលរដ្ឋថៃដែលក្នុងនោះមានអ្នកនេសាទថៃនៅមន្ទីរស-២១ ដែរ[258] ។

៦១. ពលរដ្ឋនៃប្រទេសផ្សេងទៀត ក៏ត្រូវបានចាប់ដោយកងទ័ពជើងទឹករបស់កម្ពុជាប្រជាធិបតេយ្យហើយបញ្ជូនទៅមន្ទីរស-២១ដែរ ។ ឧទាហរណ៍៖ មានបរទេសលោកខាងលិចយ៉ាងហោចណាស់ចំនួន ៤ នាក់ត្រូវបានចាប់ដោយកងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យនៅក្នុងផ្ទៃទឹកកម្ពុជា រួច

បញ្ជូនទៅមន្ទីរស-២១ ដែលជាកន្លែងសម្លាប់[259] ។ កងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យ បានវាយប្រហារទៅលើនាវាវៀតណាម[260] ហើយបានរាយការណ៍អំពីការចាប់ "ភ្នាក់ងារវៀតណាម" នៅសមុទ្រ[261] ។ សាក្សីម្នាក់បានបញ្ជាក់ថា ប្រជាជនវៀតណាមជា "ច្រើន" នាក់ត្រូវបានចាប់ដោយកងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យ រួចបញ្ជូនទៅទីបញ្ជាការកងពល១៦៤[262] ។ ប្រជាជនមួយចំនួនដែលត្រូវគេយល់ថាជា "គិញវៀតណាម" ហើយមានឈ្មោះវៀតណាម ត្រូវបានបញ្ជូនទៅមន្ទីរស-២១ ពីកងពលធំលេខ ១៦៤ និងពីកំពង់សោម[263] ។ យ៉ាងហោចណាស់ អ្នកទោសវៀតណាមខ្លះនៅមន្ទីរស-២១ ជាអ្នកនេសាទដែលត្រូវបានចាប់ពេលកំពុងនេសាទនៅក្នុងផ្ទៃទឹកក្បែរព្រំដែនវៀតណាម[264] ។ លើសពីនេះ តាមការសង្កេត ហាក់ដូចជាបង្ហាញថាអ្នកទោសខ្លះដែលបានសារភាពថាជាទាហានវៀតណាម ឬក៏ជាគិញវៀតណាម តាមការពិតជាជនស៊ីវិលវៀតណាមដែលកងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យចាប់បាន[265] ។ ឌុច ប្រធានមន្ទីរស-២១ បានទទួលស្គាល់ថា កងពលធំលេខ ១៦៤ មានតួនាទីមួយក្នុងការបញ្ជូនអ្នកនេសាទថៃ និងវៀតណាមដែលចាប់បានទៅមន្ទីរស-២១ ដើម្បីសម្លាប់[266] ។

## **វៀតណាម**

៦២. កម្មាភិបាលកងពលធំលេខ ១៦៤ បានដឹកនាំកងទ័ពមកពីកងពលផ្សេងៗ នៅពេលមានការវាយប្រហារទៅលើប្រទេសវៀតណាម នៅចុងឆ្នាំ១៩៧៧ និង ១៩៧៨[267] ។ កម្មាភិបាលកម្ពុជាប្រជាធិបតេយ្យ បានវាយប្រហារលើឃុំជាច្រើន ហើយសម្លាប់កងទ័ពវៀតណាមឱ្យបានច្រើនដូចដែលអាចធ្វើទៅបាន ហើយដុតផ្ទះ មន្ទីរពេទ្យ និងរោងចក្រ ។ ទោះបីជាកងទ័ពមិនមានបញ្ជាច្បាស់លាស់ថាឱ្យសម្លាប់ប្រជាជនវៀតណាមធម្មតាក៏ដោយ ក៏ជនស៊ីវិលជាច្រើននាក់ត្រូវបានសម្លាប់ ។ ប្រជាជនវៀតណាមដែលគេចាប់បានភាគច្រើនជាកុមារត្រូវបានបញ្ជូនទៅទីបញ្ជាការកងពល[268] ។ មានភស្តុតាងបញ្ជាក់ថា **មាស មុត** បានធ្វើដំណើរជាមួយកងទ័ពនៃកងពលធំលេខ ១៦៤ ទៅកាន់ភូមិភាគឦសានដើម្បីប្រយុទ្ធជាមួយវៀតណាម[269] ។

## **កងពលធំលេខ ៨០១**

## **គុក៨១០**

៦៣. កងពលធំលេខ ៨០១ បានគ្រប់គ្រងមន្ទីរសន្តិសុខរបស់ខ្លួននៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ។ ពីដំបូងកងវរសេនាធំនីមួយៗនៅក្នុងកងពលធំលេខ ៨០១ មានមន្ទីរសន្តិសុខដោយឡែកៗ[270] ។ នៅក្នុងឆ្នាំ១៩៧៦ មន្ទីរសន្តិសុខវរសេនាធំលេខ ៨១ មានទីតាំងនៅបរកែវ ស្រុកបរកែវ ខេត្តរតនគិរី[271] ។ ក៏ប៉ុន្តែ នៅចុងឆ្នាំ១៩៧៧ មន្ទីរសន្តិសុខកងវរសេនាធំទាំងបីត្រូវបានដាក់បញ្ចូលគ្នាជាមន្ទីរសន្តិសុខកងពលមួយ ដែលមានទីតាំងនៅស្រុកវើនសៃ ខេត្តរតនគិរី ជិតទីបញ្ជាការកងពលធំលេខ ៨០១[272] ។ មន្ទីរសន្តិសុខកងពលនេះត្រូវបានហៅថា គុក៨១០[273] ។ គុក៨១០ អាចឃុំអ្នកទោសបានប្រហែល ១០០ នាក់ ក្នុងមួយពេល[274] ហើយរាយការណ៍ផ្ទាល់ទៅ សូ សារុន[275] ដែលជាមេបញ្ជាកងពលធំលេខ ៨១០[276] ។ លក្ខខណ្ឌនៅគុក៨១០ មានលក្ខណៈប្រហាក់ប្រហែលគ្នានឹងគុកថ្នាក់វរសេនាធំពីមុនដែរ[277] ។

៦៤. នៅចុងឆ្នាំ១៩៧៦ កងពលធំលេខ ៨០១ បានសម្លាប់សមាជិករបស់ខ្លួនដែលមាន "ទំនាក់ទំនង" ទៅនឹងរបបសាធារណរដ្ឋខ្មែរ ជាទូទៅដោយសារញាតិសន្តានម្នាក់ធ្លាប់បានធ្វើការឱ្យរបបមុន[278] ។ សមាជិកដែលត្រូវបោសសម្អាត ត្រូវបានចាប់[279] ដាក់គុក ហើយត្រូវបានបញ្ជាឱ្យធ្វើការធ្ងន់ធ្ងររួមទាំងឱ្យភ្ជួរដោយដៃ ដោយគ្មានន័ង្គល ឬគោក្របី[280] ។ អ្នកទោសត្រូវបានឃាមកាមនៅពេលថ្ងៃនៅពេលដែលគេឱ្យធ្វើការ ហើយដាក់ឃុំទៅវិញនៅពេលយប់[281] ។ អ្នកទោសណាដែលបានធ្វើ "កំហុស" នៅពេលដែលកំពុងនៅក្នុងមន្ទីរសន្តិសុខ នឹងត្រូវគេដាក់ខ្នោះនៅពេលយប់ បង្អត់អាហារ វាយដំ និងជួនកាលសម្លាប់[282] ។ យើងមិនដឹងថាមានប្រជាជនចំនួនប៉ុន្មាននាក់ ដែលត្រូវបានសម្លាប់នៅគុក៨១០ ទេ[283] ។

## មន្ទីរសន្តិសុខ ក.ប.ក និងទីតាំងសម្លាប់ផ្សេងៗទៀត

៦៥. ការសង្កេតហាក់បញ្ជាក់ថា កងពលនីមួយៗបានគ្រប់គ្រងមន្ទីរសន្តិសុខរៀងខ្លួន បន្ថែមទៅលើការបញ្ជូនអ្នកទោសទៅមន្ទីរស-២១ ។ មន្ទីរសន្តិសុខនៃកងពលធំលេខ ៥០២, ១៦៤ និង ៨០១ ត្រូវបានបកស្រាយជាពិស្តារនៅក្នុងកថាខណ្ឌទី៤៦, ពីទី៥៥-៥៧ និង ពីទី៦៣-៦៤ ។ ក៏ប៉ុន្តែបើតាមភស្តុតាងទាក់ទងទៅនឹង កងពលធំលេខ ៥០២, ១៦៤ និង ៨០១ និងវត្តមាននៃប្រព័ន្ធមន្ទីរសន្តិសុខទូទាំងកម្ពុជាប្រជា ធិបតេយ្យ[284] សហព្រះរាជអាជ្ញា ជឿជាក់ថា កងពលធំផ្សេងៗទៀតនៃ ក.ប.ក ក៏បានដំណើរការ មន្ទីរសន្តិសុខនានាផងដែរ ដែលត្រូវបានប្រើប្រាស់ដើម្បីអនុវត្តការបោសសម្អាត ។

៦៦. លើសពីនេះ ការបោសសម្អាតនៃ ក.ប.ក ត្រូវបានធ្វើឡើងនៅទីតាំងឧក្រិដ្ឋកម្មផ្សេងទៀតដែលជាផ្នែកមួយនៃការស៊ើបសួររបស់តុលាការរួចទៅហើយ ។ ឧទាហរណ៍៖ ទីតាំងសម្លាប់ស្ទឹងតូចនៅភូមិភាគបូព៌ា[285] ត្រូវបានប្រើប្រាស់ដើម្បីសម្លាប់ទាហានភូមិភាគបូព៌ាក្នុងចំនួនដ៏ច្រើន ។ បើតាមសាក្សីម្នាក់ រណ្តៅសាកសពនៅស្ទឹងតូចគឺពោរពេញទៅដោយទាហានភូមិភាគបូព៌ា ដែលអាចត្រូវបានកំណត់អត្តសញ្ញាណតាមរយៈឯកសណ្ឋានកងទ័ព ចាន-ឆ្នាំង ខ្សែក្រវ៉ាត់ និងស្បែកជើងធ្វើពីកង់ឡាន[286] ។ ការសង្កេតបង្ហាញថា សមាជិក ក.ប.ក ត្រូវបានបោសសម្អាតនៅក្នុងដំណាក់កាលនៃការបោសសម្អាតនៅភូមិភាគកណ្តាល(ភូមិភាគឧត្តរចាស់)[287] ការបោសសម្អាតនៅភូមិភាគឧត្តរថ្មី[288] និង ការបោសសម្អាតនៅភូមិភាគបូព៌ា[289] ។

## ជនសង្ស័យ

៦៧. សហព្រះរាជអាជ្ញាមានហេតុផលជឿថា **ស៊ូ ម៉េត** និង **មាស មុត** បានប្រព្រឹត្តអំពើឧក្រិដ្ឋជាក់លាក់ដែលបានរៀបរាប់នៅក្នុងកថាខណ្ឌទី៤៣-៦៦ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី២ នេះ ដែលបង្កើតបានជាបទល្មើសនៅក្រោមច្បាប់ អ.វ.ត.ក ។

## ស៊ូ ម៉េត

### ព័ត៌មានផ្ទាល់ខ្លួន

៦៨. មុនឆ្នាំ១៩៧០ **ស៊ូ ម៉េត** គឺជាគ្រូបង្រៀនម្នាក់ ។ ពីឆ្នាំ១៩៧០ ទៅខែមេសា ឆ្នាំ១៩៧៥ គាត់ជាប្រធានកងពលធំមួយរបស់ ប.ក.ក[290] ។ នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ គាត់ជាលេខាកងពលធំលេខ ៥០២ នៃ ក.ប.ក ។ ក្រោយសម័យកម្ពុជាប្រជាធិបតេយ្យ គាត់នៅតែជាកម្មាភិបាលជាន់ខ្ពស់ម្នាក់នៃកងទ័ពរបស់ ប.ក.ក[291] ។ គាត់ត្រូវបានគេរាយការណ៍ថា បានរស់នៅសំឡូតអស់មួយរយៈនៅអំឡុងពេលទសវត្សរ៍ ឆ្នាំ១៩៨០[292] ។ ក្រោយមក គាត់បានចុះចូលជាមួយរដ្ឋាភិបាលកម្ពុជា ហើយបានក្លាយទៅផ្នែកមួយនៃកងយោធពលខេមរភូមិន្ទ ។ នៅឆ្នាំ២០០៦ គាត់ត្រូវបានផ្ទេរពីសំឡូតទៅបាត់ដំបង ដើម្បីធ្វើជាបញ្ជាការរងប្រចាំតំបន់ ៥ នៃកងយោធពលខេមរភូមិន្ទ[293] ។ សហព្រះរាជអាជ្ញា ជឿជាក់ថាគាត់ត្រូវបានតំឡើងស័ក្តិនាពេលថ្មីៗនេះ ឱ្យទៅជាមេបញ្ជាការយោធភូមិភាគទី ៥ នៃកងយោធពលខេមរភូមិន្ទ និងជា “ទីប្រឹក្សា” អគ្គមេបញ្ជាការ

នៃកងយោធពលខេមរភូមិន្ទផងដែរ ។ គេជឿថាគាត់មានឋានៈជាឧត្តមសេនីយ៍ផ្កាយ២ ។ **ស៊ូ ម៉េត** អាចមានឈ្មោះមួយទៀតថា **ស៊ូ សាម៉េត**[294] ។

## អំណាចតែងតាំង និង អំណាចជាក់ស្តែង

៦៩. **ស៊ូ ម៉េត** ធ្លាប់ធ្វើជាមេបញ្ជាការ (ដែលគេស្គាល់ថាជា លេខា) នៃកងពលធំលេខ ៥០២ នៃ ក.ប.ក[295] ដែលមានទីតាំងនៅព្រលានយន្តហោះពោធិ៍ចិនតុង នៅជាយក្រុងភ្នំពេញ[296] ។ គាត់ជាលេខាកងពលធំលេខ ៥០២ យ៉ាងហោចណាស់ចាប់តាំងពី ខែមករា ឆ្នាំ១៩៧៦[297] រហូតដល់យ៉ាងហោចណាស់ ខែមេសា ឆ្នាំ១៩៧៨។[298] ប៉ុន្តែតាមការពិត គេជឿថាគាត់ធ្វើជាលេខាចាប់ពី ខែមិថុនា ឆ្នាំ១៩៧៥ រហូតដល់ ខែមករា ឆ្នាំ១៩៧៩ ។

៧០. **ស៊ូ ម៉េត** គឺជាសមាជិកនៃគណៈជំនួយការរបស់គណៈមជ្ឈិមនៃ ប.ក.ក[299] ។ នេះគឺជាឋានានុក្រមមួយក្នុងចំណោម "ឋានានុក្រមជាន់ខ្ពស់" ទាំងបួននៃ ប.ក.ក ហើយមានតែគណៈអចិន្ត្រៃយ៍ និងគណៈមជ្ឈិមទេ ដែលមានឋានានុក្រមខ្ពស់ជាងគេនៅក្នុងឋានានុក្រមនៃ ប.ក.ក[300] ។ សមាជិកនៃគណៈជំនួយការ មាន "ការទទួលខុសត្រូវផ្នែកនយោបាយ" នៅក្នុង ប.ក.ក[301] ហើយមានសិទ្ធិក្នុងការទទួលបាននូវការហ្វឹកហាត់នៅមន្ទីរ៨៧០ ជាមួយសមាជិកគណៈមជ្ឈិម[302] ។ ការទទួលខុសត្រូវខាងនយោបាយរបស់ **ស៊ូ ម៉េត** រួមមាន៖ (១) ការអនុវត្តន៍នូវមាគ៌ារបស់បក្សនៅក្នុងទូទាំងប្រទេស ។ (២) ការណែនាំដល់គណៈកម្មាធិការភូមិភាគនិងតំបន់នានា ឱ្យអនុវត្តសកម្មភាពនានាឱ្យបានស្របតាមមាគ៌ារបស់បក្ស ។ (៣) ការគ្រប់គ្រង និងរៀបចំកម្មាភិបាល និងសមាជិកបក្សនៅក្នុងទូទាំងបក្សទាំងមូល និងតាមគ្រប់ស្ថាប័នស្នូលទាំងអស់ ដើម្បីក្តាប់ឱ្យបានជាប្រចាំ ឱ្យបានច្បាស់លាស់ និងយ៉ាងដឹតដល់អំពីប្រវត្តិរូប គោលជំហរនយោបាយ សតិអារម្មណ៍ និងចាត់តាំងរបស់បុគ្គល" ។ និង(៤) ធ្វើសកម្មភាពផ្សេងៗក្នុងនាមរបស់បក្សក្នុងការទំនាក់ទំនងជាមួយបណ្តាបក្សម៉ាក្សលេនីនដទៃៗទៀត[303] ។

៧១. កងពលធំលេខ ៥០២ ត្រូវបានបង្កើតឡើងភ្លាមៗក្រោយពីទីក្រុងភ្នំពេញត្រូវវាយបែកនៅខែមេសា ឆ្នាំ១៩៧៥ ដោយកងទ័ពចម្រុះមកពីអង្គភាពផ្សេងៗដែលមានមកពីមុនស្រាប់បូកបញ្ចូលគ្នា ។ កងពលធំនេះទទួលបញ្ជាផ្ទាល់ពីអគ្គសេនាធិការ ក.ប.ក[304] ដែលត្រូវបានបញ្ជាដោយ សុន សេន ហៅ បង៨៩ ។ សុន សេន គឺជាសមាជិកម្នាក់នៃគណៈអចិន្ត្រៃយ៍របស់គណៈមជ្ឈិមនៃ ប.ក.ក

00291951



ដែលជាអង្គការដ៏ខ្ពស់បំផុតនៅក្នុង ប.ក.ក និងនៅក្នុងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ។ **ស៊ូ ម៉េត** មានឥទ្ធិពលមួយចំនួនទៅលើអគ្គសេនាធិការ ហើយត្រូវបានគេនិយាយថា បានក្លាយទៅជា "មនុស្សទី២" យ៉ាងជាក់ស្តែង របស់ សុន សេន (SON Sen's *de facto* "Number 2")[305] ។

៧២. កងពលធំលេខ ៥០២ គឺជាកងពលមួយនៃកងពលទាំង១០របស់ ក.ប.ក ដែលរាយការណ៍ផ្ទាល់ទៅឱ្យអគ្គសេនាធិការ[306] ។ កងពលធម្មតាមួយនៃ ក.ប.ក មានកងវរសេនាធំលេខ ៣ ដែលកងវរសេនាធំនីមួយៗមានចំនួនបីកងវរសេនាតូច[307] ។ ទោះជាយ៉ាងណាក៏ដោយ ប្រហែលជាមកពីកងពលធំលេខ ៥០២ មានតួនាទីជាកងទ័ពអាកាសរបស់កម្ពុជាប្រជាធិបតេយ្យផងដែរ នោះកងពលធំលេខ ៥០២ មានយ៉ាងហោចណាស់ចំនួន ១៥ កងវរសេនាតូច ដែលស្ថិតនៅក្រោមកងវរសេនាធំចំនួនពីរ ឬច្រើន[308] ។ ទំហំនៃកងពលធំលេខ ៥០២ ប្រែប្រួលទៅតាមពេលវេលា ប៉ុន្តែជាធម្មតា អាចមានចំនួនប្រហែល ៥.៥០០ នាក់ ។ នៅក្នុងពេលផ្សេងៗគ្នា កងពលនេះមានបុគ្គលិកចំនួន ៥.៥១១[309] ៥.៥៤៣[310] ៥.៥៩២[311] ៥.៦៨៤[312] និង ៦.៣៨៧[313] នាក់ ។

៧៣. **ស៊ូ ម៉េត** មានតួនាទីផ្សេងៗដូចជា៖

ក) **ស៊ូ ម៉េត** ក្នុងឋានៈជាមេបញ្ជាការកងពលធំលេខ ៥០២ ទទួលខុសត្រូវផ្នែកកងទ័ពអាកាស ក.ប.ក[314] ។

ខ) **ស៊ូ ម៉េត** ក្នុងឋានៈជាមេបញ្ជាការកងពលធំលេខ ៥០២ ទទួលខុសត្រូវខាងការតម្លើងរ៉ាដា[315] ។ ការតម្លើងរ៉ាដាទាំងនេះ មានតាំងស្ថិតនៅកន្លែងផ្សេងៗក្នុងប្រទេសកម្ពុជា រួមមាន៖ បូកគោ និងពោធិ៍ចិនតុង ហើយត្រួតពិនិត្យមើលការហោះហើរតាមផ្លូវអាកាសនៅពីលើប្រទេសកម្ពុជា ថៃ និង វៀតណាម[316] ។

គ) **ស៊ូ ម៉េត** ក្នុងឋានៈជាមេបញ្ជាការកងពលធំលេខ ៥០២ ទទួលខុសត្រូវលើការតម្លើងអាវុធប្រឆាំងយន្តហោះ ។ កងពលធំលេខ ៥០២ បានរក្សាសាលារៀនបច្ចេកទេសប្រឆាំងយន្តហោះ នៅវាលយន្តហោះពោធិ៍ចិនតុង ហើយនិង កងប្រតិបត្តិការប្រឆាំងយន្តហោះ ដែលមានទីតាំងនៅភាគខាងត្បូងនៃព្រលានយន្តហោះ ជិតវត្តចោមចៅ និងវត្តកោះអញ្ចាញ[317] ។

ឃ) **ស៊ូ មេ៉ត** ក្នុងឋានៈជាមេបញ្ជាការកងពលធំលេខ ៥០២ ទទួលខុសត្រូវផ្នែកសន្តិសុខនៅទីក្រុងភ្នំពេញ និងតំបន់ជុំវិញ រួមទាំងនៅក្បែរព្រលានយន្តហោះពោធិ៍ចិនតុងផង[318] ។ តំបន់ប្រតិបត្តិការនៃកងពលធំនៅភ្នំពេញ រួមមាន៖ ទួលទំពូង ដែលបុគ្គលិកកងពលអាចមើលឃើញមន្ទីរស-២១ ពីទីនោះ[319] ។

ង) **ស៊ូ មេ៉ត** ក្នុងឋានៈជាមេបញ្ជាការកងពល៥០២ និងជាប្រធានកងទ័ពអាកាស បានទទួលខុសត្រូវចំពោះការសាងសង់ព្រលានយន្តហោះយោធាមួយនៅក្បែរឃុំក្រាំងលាង ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ក្នុងភូមិភាគបស្ចិម[320] ។

ច) **ស៊ូ មេ៉ត** បានបញ្ជាអង្គភាព "កងកម្លាំងពិសេស" របស់កងពលធំលេខ ៥០២ ដែលទទួលខុសត្រូវខាងសន្តិសុខ និងខាងចាប់បុគ្គលិកកងពលធំលេខ ៥០២[321] ។

ឆ) ក្នុងឋានៈជាមេបញ្ជាការកងពលធំលេខ ៥០២ **ស៊ូ មេ៉ត** ទទួលខុសត្រូវលើប្រតិបត្តិការគុករបស់កងពលធំ មានឈ្មោះសម្ងាត់ថា មន្ទីរស-២២ ដែលមានទីតាំងនៅមុខសាលាទឹកល្អក់ នៅអូរបែកក្អម[322] ។

ជ) ក្នុងឋានៈជាមេបញ្ជាការកងពលធំលេខ ៥០២ **ស៊ូ មេ៉ត** ទទួលខុសត្រូវលើការបោសសម្អាតកងពលឱ្យអស់នូវសមាសភាពដែលគេមិនល្អ ដែលជាផ្នែកមួយនៃផែនការបោសសម្អាតដ៏ធំរបស់ ក.ប.ក ទាំងមូល[323] ។ គាត់បានរួមចំណែកនៅក្នុងផែនការឧក្រិដ្ឋកម្មរួម តាមរយៈការកំណត់អត្តសញ្ញាណ ការចាប់ និងការផ្ទេរ "ជនក្បត់" ដែលជាប់សង្ស័យ ពីកងពលធំលេខ ៥០២ ទៅមន្ទីរស-២១[324] ។ មានបុគ្គលិកជាង ៨០០ នាក់មកពីកងពលធំលេខ ៥០២ ត្រូវបានបញ្ជូនទៅកាន់មន្ទីរស-២១[325] ។

៧៤. **ស៊ូ មេ៉ត** ក្នុងឋានៈជាលេខាកងពលធំលេខ ៥០២ បានបញ្ជា ដឹកនាំ ហើយមានឥទ្ធិពលពេញលេញលើអង្គភាពនានានៅក្នុងកងពលធំលេខ ៥០២ ដែលបានជាប់ពាក់ព័ន្ធនៅក្នុងការប្រព្រឹត្តិបទឧក្រិដ្ឋទាំងឡាយដែលបានរៀបរាប់ខាងលើ ។

៧៥. បន្ថែមទៅលើអំណាចតែងតាំង និងអំណាចដាក់ស្តែងជាលេខាកងពលធំលេខ ៥០២ **ស៊ូ ម៉េត** ក៏បានដឹងឮជាក់លាក់ និងបានចូលរួមដោយផ្ទាល់នៅក្នុងបទឧក្រិដ្ឋទាំងឡាយដែលបានរៀបរាប់ខាងលើ ។ ការចូលរួម និងការដឹងឮត្រូវបានរៀបរាប់ខាងក្រោម ។

៧៦. ជាផ្នែកមួយនៃផែនការឧក្រិដ្ឋកម្មរួម ដើម្បីបោសសម្អាតនូវសមាសភាពមិនល្អក្នុង ក.ប.ក[326] **ស៊ូ ម៉េត** បានចាប់បុគ្គលិកកងពលធំលេខ ៥០២ ហើយបញ្ជូនទៅមន្ទីរស-២១[327] ដែលអ្នកទាំងនេះត្រូវបានគេធ្វើទារុណកម្ម និងក្រោយមកត្រូវបានសម្លាប់ ។ **ស៊ូ ម៉េត** បានចូលរួមដោយផ្ទាល់នៅក្នុងផ្នែកផ្សេងៗនៃសកម្មភាពបោសសម្អាតនេះ ។ ជាពិសេស គាត់បានទាក់ទងតាមសំបុត្រជាប្រចាំទៅ ឌុច ដែលជាប្រធានមន្ទីរស-២១[328]៖

ក) **ស៊ូ ម៉េត** បានសរសេរទៅ ឌុច នៅថ្ងៃទី១ ខែមេសា ឆ្នាំ១៩៧៧ ពន្យល់អំពីមូលហេតុនៃការបញ្ជូនមនុស្សចំនួន ៤ នាក់ពីកងពលធំលេខ ៥០២ ទៅមន្ទីរស-២១ ក្នុងរយៈពេលពីរថ្ងៃមុន ។ មនុស្សទាំងបួននាក់ត្រូវបានឆ្លើយដាក់នៅក្នុងចម្លើយសារភាពរបស់ សោម នៃមន្ទីរ៦២ ដែលជាការិយាល័យរដ្ឋបាលរបស់អគ្គសេនាធិការ ។ **ស៊ូ ម៉េត** បញ្ចប់សំបុត្រដោយចារថា គាត់កំពុងរង់ចាំយោបល់ពីអង្គការមុនពេលចាត់វិធានការប្រឆាំងនឹងមនុស្សផ្សេងៗទៀត ដែលបានរៀបរាប់នៅក្នុងចម្លើយសារភាពរបស់ សោម[329] ។

ខ) **ស៊ូ ម៉េត** បានសរសេរទៅ ឌុច នៅថ្ងៃទី៣០ ខែឧសភា ឆ្នាំ១៩៧៧ អំពីការផ្ទេរអ្នកទោសទៅមន្ទីរស-២១ ។ នៅក្នុងលិខិតរបស់គាត់ **ស៊ូ ម៉េត** បានចារថា៖ ១) គាត់បានបញ្ជូនក្រុមនេះពី "កង២៥" នៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ១៩៧៧, ២) គាត់បានបញ្ជូនមនុស្សចំនួន ២៥ នាក់បន្ថែមទៀតក្នុងរយៈពេលថ្មីៗកន្លងមកនេះ, ៣) គាត់បានបញ្ជូន "ជនក្បត់" ចំនួន ២ នាក់នៅថ្ងៃទី២៩ ខែឧសភា ឆ្នាំ១៩៧៧, ៤) នៅថ្ងៃទី៣០ ខែឧសភា គាត់នឹងបញ្ជូនមនុស្សចំនួន ៤ នាក់នៅម៉ោង ១៩:០០, ៥) នៅថ្ងៃ៣០ ខែឧសភា គាត់នឹងបញ្ជូនមនុស្សចំនួន ៧ នាក់ទៀតនៅម៉ោង ២២:០០ ។ គាត់បានបញ្ចប់លិខិតដោយស្នើទៅ ឌុច ថាឱ្យផ្ញើចម្លើយសារភាពរបស់ "ម៉ៅ" ដែលគាត់បានសុំពីលើកមុន ដើម្បីឱ្យគាត់អាចបន្តស្វែងរកខ្មាំងបន្តថែមទៀត[330] ។

00291954



គ) នៅក្នុងសំបុត្រឆ្លើយតបរបស់គាត់ផ្ញើទៅកាន់ ឌុច នៅថ្ងៃទី៣០ ខែឧសភា ឆ្នាំ១៩៧៧[331] **ស៊្វ ម៉េត** ហាក់បីដូចជាបានទទួលចម្លើយសារភាពរបស់ ម៉ៅ ពីព្រោះសំបុត្រទៅកាន់ ឌុច ចុះថ្ងៃទី១ ខែមិថុនា ឆ្នាំ១៩៧៧ បញ្ជាក់អំពីការផ្ទេរទៅមន្ទីរស-២១ នូវបុគ្គលម្នាក់ទៀតឈ្មោះ ស៊ុន ហេង ដែលត្រូវបានឆ្លើយដាក់នៅក្នុងចម្លើយសារភាពរបស់ ម៉ៅ, សោម និង ប៉ង់[332] ។

ឃ) **ស៊្វ ម៉េត** បានសរសេរសំបុត្រទីពីរទៅកាន់ ឌុច នៅថ្ងៃទី១ ខែមិថុនា ឆ្នាំ១៩៧៧ ដែលក្នុងនោះគាត់បានស្នើសុំបញ្ជូនមនុស្សបីនាក់ទៀតទៅមន្ទីរស-២១ ។ គាត់បានបញ្ជាក់ថា ក្នុងចំណោមនោះ មានអ្នកទោសម្នាក់ឈ្មោះ ឡាច ជា គឺជាបងប្អូនប្រុសរបស់ ឡាច ទ្រី ដែល **ស៊្វ ម៉េត** បានចាប់ និងបញ្ជូនទៅមន្ទីរស-២១ ។ នៅចុងសំបុត្រ **ស៊្វ ម៉េត** បានចារថា គាត់បានចាប់ពួកនេះរួចទៅហើយ ប៉ុន្តែ អ្នកទោសទាំងបីមិនបានសារភាពឱ្យបានច្បាស់លាស់[333] ។

ង) **ស៊្វ ម៉េត** បានសរសេរសំបុត្រទៅកាន់ ឌុច ម្តងទៀតនៅថ្ងៃទី២ ខែមិថុនា ឆ្នាំ១៩៧៧ ដើម្បីបញ្ជូនមនុស្សបីនាក់ទៀតទៅមន្ទីរស-២១ ។ ក្នុងចំណោមនោះ មនុស្សពីរនាក់ត្រូវបានឆ្លើយដាក់នៅក្នុងចម្លើយសារភាពរបស់អតីតសមាជិកកងពលធំលេខ ៣១០ ។ ជនទីបីឈ្មោះ គឹម វី ត្រូវបានចោទប្រកាន់ថាជាអតីតតន្ត្រីករមកពីភ្នំពេញ ។ សំបុត្រនោះបានចែងថា ទោះបីជា គឹម វី មិនត្រូវបានគេឆ្លើយដាក់នៅក្នុងចម្លើយសារភាពណាមួយក៏ដោយក៏ **ស៊្វ ម៉េត** បានពិនិត្យឯកសារអ្នកទោសនេះដោយផ្ទាល់ ហើយសន្និដ្ឋានថា គឹម វី គឺជា "ខ្មាំង"[334] ។

ច) **ស៊្វ ម៉េត** បានសរសេរទៅកាន់ ឌុច នៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩៧៧ ដើម្បីបញ្ជូនអ្នកទោសម្នាក់ឈ្មោះ សែម ដែលជាលេខាកងអនុសេនាធំមួយនៃកងវរសេនាតូចលេខ ៥១២ ទៅកាន់មន្ទីរស-២១[335] ។ តិចជាងពីរសប្តាហ៍ក្រោយមក **ស៊្វ ម៉េត** បានសរសេរត្រឡប់ទៅ ឌុច ដើម្បីស្នើសុំចម្លើយសារភាពរបស់ សែម ។ វាទំនងជាថា ផល ជាជំនួយការ **ស៊្វ ម៉េត** ត្រូវបានគេឆ្លើយដាក់នៅក្នុងចម្លើយសារភាពមួយពីមុន ហើយ **ស៊្វ ម៉េត** ចង់ដឹងថាតើ សែម បានឆ្លើយដាក់ ផល ឬទេ[336] ។

ឆ) **ស៊្វ ម៉េត** បានសរសេរទៅកាន់ ឌុច នៅថ្ងៃទី៣ ខែតុលា ឆ្នាំ១៩៧៧ ដើម្បីស្នើសុំបញ្ជូនមនុស្សពីរនាក់ទៀតទៅមន្ទីរស-២១ ។ **ស៊្វ ម៉េត** បានសរសេរថា មនុស្សទាំងពីរនេះធ្លាប់បានឆ្លងកាត់ការហ្វឹកហាត់នៅបរទេស[337] ។

00291955



ជ) នៅថ្ងៃទី៤ ខែតុលា ឆ្នាំ១៩៧៧ **ស៊ូ ម៉េត** បានសរសេរទៅកាន់ ឌុច ដើម្បីបញ្ជូនមនុស្សបីនាក់ទៀតមកកាន់មន្ទីរស-២១ ។ មនុស្សទាំងបីនាក់នោះត្រូវបានសរសេរថាធ្លាប់ចេញទៅបរទេស ។ ជនពីរនាក់ត្រូវ បានសម្គាល់ថាមកពីកងពលធំខ្មែរ ៣១០[338] ។

ឈ) លើសពីនេះ យ៉ាងហោចណាស់មានចម្លើយសារភាពនៅមន្ទីរស-២១ ចំនួនបួនឯកសារ បានបង្ហាញថាច្បាប់ចម្លងនៃចម្លើយសារភាពជាច្រើនច្បាប់ត្រូវបានផ្ញើទៅ **ស៊ូ ម៉េត**[339] ។

ញ) ជាសរុប មានបុគ្គលិកចំនួន ៨០០ នាក់មកពីកងពលធំលេខ ៥០២ ត្រូវបានបញ្ជូនទៅសម្លាប់នៅមន្ទីរស-២១[340] ។ **ស៊ូ ម៉េត** បានទទួលស្គាល់ថាគាត់បានដឹងឮថា បុគ្គលិកមកពីមន្ទីរស-២១ បានទៅកងពលធំលេខ ៥០២ ដើម្បី "យកជនសង្ស័យ" ប៉ុន្តែបានបដិសេធការជាប់ពាក់ព័ន្ធរបស់គាត់នៅក្នុងការចាប់ខ្លួន[341] ។

៧៧) នៅពេលដែលបុគ្គលិកកងពលធំលេខ ៥០២ មួយចំនួនដែលត្រូវបានចាប់ ហើយត្រូវបញ្ជូនទៅមន្ទីរ ស-២១ដើម្បីសួរចម្លើយ បុគ្គលិកផ្សេងទៀតត្រូវបានចាប់និងសួរចម្លើយនៅកងពលធំលេខ ៥០២ ផ្ទាល់ ។ **ស៊ូ ម៉េត** បានដឹងឮថា ការសួរចម្លើយនេះបានកើតឡើង ពីព្រោះគាត់បានចុះហត្ថលេខាលើរបាយការណ៍ជាច្រើនដែលពិភាក្សាអំពីការសួរចម្លើយ៖

ក) **ស៊ូ ម៉េត** បានចុះហត្ថលេខាលើរបាយការណ៍មួយស្តីអំពី "ចម្លើយសារភាពរបស់មនុស្សម្នាក់ ហំ ហាង" ដែលបានបញ្ជាក់ថា ហំ ហាង បាន "សារភាព" ថាបានគ្រោង "កម្មេចបដិវត្តន៍" ។ របាយការណ៍នេះបានបញ្ចប់ដោយសេចក្តីសន្និដ្ឋានរបស់កងវរសេនាធំលេខ ៥១ នៃកងពលធំលេខ ៥០២ ថា ហំ ហាង "គឺជាខ្មាំង"[342] ។

ខ) **ស៊ូ ម៉េត** បានចុះហត្ថលេខាលើរបាយការណ៍មួយស្តីអំពីចម្លើយសារភាព "របស់ ហែម ភី អំពីការចាប់ខ្លួនរបស់គាត់" ដែលបានបញ្ជាក់ថានៅក្នុង "ចម្លើយសារភាពក្រោយពីបានចាប់ខ្លួន" ហែម ភី បានទទួលស្គាល់ថាបានគ្រោងវាយប្រហារលើមូលដ្ឋានកងទ័ពនៅភ្នំពេញ ។ របាយការណ៍នេះបានបញ្ចប់ដោយមានការសន្និដ្ឋានរបស់កងវរសេនាធំលេខ ៥១ នៃកងពលធំលេខ ៥០២ ថា ហែម ភី និង "គ្នាវាសុទ្ធតែជាខ្មាំង"[343] ។

00291956



គ) សាន ដែលជាអនុលេខាកងពលធំលេខ ៥០២[344] បានចុះហត្ថលេខាលើរបាយការណ៍មួយស្តីអំពី "ការឆ្លើយតបរបស់ ឌី ព្រឹង" ដែលត្រូវបាន "សួរចម្លើយ" ក្រោយពីត្រូវបានចាប់ពីបទគ្រោង "ធ្វើបាតុកម្ម... ប្រឆាំងបដិវត្តន៍" ។ ជាលទ្ធផលនៃការសួរចម្លើយរបស់គាត់ ព្រឹង បានឆ្លើយដាក់មនុស្សចំនួន ៣៣ នាក់ថាជាប់ពាក់ព័ន្ធនៅក្នុងផែនការរបស់គាត់[345] ។

ឃ) ស៊ូ ម៉េត បានចុះហត្ថលេខា លើរបាយការណ៍មួយស្តីអំពីការចាប់ខ្លួនមនុស្សពីរនាក់ជិតព្រលានយន្តហោះពោធិ៍ចិនតុង ។ ជនទាំងពីរនាក់នោះ ត្រូវបានចាប់នៅពេលកំពុងលួចអាហារ ហើយបានសារភាពនៅក្នុង "ការឆ្លើយតប" របស់គាត់ថាពួកទាំងនោះជាផ្នែកមួយនៃចលនាប្រឆាំងនឹងបដិវត្តន៍[346] ។

ង) ស៊ូ ម៉េត បានស្នើនៅក្នុងសំបុត្រមួយទៅកាន់ ឌុច សុំបញ្ជូនបុគ្គលពីរនាក់ទៅកាន់មន្ទីរស-២១ ។ នៅក្នុងសំបុត្រនោះ គាត់បានទទួលស្គាល់ថាបានចាប់បុគ្គលទាំងពីរនាក់នៅពេលមុននេះ ប៉ុន្តែពួកនោះមិនបានសារភាពឱ្យបានច្បាស់លាស់ទេ[347] ។ សំបុត្រនេះបញ្ជាក់ថា មូលហេតុមួយដែលអ្នកទោសម្នាក់ត្រូវផ្ទេរទៅមន្ទីរស-២១ គឺមកពីអ្នកសួរចម្លើយនៅកងពលធំលេខ ៥០២ មិនអាចសួរយកនូវចម្លើយសារភាពមួយ ដែលអាចទទួលយកបាន ។

៧៨. នៅខែមករា ឆ្នាំ១៩៧៦ ស៊ូ ម៉េត បានសរសេររបាយការណ៍មួយរៀបរាប់អំពីស្ថិតិនៃកងកម្លាំងរបស់កងវរសេនាតូចលេខ ២ ទ័ពអាកាស នៃកងពលធំលេខ ៥០២ ។ បញ្ជីបានបង្ហាញថាមានសមាជិកចំនួន ៩ នាក់ត្រូវបាន "ដកចេញ" ដែលនៅក្នុងនោះមនុស្សចំនួន ៤ នាក់ត្រូវបានកំណត់អត្តសញ្ញាណថាជា "សមាភាពមិនល្អ"[348] ។

៧៩. កងពលធំលេខ ៥០២ បានគ្រប់គ្រងគុកមួយ មានឈ្មោះសម្ងាត់ថាមន្ទីរស-២២ ដែលមានទីតាំងនៅមុខសាលារៀនទឹកល្អក់ នៅអូរបែកក្អម[349] ។ ស៊ូ ម៉េត បានដឹងអំពីលក្ខខណ្ឌរស់នៅក្នុងគុក ពីព្រោះគាត់បានទៅទស្សនាគុកនោះយ៉ាងហោចណាស់លើសពីមួយដង[350] ។ ស៊ូ ម៉េត បានដឹងថាបុគ្គលិកកងពលធំលេខ ៥០២ ត្រូវបានចាប់ខ្លួន ពីព្រោះគាត់បានសរសេររបាយការណ៍ជាច្រើនដែលនៅក្នុងនោះមានរៀបរាប់អំពីការចាប់ខ្លួន[351] ។ ស៊ូ ម៉េត ក៏បានដឹងដែរថាមនុស្សក្រោមបង្គាប់របស់ខ្លួនកំពុងចាប់មនុស្សពីកងផ្សេងៗទៀត ដែលបានចូលតំបន់កាន់កាប់របស់កងពលធំលេខ ៥០២ នៅក្នុង និង នៅជុំវិញទីក្រុងភ្នំពេញ[352] ។

៨០. លក្ខខណ្ឌរស់នៅការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង[353] មានលក្ខណៈផ្ទុយនឹងច្បាប់ ។ អ្នកទោសត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការឃុំឃាំងដោយមិនស្របច្បាប់ បង្ខំឱ្យធ្វើការជាទម្ងន់ ដាក់ឱ្យស្ថិតនៅក្នុងលក្ខខណ្ឌអមនុស្សធម៌ ព្រមទាំង ចាប់សម្លាប់ដោយគ្មានការកាត់ក្ដី ។ **ស៊ូ ម៉េត** បានដឹងអំពីលក្ខខណ្ឌទាំងនេះ ពីព្រោះគាត់បានទៅទស្សនាការដ្ឋានព្រលានយន្តហោះដោយទៀងពេលកំណត់ ដើម្បីត្រួតពិនិត្យសកម្មភាពដំណើរការសាងសង់[354] ។ គាត់ក៏បានដឹងអំពីលក្ខខណ្ឌរស់នៅក្នុងការដ្ឋានផងដែរ ពីព្រោះ ល្វើយ ជាមេទ័ពមកពីកងពលធំលេខ ៥០២ ទទួលខុសត្រូវលើការដ្ឋានសាងសង់ព្រលានយន្តហោះ បានរាយការណ៍ផ្ទាល់ទៅកាន់ **ស៊ូ ម៉េត**[355] ។

## មាស មុត
## ព័ត៌មានផ្ទាល់ខ្លួន

៨១. **មាស មុត** មានឈ្មោះកំណើត ខែ មុត បានកើតនៅក្នុងខេត្តតាកែវ[356] ឬ ខេត្តកំពត[357] ។ គាត់ជាកូនប្រសារច្បងរបស់ ឈិត ជឿន ហៅ តាម៉ុក[358] អតីតលេខាភូមិភាគនិរតីពីខែមេសា ឆ្នាំ១៩៧៥ ដល់ខែមករា ឆ្នាំ១៩៧៩ ។ **មាស មុត** គឺជាអនុលេខាតំបន់ ១៣ នៅក្នុងភូមិភាគនិរតី ពីឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៣[359] ។ នៅឆ្នាំ១៩៧៣ គាត់ត្រូវបានតែងតាំងជាលេខាកងពលធំលេខ ៣ នៃភូមិភាគនិរតី[360] ។ នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ គាត់ជាលេខាកងពលធំលេខ ១៦៤ នៃ ក.ប.ក ។ ក្រោយរបបកម្ពុជាប្រជាធិបតេយ្យ **មាស មុត** នៅតែជាផ្នែកមួយនៃ ក.ប.ក រហូតដល់ឆ្នាំ១៩៩៩ នៅពេលដែលគាត់បានចុះចូលខាងរដ្ឋាភិបាលកម្ពុជា ។ ក្នុងពេលនោះ គាត់បានក្លាយទៅ "ទីប្រឹក្សា" របស់ក្រសួងការពារជាតិ ។ សព្វថ្ងៃ **មាស មុត** រស់នៅក្នុង "ផ្ទះឈើដ៏ធំ" មួយនៅជាយក្រុងសំឡូត[361] ។ សហព្រះរាជអាជ្ញា ជឿជាក់ថាសព្វថ្ងៃគាត់នៅតែជាទីប្រឹក្សារបស់ក្រសួងការពារជាតិ និងមានឋានៈជាឧត្តមសេនីយ៍ផ្កាយ ២ ដដែល ។

## អំណាចតែងតាំង និង អំណាចដាក់ស្នែង

៨២. **មាស មុត** គឺជាលេខាកងពលធំលេខ ១៦៤ នៃ ក.ប.ក ដែលមានមូលដ្ឋាននៅកំពង់សោម រាម និងកំពត[362] ។ គាត់ជាលេខាកងពលធំលេខ ១៦៤ យ៉ាងហោចណាស់ក៏ចាប់ពីខែមករា ឆ្នាំ១៩៧៦[363]

រហូតដល់យ៉ាងហោចណាស់ខែមេសា ឆ្នាំ១៩៧៨[364] ។ ប៉ុន្តែតាមការពិត គេជឿថាគាត់ ជាលេខា ចាប់ពីក្រោយខែមេសាបន្តិច ក្នុងឆ្នាំ១៩៧៥ រហូតដល់ខែមករា ឆ្នាំ១៩៧៩[365] ។

៨៣. បន្ថែមទៅលើតួនាទីរបស់គាត់ជាលេខាកងពលធំលេខ ១៦៤ **មាស មុត** ជាសមាជិកនៃគណៈមជ្ឈិមនៃ ប.ក.ក[366] ឬជាសមាជិកនៃគណៈជំនួយការនៃគណៈមជ្ឈិមនៃប.ក.ក[367] ។ ក្នុងករណីណាមួយក៏ដោយ គាត់ជាសមាជិកម្នាក់នៃ "ឋានុក្រមជាន់ខ្ពស់ នៃ ប.ក.ក ហើយមានគណៈអចិន្ត្រៃយ៍តែមួយគត់ ដែលមានឋានៈខ្ពស់ជាងនៅក្នុងឋានានុក្រម ប.ក.ក[368] ។ សមាជិកនៃគណៈជំនួយការមាន "ការទទួលខុសត្រូវផ្នែកនយោបាយ" នៅក្នុង ប.ក.ក[369] ហើយមានសិទ្ធិក្នុងការទទួលបាននូវការហ្វឹកហាត់នៅមន្ទីរ៨៧០ ជាមួយសមាជិកគណៈមជ្ឈិម[370] ។ ការទទួលខុសត្រូវខាងនយោបាយរបស់ **ស៊ូ ម៉េត** រួមមាន៖ (១) ការអនុវត្តន៍នូវមាគ៌ារបស់បក្សនៅក្នុងទូទាំងប្រទេស ។ (២) ការណែនាំដល់គណៈកម្មាធិការភូមិភាគនិងតំបន់នានា ឱ្យអនុវត្តសកម្មភាពនានាឱ្យបានស្របតាមមាគ៌ារបស់បក្ស ។ (៣) ការគ្រប់គ្រង និងរៀបចំកម្មាភិបាល និងសមាជិកបក្សនៅក្នុងទូទាំងបក្សទាំងមូល និងតាមគ្រប់ស្ថាប័នស្នូលទាំងអស់ ដើម្បីក្ដាប់ឱ្យបានជាប្រចាំ ឱ្យបានច្បាស់លាស់ និងយ៉ាងដឹតដល់អំពីប្រវត្តិរូប គោលជំហរនយោបាយ សតិអារម្មណ៍និងចាត់តាំងរបស់បុគ្គល" ។ និង(៤) ធ្វើសកម្មភាពផ្សេងៗក្នុងនាមរបស់បក្សក្នុងការទំនាក់ទំនងជាមួយបណ្ដាបក្សម៉ាក្សលេនីនដទៃៗទៀត[371]។

៨៤. កងពលធំលេខ ១៦៤ គឺជាកងពលមួយនៃកងពលធំទាំង ១០ របស់ ក.ប.ក[372] ហើយបានរាយការណ៍ដោយផ្ទាល់ទៅកាន់អគ្គសេនាធិការ ក.ប.ក ដែលបានដឹកនាំដោយ សុន សេន ហៅ បង៨៩[373] ។ កងពលធំលេខ ១៦៤ ហាក់ដូចជាមានកងវរសេនាតូចចំនួន ១២ កងដែលនៅក្រោមកងវរសេនាធំចំនួន ៥ ឬ ច្រើនកង[374] ។ ទំហំនៃកងពលធំលេខ ១៦៤ ប្រែប្រួលទៅតាមពេលវេលា ហើយធំជាងកងពលធម្មតា ។ កងពលធំលេខ ១៦៤ មានចំនួនទ័ពពី ៨,៥០០ នាក់ទៅ ១០,០០០ នាក់នៅក្នុងពេលផ្សេងៗគ្នា[375] ។

៨៥. ទង់បដិវត្តន៍នៃ ប.ក.ក បានរំឭកចំពោះបុគ្គលិក ក.ប.ក ថាឱ្យចាត់វិធានការបោសសម្អាតជាមុន ដើម្បីការពារប្រទេសជាតិ ព្រមទាំងព្រំដែនគោក និងសមុទ្ទ ។ ជាពិសេស ទង់បដិវត្តន៍បានបញ្ជាឱ្យកងទ័ពប្រកាន់គោលជំហរដ៏រឹងមាំផ្នែកនយោបាយ មនោគមន៍វិជ្ជា និងអង្គការចាត់តាំង ទាំងបញ្ហានៅក្នុងបក្ស និងក្នុងជួរក.ប.ក[376] ។ **មាស មុត** ជាលេខាកងពលធំលេខ ១៦៤ និងជាមេបញ្ជាការ

កងទ័ពជើងទឹក បានដឹងឮអំពីគោលនយោបាយរបស់ ប.ក.ក និង ក.ប.ក ហើយមានកាតព្វកិច្ច ធ្វើការហ្វឹកហាត់ដល់បុគ្គលិករបស់គាត់ឱ្យបានសមស្រប ដើម្បីពង្រឹងគោលជំហរកងទ័ព ។

៨៦. **មាស មុត** មានកាតព្វកិច្ចជាច្រើនដូចជា ៖

ក) **មាស មុត** ក្នុងឋានៈជាលេខាកងពលធំលេខ ១៦៤ គឺជាមេបញ្ជាការនៃកងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យ[377] ។ គាត់បានទទួលខុសត្រូវលើការការពារឆ្នេរសមុទ្រកម្ពុជា រួមទាំងក្រុងកំពង់សោម, រាម និង កងកេង ហើយការពារកោះទាំងអស់ ដែលរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យបានអះអាងកាន់កាប់[378] ។

ខ) **មាស មុត** ក្នុងឋានៈជាលេខាកងពលធំលេខ ១៦៤ បានទទួលខុសត្រូវលើការយាមល្បាតឆ្នេរសមុទ្រ និងកោះនានារបស់ប្រទេសកម្ពុជា ហើយគាត់បានរាយការណ៍ជាប្រចាំអំពីប្រតិបត្តិការរបស់កងទ័ពជើងទឹកទៅកាន់ សុន សេន និងមេដឹកនាំជាន់ខ្ពស់ផ្សេងៗទៀតនៃ ប.ក.ក[379] ។ ជាពិសេស កងកម្លាំងរបស់ **មាស មុត** បានទទួលខុសត្រូវលើការចាប់ ឬកម្ទេចនាវាថៃ ឬវៀតណាម ដែលបានចូលក្នុងផ្ទៃទឹកកម្ពុជា[380] ។

គ) **មាស មុត** ក្នុងឋានៈជាលេខាកងពលធំលេខ ១៦៤ បានទទួលខុសត្រូវលើសន្តិសុខនៅក្នុងកងពលធំ និងក្នុងតំបន់ផ្សេងៗទៀតដែលនៅក្រោមការគ្រប់គ្រងរបស់គាត់ ។ ជាពិសេស គាត់មានតួនាទីក្នុងការបោសសម្អាតសមាភាពមិនល្អ និងជនក្បត់នានាចេញពីកងពលធំលេខ ១៦៤ ដែលជាផ្នែកមួយនៃផែនការបោសសម្អាតដ៏ធំរបស់ ក.ប.ក[381] ។ ក្នុងឋានៈជាលេខាកងពលធំលេខ ១៦៤ គាត់ក៏បានទទួលខុសត្រូវផងដែរលើមន្ទីរសន្តិសុខដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់កងពលធំលេខ ១៦៤ នៅវត្តឥន្ទញាណ[382] ។

ឃ) ចាប់ផ្តើមនៅឆ្នាំ១៩៧៥ **មាស មុត** បានគ្រប់គ្រងក្រុងកំពង់សោម[383] ។ នៅក្នុងសមត្ថកិច្ចនេះ គាត់មានអំណាចលើមុខងារផ្នែករដ្ឋបាលនៅក្នុងតំបន់ រួមទាំងការដឹកជញ្ជូន ការគ្រប់គ្រងស្បៀងអាហារ និងការបង្កបង្កើនផល[384] ។ មានតែមុខងារផ្នែកនៅកំពង់សោមប៉ុណ្ណោះ ដែលមិនស្ថិតនៅក្រោមការគ្រប់គ្រងរបស់កងពលធំលេខ ១៦៤ គឺកំពង់ផែ និងផ្លូវដែក[385] ។ របាយការណ៍អង្គប្រជុំយោធាបានបង្ហាញថា មានចំនួនជនស៊ីវិល និងសមាជិកកងពលរហូតដល់ទៅ ១៧,០០០នាក់

00291960



ស្ថិតនៅក្រោមការគ្រប់គ្រងរបស់គាត់ និងបានចូលរួមនៅក្នុងការបង្កបង្កើនផលនៅលើដីគោក និងកោះមួយចំនួនតាមឆ្នេរសមុទ្ទ ក្នុងរវាងឆ្នាំ១៩៧៥ និង ឆ្នាំ១៩៧៨[386] ។

ង) **មាស មុត** ក្នុងឋានៈជាលេខាកងពលធំលេខ ១៦៤ បានទទួលខុសត្រូវលើការគ្រប់គ្រងការដ្ឋានបង្ខំឱ្យធ្វើការជាទម្ងន់មួយ នៅកន្លែងវាយថ្មនៅស្ទឹងហាវ[387] ។

ច) **មាស មុត** ក្នុងឋានៈជាលេខាកងពលធំលេខ ១៦៤ បានចូលរួមអង្គប្រជុំដ៏ទៀងទាត់របស់អគ្គសេនាធិការ ដែលមានលេខា និងអនុលេខានៃកងពល "ស្រួច" នៃ ក.ប.ក និងកងវរសេនាធំឯករាជ្យ បានពិភាក្សាអំពីស្ថានភាពសត្រូវខាងក្នុង និងសត្រូវខាងក្រៅ[388] បញ្ហាផលិតផលកសិកម្ម និងភ័ស្តុភារ[389] ។

ឆ) **មាស មុត** ក្នុងឋានៈជាលេខាកងពលធំលេខ ១៦៤ បានជួប និងទទួលបញ្ជាដោយផ្ទាល់ពីមេដឹកនាំជាន់ខ្ពស់របស់កម្ពុជាប្រជាធិបតេយ្យ និង ប.ក.ក. ។ ខ្លួនគាត់ ឬ អ្នកក្រោមបង្គាប់ម្នាក់ដែលដើរតួជាតំណាងកងពលធំលេខ ១៦៤ បានជួបជាប្រចាំជាមួយ សុន សេន និងលេខាកងពលធំផ្សេងៗទៀត[390] ។ គាត់បានទាក់ទងតាមសំបុត្រដោយផ្ទាល់ជាមួយ សុន សេន[391] និងជាមួយមន្ទីរ៨៧០[392] ។ នៅថ្ងៃទី៣ ខែសីហា ឆ្នាំ១៩៧៦ គាត់បានជួបជាមួយសមមិត្តលេខា (ប៉ុល ពត) និងមេដឹកនាំជាន់ខ្ពស់ផ្សេងៗទៀត រួមមាន វន វេត និង សុន សេន ដើម្បីពិភាក្សាអំពីវិធានការការពារ និងបញ្ហាភ័ស្តុភារផ្សេងៗទៀត[393] ។

ជ) **មាស មុត** ក្នុងឋានៈជាលេខាកងពលធំលេខ ១៦៤ និងជាមេបញ្ជាការកងទ័ពជើងទឹកនៃ ក.ប.ក បានទទួលព័ត៌មានថ្មីៗជាប្រចាំពីអ្នកក្រោមបង្គាប់អំពីបញ្ហាសន្តិសុខនៅតាមឆ្នេរសមុទ្ទ និងនៅក្នុងកងពល[394] ។ ការឆ្លើយឆ្លងតាមសំបុត្រនេះ ជាញឹកញាប់ត្រូវបានចម្លងជូនទៅ **នួន ជា**, សុន សេន និងមន្ទីរ៨៧០[395] ។ គំនិត និង យោបល់របស់ **មាស មុត** អំពីសន្តិសុខ និងការហ្វឹកហាត់របស់កងពលធំលេខ ១៦៤ ត្រូវបានស្វែងរកតាមរយៈទូរលេខ[396] ។

## ការចូលរួម និង ការដឹងឮ

៨៧. បន្ថែមទៅលើអំណាចតែងតាំង និង អំណាចដាក់ស្ដែង ក្នុងឋានៈជាលេខាកងពលធំលេខ ១៦៤ **មាស មុត** មានការដឹងឮ និងបានចូលរួមដោយផ្ទាល់នៅក្នុងបទឧក្រិដ្ឋដែលបានរៀបរាប់ខាងលើ ។ ការចូលរួម និងការដឹងឮរបស់គាត់ត្រូវបានរៀបរាប់នៅខាងក្រោម ។

៨៨. **មាស មុត** បានចូលរួមនៅក្នុងអង្គប្រជុំអគ្គសេនាធិការជាញឹកញាប់ ដែលចូលរួមដោយលេខា និងអនុលេខាកងពល"ស្រួច" នៃ ក.ប.ក និងកងវរសេនាធំឯករាជ្យ ដែលនៅក្នុងអង្គប្រជុំនេះ ផែនការបោសសម្អាតនៅតាមកងពលនៃ ក.ប.ក ត្រូវបានពិភាក្សា[397] ។ នៅក្នុងអង្គប្រជុំមួយ នៅថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧៦ សុន សេន បានសង្កត់ធ្ងន់អំពីភាពចាំបាច់ដើម្បីធានាថា កងទ័ពត្រូវមានមានភាព "ស្អាតស្អំ" ហើយ "ខ្សែរយៈក្បត់" ត្រូវបានកម្ចាត់យ៉ាងទាន់ពេល[398] ។ លេខា និងអនុលេខា ក.ប.ក ចំនួន ១៣ នាក់ បានបញ្ជាក់អំពីការគាំទ្រផែនការនេះ រួមទាំង **មាស មុត** ដែលបានធ្វើការកត់សម្គាល់ថា ផែនការបោសសម្អាតនៅក្នុងកងទ័ពគឺជា "ជោគជ័យដ៏ធំមួយរបស់បក្ស" ហើយមាន "សារៈសំខាន់ណាស់ដែលត្រូវបានដាច់ខាតក្នុងការបោសសម្អាត"[399] ។

៨៩. **មាស មុត** បានដឹង និងបានចូលរួមនៅក្នុងការបោសសម្អាតនៅក្នុងកងពលធំលេខ ១៦៤៖

ក) នៅថ្ងៃទី១១ ខែមិថុនា ឆ្នាំ១៩៧៦ **មាស មុត** បានរាយការណ៍ទៅកាន់ សុន សេន ថាគាត់ចាប់បានសំបុត្រមួយផ្ញើចេញពីសមាជិកមិនស្គាល់មុខម្នាក់នៃកងពលធំលេខ ១៦៤ ដែលបានប្រឆាំងនឹងអង្គការ ហើយចង់គេចពីកងពល ។ **មាស មុត** បានស្នើសុំយោបល់ពី សុន សេន អំពីវិធានការដោះស្រាយបញ្ហា ហើយបានបញ្ជាក់ថា គាត់កំពុងព្យាយាមតាមរកប្រភពដើមនៃសំបុត្រ ដោយផ្អែកលើអក្សរដៃរបស់អ្នកសរសេរ[400] ។

ខ) នៅក្នុងទូរលេខមួយទៅកាន់ សុន សេន ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ១៩៧៦ **មាស មុត** បានរាយការណ៍ថា "អ្នកទោសទាំងអស់ដែលមានបញ្ហា" ត្រូវបានដោះលែងដោយយុទ្ធជន ចំនួន ២ នាក់នៅកងពលធំលេខ ១៦៤[401] ។ នៅក្នុងអង្គប្រជុំ ក.ប.ក នៅថ្ងៃទី៣១ ខែសីហា ឆ្នាំ១៩៧៦ **មាស មុត** ឬ តំណាងរបស់គាត់បានបញ្ជាក់ថា សមាជិកនៃកងពលធំលេខ ១៦៤ ដែលត្រូវបានឃុំឃាំង ត្រូវបានដោះលែងដោយ "យុទ្ធជនក្បត់" ចំនួនពីររូប[402] ។

គ) នៅក្នុងសេចក្តីណែនាំមួយផ្ញើពី សុន សេន ទៅកងពលធំលេខ ១៦៤ នៅថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ១៩៧៦ សុន សេន បានផ្តល់សេចក្តីណែនាំទៅកាន់ **មាស មុត** ឱ្យរក្សាការចាប់ថ្មីៗនេះជាការសម្ងាត់[403] ។

ឃ) **មាស មុត** បានបញ្ជាក់នៅក្នុងអង្គប្រជុំរវាងលេខា និងអនុលេខាកងពល និងកងវរសេនាធំឯករាជ្យនៅថ្ងៃទី១ ខែមីនា ឆ្នាំ១៩៧៧ ថា កងអនុសេនាតូចមួយនៃកងពលធំរបស់គាត់ត្រូវបាន "បោសសម្អាត" ដោយបានថ្លែងថា ជនក្បត់នៅតែមាន ហើយបានបញ្ជាក់ថា ការបោសសម្អាតនៅមិនទាន់គ្រប់គ្រាន់ដើម្បីកម្ចាត់ខ្មាំងនៅឡើយ[404] ។

ង) អនុលេខាកងពលធំលេខ ១៦៤ បានផ្ញើទូរលេខមួយច្បាប់ទៅ **មាស មុត** ដោយបានសរសេរថា "យើងបានចាត់វិធានការប្រឆាំងនឹងខ្មាំងដែល បង បានសម្រេច ហើយខ្មាំងនោះបានរត់ចូលព្រៃ ។ ឥឡូវនេះ មនុស្ស ៥ នាក់ត្រូវបានចាប់ខ្លួន"[405] ។

ច) នៅក្នុងទូរលេខមួយច្បាប់ផ្ញើទៅកាន់មន្ទីរ៨៧០ នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៧ **មាស មុត** បានសរសេរថា បុគ្គលិកនៅក្នុងកងទ័ពជើងទឹកមានភារកិច្ច "បោសសម្អាតដោយមិនស្ទាក់ស្ទើរ" នូវសត្រូវកងទ័ពទាំងអស់រួមទាំងខ្មាំងខាងក្នុងដែរ ។ ក្នុងឋានៈជាមេបញ្ជាការកងទ័ពជើងទឹក **មាស មុត** ប្តេជ្ញា "រួបរួមទាំងស្រុងនៅក្នុងបក្ស"[406] ។

៩០. ជាផ្នែកមួយនៃការបោសសម្អាតកងពលធំលេខ ១៦៤ **មាស មុត** បានចាប់បុគ្គលិកកងពលធំលេខ ១៦៤ ហើយបញ្ជូនទៅមន្ទីរស-២១ ដើម្បីធ្វើការឃុំខ្លួន សួរចម្លើយ និងសម្លាប់ ។ មានបុគ្គលិកជិត ៤០០ នាក់មកពីកងពលធំលេខ ១៦៤ ត្រូវបានចាប់បញ្ជូនទៅមន្ទីរស-២១ ដោយ **មាស មុត**[407] ។ ឌុច ប្រធានមន្ទីរស-២១ បានផ្តល់បំភ្លឺថា ការសម្រេចចិត្តបញ្ជូនមនុស្សទៅមន្ទីរស-២១ ត្រូវបានធ្វើឡើងជារួមដោយ សុន សេន និងប្រធានកងរបស់អ្នកដែលត្រូវចាប់ខ្លួន[408] ។ ឯកសារផ្សេងៗបញ្ជាក់ថា **មាស មុត** បានដឹង និងបានចូលរួមនៅក្នុងការបញ្ជូនអ្នកទោសទៅមន្ទីរស-២១៖

ក) ទំព័រដំបូងនៃចម្លើយសារភាពនៅមន្ទីរស-២១ របស់ ហង់ ឡឿន ហៅ ខឹម[409] អនុលេខាកងពលធំលេខ ១៦៤ មានកំណត់ត្រាមួយដែលនិយាយថា៖ "ខ្ញុំនឹងហៅសមមិត្ត មុត មកពិនិត្យជាមួយ"[410] ។

ខ) ចម្លើយសារភាពនៅមន្ទីរស-២១របស់ ឃុន ខឹម មេបញ្ជាការកងវរសេនាតូចលេខ ១៤១ នៃកងពលធំលេខ ១៦៤ មានចំណារដៃនៅទំព័រមុខនៃឯកសារដែលចុះហត្ថលេខាដោយ សុន សេន នៅថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៧៧ ។ ចំណារនោះសរសេរថា៖ "ទាក់ទង **មាស មុត** ដើម្បីឱ្យចាត់វិធានការបន្ថែម"[411] ។

គ) ចម្លើយសារភាពនៅមន្ទីរស-២១ របស់ ប៉ែន ហំ លេខាកងវរសេនាតូចលេខ ១៧០ នៃកងពលធំលេខ ១៦៤ ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ១៩៧៧ មានចំណារនៅលើទំព័រមុខដែលនិយាយថា៖ "ទាក់ទងសមមិត្ត **មាស មុត**" និង "សម្រាប់ខាងសមមិត្ត **មាស មុត**"[412] ។

៩១. **មាស មុត** ច្បាស់ជាបានដឹងឮអំពីការបញ្ជូនអ្នកទោសពីកងពលធំលេខ ១៦៤ ទៅមន្ទីរស-២១ ពីព្រោះសមាជិកជាច្រើននៃកម្មាភិបាលជាន់ខ្ពស់របស់កងពលធំលេខ ១៦៤ ត្រូវបានចាប់ហើយបញ្ជូនទៅមន្ទីរស-២១ ។ វាទំនងជាថាកម្មាភិបាលកងពលធំលេខ ១៦៤ ដែលខ្ពស់ជាងគេដែលត្រូវបានចាប់គឺ ហង់ ខឿន ហៅ ខឹម ដែលជាអនុលេខាកងពលធំលេខ ១៦៤ និងជាអ្នកនៅក្រោមបង្គាប់ **មាស មុត** ផ្ទាល់[413] ។ កម្មាភិបាលជាន់ខ្ពស់ផ្សេងៗទៀត ដែលបានចាប់និងបញ្ជូនពីកងពលធំលេខ ១៦៤ មាន៖ ម៉ែន ង៉ែត ដែលជាសមាជិកកងពលធំលេខ ១៦៤[414], មុំ ឈឹម ហៅ យ៉ាន ដែលជាសមាជិកកងពលធំលេខ ១៦៤[415], សំ ដែលជាមេបញ្ជាកងវរសេនាធំលេខ ១៤០[416], សាន់ សៀប ហៅ សំ ដែលជាអនុលេខាកងវរសេនាធំលេខ ៦២[417], សែក រៀង ដែលជាមេបញ្ជាការកងវរសេនាតូចលេខ ១៤៣[418], ចឹក ស្រេង ដែលជាលេខាកងវរសេនាតូច[419], គង គៀន ហៅ អ៊ឹង វ៉េត ដែលជាលេខាកងវរសេនាតូចលេខ ៦៣១[420], គុង សៀន ហៅ សាន ដែលជាលេខាកងវរសេនាតូចលេខ ១៤០[421], ប៉ែន ហំ ដែលជាលេខាកងវរសេនាតូចលេខ ១៧០[422], ណុប នន ដែលជាលេខាកងវរសេនាតូច[423], គុណ ខឹម ដែលជាលេខាកងវរសេនាតូចលេខ ១៤១[424], គួង សៀន ហៅ សាន ដែល ជាលេខាកងវរសេនាតូចលេខ ១៤២[425], ឈុន លុន ហៅ អាត ដែលជាអនុលេខាកងវរសេនាតូចលេខ ១៦៥[426], អៀង សុង ហៅ ស្រ៊ាង ដែលជាសមាជិកកងវរសេនាតូចលេខ ១៤២[427] និង ងួន ឡាក ហៅ សាវ៉ាត់ ដែលជាសមាជិកវរសេនាតូចលេខ ១៧០[428] ។

៩២. **មាស មុត** បានថ្លែងថា"មេដឹកនាំធំៗ"នៃក.ប.ក បានផ្ញើសំបុត្រទៅកាន់គាត់ ហើយស្នើថា សមាជិកកងពលធំលេខ ១៦៤ ត្រូវបញ្ជូនចេញក្រៅភូមិភាគរបស់គាត់ ។ **មាស មុត** បានទទួលស្គាល់ថា

គាត់តែងតែធ្វើតាមសំណើ ប៉ុន្តែបានអះអាងថា គាត់មិនបានដឹងអំពីអ្វីដែលបានកើតឡើងទៅលើសមាជិកកងពល ក្រោយពីគាត់បានបញ្ជូនពួកគេចេញហើយទេ[429] ។ **មាស មុត** ថ្មីៗនេះបានទទួលស្គាល់ថា គាត់បានដឹងថាសមាជិកនានានៅក្នុងកងពលរបស់គាត់ត្រូវបានបញ្ជូនទៅមន្ទីរស-២១ ។ គាត់បាននិយាយថា ឌុច បានចេញដីកាចាប់ខ្លួនបុគ្គលិកកងពលធំលេខ ១៦៤ ហើយបានរៀបចំបញ្ជូនអ្នកដែលគេបានចាប់ទៅមន្ទីរស-២១[430] ។

៩៣. កងពលធំលេខ ១៦៤ បានចាប់វៀតណាម ថៃ និងជនបរទេសផ្សេងទៀត ជាច្រើននាក់នៅតាមព្រំដែនភាគនិរតីនៃប្រទេសកម្ពុជា ។ **មាស មុត** ក្នុងឋានៈជាមេបញ្ជាការកងទ័ពជើងទឹកនៃកម្ពុជាប្រជាធិបតេយ្យ និងកងពលធំលេខ ១៦៤ បានដឹងឮអំពីការចាប់ខ្លួននេះ ដូចដែលបានបង្ហាញនៅក្នុងរបាយការណ៍ជាច្រើន ដែលបានផ្ញើដោយ **មាស មុត** ទៅ ប៉ុល ពត, **នួន ជា**, **អៀង សារី** និង សុន សេន៖

ក) **មាស មុត** បានរាយការណ៍តាមទូរស័ព្ទសម្ងាត់នៅថ្ងៃទី១ ខែមេសា ឆ្នាំ១៩៧៨ ទៅ ប៉ុល ពត **នួន ជា** និង **អៀង សារី** អំពីការចាប់ខ្លួន និងការសម្លាប់ជនជាតិវៀតណាមចំនួន ១២០ នាក់ និងការពន្យារពេលដោះលែងជនជាតិថៃ ដែលបានចាប់នៅក្នុងអំឡុងពេលពីថ្ងៃទី២៧-៣០ ខែមីនា ឆ្នាំ១៩៧៨[431] ។

ខ) **មាស មុត** បានរាយការណ៍តាមទូរស័ព្ទសម្ងាត់ទៅ សុន សេន នៅថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៧៨ អំពីការចាប់ជនជាតិវៀតណាមចំនួន ៧៦ នាក់ និងជនថៃចំនួន ២១ នាក់ និងការរឹបអូសយកបានទូកវៀតណាមចំនួន ២ គ្រឿង ។ គាត់បានថ្លែងថា ជនជាតិវៀតណាមដែលបានចាប់ខ្លួន មានអាយុនិងភេទចម្រុះគ្នា ហើយពីរនាក់បានធ្លាក់ទៅក្នុងទឹក ទោះបីជាត្រូវបានចងហើយក៏ដោយ ។ **មាស មុត** បានរាយការណ៍អំពីការបាញ់ប្រហារទៅលើកាណូតវៀតណាមមួយ នៅចម្ងាយមួយគីឡូម៉ែត្រភាគខាងត្បូងកោះខ្យង ។ នៅក្នុងរបាយការណ៍នេះ **មាស មុត** បាននិយាយអំពីស្ថានភាពផ្សេងៗនៅលើកោះមួយចំនួនទៀត[432] ។

គ) **មាស មុត** បានរាយការណ៍តាមទូរស័ព្ទសម្ងាត់ទៅ សុន សេន នៅថ្ងៃទី១១ ខែសីហា ឆ្នាំ១៩៧៧ ទាក់ទងនឹងការចាប់ខ្លួនអ្នកនេសាទថៃចំនួន ៤ នាក់នៅលើផ្ទៃទឹកកម្ពុជា ។ អ្នកទាំង ៥ នាក់ដែលត្រូវបានចាប់ខ្លួន ត្រូវបានបញ្ជូនទៅកំពង់សោមដើម្បីសួរចម្លើយ ។ សុន សេន បានទទួលរបាយ

ការណ៍ ហើយចម្លងជូនទៅ "អង្គការ" ដើម្បីជាព័ត៌មាន ដោយមានចំណារថាចង់ស្រាវជ្រាវរក "ខ្មែរយៈក្បត់" ផ្ទៃក្នុងបន្ថែមទៀត ។ សុន សេន ក៏បានពិនិត្យទៅលើច្រកចូលផ្សេងៗ ដែលអ្នកនេសាទថៃអាចឆ្លងចូល និងស្ថានភាពនៃជនក្បត់ផ្សេងទៀតនៅតាមច្រកព្រំដែន[433] ។

ឃ) **មាស មុត** បានផ្ដល់របាយការណ៍មួយនៅក្នុងអង្គប្រជុំរវាងលេខា និងភ័ស្តុភារនៃកងពលធំ និងកងវរសេនាធំឯករាជ្យនៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ១៩៧៦ ដោយបានរាយការណ៍ថា ទូកនេសាទថៃរាប់រយគ្រឿងបានទន្ទ្រានចូលក្នុងផ្ទៃទឹកកម្ពុជា ហើយទូកនេសាទមួយត្រូវបានចាប់នៅថ្ងៃទី១១ ខែកញ្ញា ។ របាយការណ៍នោះបានថ្លែងថា កងទ័ពជើងទឹកកំពុងត្រៀមប្រយុទ្ធនឹងពួកវៀតណាម ប្រសិនបើវៀតណាមវិលចូលកាន់តែជិត[434] ។

៩៤. **មាស មុត** អាចនឹងមានតួនាទីមួយនៅក្នុងការបោសសម្អាតអាចារ្យ កង និងខ្មែរយៈរបស់គាត់ ។ នៅថ្ងៃទី១៩ ខែតុលា ឆ្នាំ១៩៧៦ **មាស មុត** បានផ្ញើសំបុត្រមួយដែលសរសេរដោយដៃទៅ សុន សេន ថា ភរិយារបស់អាចារ្យ កង បានស្នើសុំការព្យាបាលជំងឺនៅឯកងពលធំលេខ ១៦៤ ។ អាចារ្យ កង ត្រូវបានសម្លាប់ និងបោសសម្អាតរួចរាល់អស់ហើយ ។ សុន សេន បានទទួលរបាយការណ៍នេះ ហើយបានបញ្ជូនទៅឱ្យ **នួន ជា** ដោយមានចារថាសុំឱ្យ **នួន ជា** ជួយស្វែងរកជនដែលមានឈ្មោះ ឆេង និង បាន ដែលអ្នកទាំងពីរមានជាប់ពាក់ព័ន្ធនៅក្នុងករណីនេះ[435] ។

៩៥. **មាស មុត** បានទៅទស្សនាតំបន់ស្ទឹងហាវជាច្រើនលើក ដើម្បីត្រួតពិនិត្យការងារសាងសង់ផ្លូវថ្នល់មួយកន្លែង ។ ជួនកាល គាត់បានស្នាក់នៅមួយយប់ជាមួយអ្នកបច្ចេកទេសចិននានា ដែលបានជួយក្នុងការសាងសង់[436] ។ ជាលទ្ធផល គាត់ច្បាស់ជាបានដឹងអំពី ការដ្ឋានបង្ខំឱ្យធ្វើការជាទម្ងន់នៅស្ទឹងហាវ ។

## បទល្មើសដែលមានចោទប្រកាន់

៩៦. សហព្រះរាជអាជ្ញា មានមូលហេតុ និងជឿជាក់យ៉ាងច្បាស់ថា ជនសង្ស័យឈ្មោះ **ស៊ូ ម៉េត** និង **មាស មុត** បានប្រព្រឹត្តបទល្មើសទាំងឡាយដែលបានរៀបរាប់នៅក្នុងកថាខណ្ឌទី៤៣ ដល់៦៦ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី២ ដែលត្រូវបានកំណត់តាមផ្លូវច្បាប់ដូចខាងក្រោម ក្នុងកថាខណ្ឌទី៩៩ ។ យើងជឿជាក់ថា យ៉ាងហោចណាស់ចាប់ពី ខែមិថុនា ឆ្នាំ១៩៧៥ **ស៊ូ ម៉េត**

00291966



និង **មាស មុត** គឺជា មេដឹកនាំជាន់ខ្ពស់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និង/ឬ ជាជនដែលមានការទទួលខុសត្រូវខ្ពស់ បំផុតចំពោះឧក្រិដ្ឋកម្មដូចដែលបានរៀបរាប់ ។ **ស៊ូ ម៉េត** និង **មាស មុត** ជាលក្ខណៈបុគ្គល ឬ ជាលក្ខណៈរួម មានផែនការញុះញង់ បញ្ជា ប្រព្រឹត្ត ឬ ជួយនិងជំរុញឱ្យមានការប្រព្រឹត្តិបទឧក្រិដ្ឋ ទាំងនេះ ។ ជនទាំងនេះ មានចេតនាដោយផ្ទាល់ចង់ឱ្យ បទឧក្រិដ្ឋទាំងនេះត្រូវបានប្រព្រឹត្ត ឬ យ៉ាងហោចណាស់ បានដឹងយ៉ាងច្បាស់ថា បទឧក្រិដ្ឋទាំងនេះ ច្បាស់ជានឹងត្រូវបានប្រព្រឹត្តនៅក្នុង ការអនុវត្តន៍នូវ ផែនការ ការញុះញង់ ការបញ្ជា ឬ ជំនួយរបស់ពួកគេ ។

៩៧. នៅពេលដែល **ស៊ូ ម៉េត** និង **មាស មុត** បានប្រព្រឹត្តបទឧក្រិដ្ឋទាំងនេះ ជនទាំងនេះបានធ្វើជា លក្ខណៈបុគ្គល ឬ តាមរយៈការចូលរួមនៅក្នុងសហកម្មឧក្រិដ្ឋកម្មរួមជាមួយនឹងសហចារីផ្សេងៗ ទៀត ដែលបានកំណត់នៅក្នុងកថាខណ្ឌទី៣៣-៥១ នៃដីកាសន្និដ្ឋានរឿងឱ្យស៊ើបសួរនេះ ។ បទឧក្រិដ្ឋទាំងនេះគឺជាកម្មវត្ថុនៃសហកម្មឧក្រិដ្ឋកម្មរួម ឬ ម៉្យាងទៀតជាផលវិបាកធម្មតា និងដែល អាចទស្សន៍ទាយបាននៃសហកម្មឧក្រិដ្ឋកម្មរួម ។ សមាជិកផ្សេងៗទៀតនៃសហកម្មឧក្រិដ្ឋកម្មរួម បានប្រព្រឹត្តទៅតាមមូលដ្ឋាននៃគោលបំណងរួម ហើយដោយមានចេតនាដូចគ្នា ។

៩៨. **ស៊ូ ម៉េត** និង **មាស មុត** ក៏ត្រូវទទួលខុសត្រូវផងដែរចំពោះបទឧក្រិដ្ឋទាំងនេះ ក្នុងតួនាទីជា ថ្នាក់លើនៃអ្នកក្រោមបង្គាប់ដែលបានប្រព្រឹត្តបទឧក្រិដ្ឋ ។ **ស៊ូ ម៉េត** និង **មាស មុត** មានអំណាច និងការគ្រប់គ្រងយ៉ាងពេញលេញទៅលើអ្នកក្រោមបង្គាប់ ហើយបានដឹងឮ ឬមានហេតុផលនឹង ដឹងថា អ្នកក្រោមបង្គាប់របស់ខ្លួន ហៀបនឹង ឬ បានប្រព្រឹត្តទង្វើបែបនោះ ហើយខកខានពុំបានចាត់ វិធានការចាំបាច់ និងសមរម្យ ដើម្បីការពារទង្វើទាំងនោះមិនឱ្យកើតមាន ឬដើម្បីផ្តន្ទាទោសជល់ ចារីទាំងឡាយ ។

៩៩. ហេតុដូច្នេះ សហព្រះរាជអាជ្ញា មានមូលហេតុ និងជឿជាក់យ៉ាងច្បាស់ថា **ស៊ូ ម៉េត** និង **មាស មុត** បានចូលរួមនៅក្នុងបទឧក្រិដ្ឋទាំងឡាយដូចខាងក្រោម៖

១)ឧក្រិដ្ឋកម្មនៃការដាក់ក្នុងមន្ទីរឃុំឃាំង, ការធ្វើឱ្យទៅជាទាសករ, អំពើអមនុស្សធម៌, ការធ្វើ ទារុណកម្ម, ការធ្វើមនុស្សឃាត, ការសម្លាប់រង្គាល, ការធ្វើទុកបុកម្នេញដោយមូលហេតុ នយោបាយ ពូជសាសន៍ និងសាសនា, ព្រមទាំងអំពើអមនុស្សធម៌ផ្សេងៗទៀត ។ អពើទាំងនេះ

ត្រូវបានប្រព្រឹត្តឡើងជាផ្នែកមួយនៃការវាយប្រហារ ជាទូទៅ ឬ ជាប្រព័ន្ធ សំដៅប្រឆាំងទៅលើប្រជាជនស៊ីវិល ។ អំពើទាំងនេះ បង្កជា **ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ** ដែលអាចផ្តន្ទាទោសបានក្រោមមាត្រា ៥, ២៩ (ថ្មី) និង ៣៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ។

២) ឧក្រិដ្ឋកម្មនៃការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់, ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិលនូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌ និងទៀងទាត់, ការធ្វើបាបដោយអមនុស្សធម៌, ការបង្កដោយចេតនាឱ្យមានរបួសធ្ងន់ធ្ងរ ឬឱ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព, ការធ្វើទារុណកម្ម និង ការធ្វើមនុស្សឃាតដោយចេតនា ។ អំពើទាំងអស់នេះ បង្កជា **អំពើបំពានបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩** ដែលអាចផ្តន្ទាទោសបានក្រោមមាត្រា ៦, ២៩ (ថ្មី) និង ៣៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ។

៣) ឧក្រិដ្ឋកម្មនៃការធ្វើទារុណកម្ម និង ការធ្វើមនុស្សឃាត គឺជាការបំពានទៅលើ **ក្រមព្រហ្មទណ្ឌ ឆ្នាំ១៩៥៦** (មាត្រា ៥០០, ៥០១, ៥០៣, ៥០៤, ៥០៥, ៥០៦, ៥០៧ និងមាត្រា ៥០៨) ដែលអាចផ្តន្ទាទោសបានក្រោមមាត្រា ៣ (ថ្មី), ២៩ (ថ្មី) និង ៣៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ។

១០០. យើងជឿជាក់ថាលក្ខខណ្ឌចាំបាច់សម្រាប់ការចាប់ខ្លួន និងការឃុំខ្លួនបណ្តោះអាសន្នលើជនសង្ស័យឈ្មោះ **ស៊ូ ម៉េត** និង **មាស មុត** ដូចបានចែងនៅក្នុងវិធាន ៤២ និង ៦៣ នៃវិធានផ្ទៃក្នុង ត្រូវបានបំពេញ ដោយមានមូលហេតុទាំងឡាយដូចខាងក្រោម៖

១) ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនេះ បានផ្តល់មូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់ថា **ស៊ូ ម៉េត** និង **មាស មុត** ធ្លាប់បានប្រព្រឹត្តនូវបទឧក្រិដ្ឋនានា ដែលបានបញ្ជាក់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនេះ ។ ភស្តុតាងដែលប្រមូលបាននៅក្នុងដំណាក់កាលស៊ើបអង្កេតបឋមរបស់សហព្រះរាជអាជ្ញា រួមទាំងសាក្សី និងភស្តុតាងជាឯកសារផងនោះ គាំទ្រដល់លទ្ធភាពដែលថា **ស៊ូ ម៉េត** និង **មាស មុត** អាចនឹង ត្រូវកាត់ឱ្យជាប់ទោសអំពីបទឧក្រិដ្ឋដែលបានបញ្ជាក់ក្នុងនេះ ហើយ នឹងត្រូវបានផ្តន្ទាទោសទៅតាមច្បាប់ អ.វ.ត.ក ។

២) **ស៊ូ ម៉េត** និង **មាស មុត** មានសមត្ថភាព និងមធ្យោបាយសេដ្ឋកិច្ច ដើម្បីគេចខ្លួនចេញពីប្រទេស និង/ឬ គេចវេះពីយុត្តិធម៌ ។ ដូចដែលបានកត់សម្គាល់ខាងលើ នៅក្នុងកថាខណ្ឌទី៦៨ **ស៊ូ ម៉េត**

គឺជាសមាជិកជាន់ខ្ពស់១រូបនៃកងយោធពលខេមរភូមិន្ទ ហើយបច្ចុប្បន្នជាមេបញ្ជាការយោធភូមិភាគទី៥ នៃកងយោធពលខេមរភូមិន្ទ នៅតាមបណ្ដោយព្រំដែនថៃ ។ ដូចដែលបានកត់សម្គាល់ខាងលើ នៅក្នុងកថាខណ្ឌទី៨១ **មាស មុត** គឺជា "ទីប្រឹក្សា" ជាន់ខ្ពស់របស់ក្រសួងការពារជាតិ និងជាបុគ្គលដែលមានទ្រព្យសម្បត្តិស្តុកស្តម ។ ជនសង្ស័យទាំងនេះដឹងថា អ.វ.ក.ត ត្រូវបានបង្កើតឡើង ហើយខ្លួនអាចជាសក្ដានុពលគោលដៅនៃការស៊ើបសួរ[437] ។ ដោយសារបទឧក្រិដ្ឋនានា ដែលបានប្រព្រឹត្តមានលក្ខណៈធ្ងន់ធ្ងរ និងលទ្ធភាពដែល **ស៊ូ ម៉េត** និង **មាស មុត** អាចទទួលការដាក់ពន្ធនាគារយូរអង្វែងសម្រាប់បទឧក្រិដ្ឋទាំងនោះ ជនទាំងនេះអាចគេចខ្លួនពីយុត្តិធម៌ និងមិនមកបង្ហាញខ្លួននៅចំពោះមុខការកាត់ក្ដីទេ។

៣) ដោយសារមុខដំណែងដ៏ខ្ពស់របស់ **ស៊ូ ម៉េត** និង **មាស មុត** ដែលបានកាន់កាប់នៅក្នុងអតីតកាល, ដោយសារមុខដំណែង និងអំណាចដែលជនទាំងនេះបន្តកាន់កាប់ ព្រមទាំងដោយសារលក្ខណៈទូទៅ លក្ខណៈជាប្រព័ន្ធ និង ភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋទាំងឡាយ ដែលបានប្រព្រឹត្តដោយជនទាំងនេះ នោះវាទំនងជាមានលទ្ធភាពយ៉ាងជាក់លាក់ថា សាក្សី ជនរងគ្រោះ និងជនទីបី នឹងមានអារម្មណ៍ភ័យខ្លាចគេគំរាមកំហែង និងបំភិតបំភ័យ ហើយជាលទ្ធផល ពុំបានចូលរួមជួយក្នុងដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានេះទេ ប្រសិនបើជនទាំងនេះមិនត្រូវបានចាប់ខ្លួន និងឃុំឃាំងទេនោះ ។ ការណ៍នេះក៏បានគាំទ្រដោយការពិត ដែលថាមានតែសាក្សីនៃបទឧក្រិដ្ឋដែលបានប្រព្រឹត្តឡើងមួយចំនួនតូចប៉ុណ្ណោះ ដែលនៅរស់រានមានជីវិតនៅឡើយ ។ លើសពីនេះ ដោយសារចម្លើយដែលធ្វើឡើងដោយសាក្សីអាចចាត់ទុកថាជា"ភស្តុតាង"បានទៅតាមអត្ថន័យនៃវិធាន ៦៣.៣.ខ(២) នោះការដាក់សម្ពាធ ឬការបំភិតបំភ័យណាមួយដែលបានធ្វើទៅលើសាក្សី ឬ ជនរងគ្រោះ ត្រូវតែបានគេគិតថាជា ការបំផ្លាញភស្តុតាង[438] ។

៤) ដោយសារតែការស៊ើបអង្កេត និងការកាត់សេចក្ដីក្រោយនេះ អាចធ្វើឱ្យសាធារណៈជនមានការចាប់អារម្មណ៍ដ៏ធំធេង និងមានចំណង់យ៉ាងខ្លាំងក្នុងការចូលរួមនោះ ដើម្បីបម្រើផលប្រយោជន៍យុត្តិធម៌ **ស៊ូ ម៉េត** និង **មាស មុត** ចាំបាច់ត្រូវចាប់ខ្លួន និងធ្វើការឃុំឃាំង ដើម្បីការពារកុំឱ្យមានការប៉ះពាល់ដល់ដំណើរការនីតិវិធី និង ដើម្បីធានាសុវត្ថិភាពជនទាំងពីរ ព្រមទាំងដើម្បីរក្សាសណ្ដាប់ធ្នាប់សាធារណៈ ។

១០១. សហព្រះរាជអាជ្ញា សូមស្នើឱ្យសហចៅក្រមស៊ើបអង្កេត ចាត់វិធានការសម្រាប់ការការពារបុគ្គល រួមទាំងជនរងគ្រោះ សាក្សី និង ជនទីបី ដែលត្រូវបានរៀបរាប់ ដោយផ្ទាល់ ឬមួយក៏ ដោយសារតែភាពចាំបាច់ដោយមានការជាប់ពាក់ព័ន្ធ ដូចនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើប សួរនេះ នៅក្នុងសំណុំរឿងដែលភ្ជាប់ជាមួយ និង នៅក្នុងឯកសារណាមួយផ្សេងទៀតដែលបានផ្តល់ មកជាមួយគ្នានេះ ។ ហេតុផល និង វិសាលភាពនៃវិធានការដែលបានស្នើ គឺដូចបានរៀបរាប់ នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី១ កថាខណ្ឌទី ១១៩ ដល់ ១២១ ។ យើងស្នើ ឱ្យអនុវត្តឱ្យបានពេញលេញនូវវិធានការទាំងឡាយដែលបានស្នើសុំនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿង ឱ្យស៊ើបសួរលើកទី១ ដែលទាក់ទងទៅនិងការស៊ើបអង្កេតនៅក្នុងករណី **ស៊ូ ម៉េត និង មាស មុត** ។

## សំណើ

១០២. សហព្រះរាជអាជ្ញា ស្នើឱ្យមានការស៊ើបអង្កេត ការចាប់ខ្លួន និង ការឃុំខ្លួនជាបណ្តោះអាសន្ន ឈ្មោះ **ស៊ូ ម៉េត និង មាស មុត** ដោយសារការចូលរួមរបស់ពួកគាត់នេះ នៅក្នុងបទចោទទាំង ឡាយដែលបានចោទប្រកាន់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនេះ និង ស្នើបន្ថែមឱ្យមាន វិធានការការពារដូចរៀបរាប់ខាងលើ ស្របតាមវិធាន ២៩ នៃវិធានផ្ទៃក្នុង ។

ធ្វើនៅភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា
នៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨
**សហព្រះរាជអាជ្ញា**

| | |
|---|---|
| **លោកស្រី ជា លាង** | **លោក** Robert PETIT |
| សហព្រះរាជអាជ្ញា | សហព្រះរាជអាជ្ញា |

## ប្រភពនៃភស្តុតាង និង ច្បាប់

[1] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ, **D3** ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧, ERN 00147244-00147399 (ភាសាអង់គ្លេស)។

[2] កាំង ហ្កេកអ៊ាវ ហៅ ឌុច សេចក្តីថ្លែងការណ៍របស់ ក.ស.ច.ស, **D86/11** ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០០៨ តាម ERN 00159558, ERN 00159552-00159559 (ភាសាអង់គ្លេស); សារាចរ ណែនាំរបស់គណៈកម្មាធិការមជ្ឈិមចេញដោយបក្សកុម្មុយនិស្តកម្ពុជា, "សេចក្តីសម្រេចរបស់ គណៈមជ្ឈិមអំពីបញ្ហាផ្សេងៗ", **IS Annex C No. 6.3** ចុះថ្ងៃ ទី៣០ ខែមីនា ឆ្នាំ១៩៧៦, ERN 00000758-00000764 (ភាសាខ្មែរ)។ នេះយោងទៅលើ "សិទ្ធិកម្ទេចនៅក្នុងជួរ និងក្រៅជួរ"។ ពាក្យថា "កម្ទេច" ត្រូវបានប្រើប្រាស់ជាញឹកញយនៅក្នុងឯកសារជាច្រើនដោយចង់មានន័យថា មនុស្សណាម្នាក់ត្រូវបានសម្លាប់ ឬប្រហារជីវិត ដែលភាសា នេះមានពន្យល់បន្ថែមនៅក្នុង អត្ថបទស្រាវជ្រាវជាន់ខ្ពស់ ដោយលោក ចន ឆធីអារី និង លោក ឆាំង យុ ដែលមានចំណងជើងថា ការចងក្រងឧក្រិដ្ឋកម្មនៃកម្ពុជាប្រជាធិបតេយ្យ, **IS Annex C No. 1.3** ក្នុងឆ្នាំ២០០៥ ត្រង់ទំព័រ **២៤០-២៤២**, ERN 00105009-00105011 (ភាសាអង់គ្លេស), ក្នុងសៀវភៅរបស់ ប៉ែត វ៉ាន់ស្លាក់ និង ចាយ៉ា វ៉ាមជី, eds, ដែលមានចំណងជើង ថា នាំយកខ្មែរក្រហមទៅប្រឈមមុខនឹងយុត្តិធម៌។

[3] កាលបរិច្ឆេទ៣៦នៃដីកាបញ្ជូនរឿងឱ្យស៊ើបសួរ, **D3** ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ តាម ERN 00146082-00146083, ERN 00146018-00146224 (ភាសាអង់គ្លេស); កាលបរិច្ឆេទ ៧៤នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ, **D3** ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ តាម ERN 00146161-00146166, ERN 00146018-00146224 (ភាសាអង់គ្លេស)។ ឯកសារនេះរៀបរាប់ ពីការប្រើប្រាស់ម្តងហើយម្តងទៀតរបស់បក្សកុម្មុយនិស្តកម្ពុជានូវពាក្យ បោសសំអាត ទៅជាន័យថា "កម្ទេច" ចំពោះជនដែលចោទថា ជាខ្មាំងបង្កប់ផ្ទៃក្នុង។

[4] ឯកសារច្បាប់របស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ មានចំណងជើងថា រដ្ឋធម្មនុញ្ញកម្ពុជា ប្រជាធិបតេយ្យ, **IS Annex C No. 9.2** ចុះថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៦ DCCN 21447, ERN 00089841-00089852 (ភាសាខ្មែរ), ជំពូក១៦។

[5] សូមមើល ទស្សនាវដ្តី បកក ដែលមានចំណងជើងថា ទង់បដិវត្ត, **IS Annex C No. 11.9** នៅ ខែកក្កដា ឆ្នាំ១៩៧៦ ត្រង់ទំព័រ **៧-៩**, ERN 00062905-00062945 (ភាសាខ្មែរ) (ដែលរៀបរាប់ ពីភាពចាំបាច់ក្នុងការការពារប្រទេស "ផ្ទៃក្នុងប្រទេស" និង "នៅលើឆាកអន្តរជាតិ"; ទស្សនាវដ្តីបកក ដែលមានចំណងជើងថា យុវជនបដិវត្ត, **IS Annex C No. 11.7** នៅខែឧសភា ឆ្នាំ១៩៧៦ ត្រង់ទំព័រ **៤-៥**, ERN 00064003-00064040 (ភាសាខ្មែរ)-ET (ដែលនិយាយថា កងទ័ព"ត្រូវលើកកំពស់ ជានិច្ចនូវស្មារតីបដិវត្តខ្លាំងក្លារបស់ខ្លួន និងត្រូវត្រៀមខ្លួនជាស្រេចឱ្យរឹងមាំបំផុត និងល្អឥតខ្ចោះក្នុងការ ការពារព្រំដែនទឹក ដី សមុទ្រ កោះ និងនៅក្នុងប្រទេសដើម្បីធានាសន្តិសុខរបស់

ប្រជាជនយើងនៅក្នុង សហករណ៍") ។ ទស្សនាវដ្ដី បកក ដែលមានចំណងជើងថា *ទង់បដិវត្ត*, ខែមិថុនា ឆ្នាំ១៩៧៦, ត្រង់ទំព័រ ៨-៩, ERN 00062836-00062876 (ភាសាខ្មែរ)។

[6] ឯកសារច្បាប់របស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ មានចំណងជើងថា រដ្ឋធម្មនុញ្ញកម្ពុជា ប្រជាធិបតេយ្យ, ជំពូក ១៦, **IS Annex C No. 9.2** ចុះថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៦ DCCN 21447, ERN 00089841-00089852 (ភាសាខ្មែរ); សូមមើលផងដែរ ឯកសារច្បាប់របស់រដ្ឋាភិបាល កម្ពុជាប្រជាធិបតេយ្យ មានចំណងជើងថា លក្ខន្តិកៈបក្សកុម្មុនិត្តកម្ពុជា, **IS Annex C No. 9.1** ខែមករា ឆ្នាំ១៩៧៦, DCCN D00674, ERN 00053007-00053080, មាត្រា ២៧ (ដែលនិយាយ យោងដល់សាខាទាំងបីដូចគ្នាថា ស្រុច តំបន់ និង ឈ្លប)។

[7] ឯកសារច្បាប់របស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ដែលមានចំណងជើងថា លក្ខន្តិកៈបក្ស កុម្មុនិស្តកម្ពុជា, **IS Annex C No. 9.1** ខែមករា ឆ្នាំ១៩៧៦, DCCN D00674, ត្រង់ទំព័រ ២៥, ERN 00053007-00053080; កំណត់ហេតុប្រជុំគណៈអចិន្ត្រៃយ៍នៃបក្សកុម្មុយនិស្ត កម្ពុជា, **IS Annex C No. 13.2** ចុះថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧៥, DCCN D00677, ត្រង់ទំព័រ ២, ERN 00019108-00019126 (ភាសាខ្មែរ) (ក្នុងនោះ គណៈអចិន្ត្រៃយ៍បានកត់សម្គាល់នៅក្នុងកំណត់ហេតុប្រជុំរបស់ខ្លួនថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧៥ ថា "កិច្ចការការពារជាតិត្រូវរៀបចំ នៅថ្នាក់មជ្ឈិម") ។ ទស្សនាវដ្ដី បកក ដែលមានចំណងជើងថា ទង់បដិវត្ត, **IS Annex C No. 11.9** ខែកក្កដា ឆ្នាំ១៩៧៦, ទំព័រ ៦៥, ERN 00062905-00062945 (ភាសាខ្មែរ) ("មានតែបក្សដែលដឹកនាំកងទ័ព ដោយពុំមានអង្គការ ឬបុគ្គលណាម្នាក់ដឹកនាំកងទ័ពឡើយ"។)

[8] តួនាទីរបស់គណៈមជ្ឈិមបក្សកុម្មុយនិស្តកម្ពុជា មានបញ្ជាក់នៅក្នុងផ្នែកនៃដីកាបញ្ជូនរឿងឱ្យស៊ើប សួររបស់ការិយាល័យសហព្រះរាជអាជ្ញា ដែលមានចំណងជើងថា បក្សកុម្មុយនិស្តកម្ពុជា និង គណៈអចិន្ត្រៃយ៍បក្សកុម្មុយនិស្តកម្ពុជា និងមន្ទីរ ៨៧០, **D3** ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧, កថាខ័ណ្ឌ ២២-២៤, ERN 00185898-00186167 (ភាសាអង់គ្លេស)។ សូមមើលផងដែរ ផ្នែកនៃ ដីកាសន្និដ្ឋានបញ្ជូនរឿង ឱ្យស៊ើបសួររបស់ការិយាល័យសហព្រះរាជអាជ្ញា ដែលមានចំណងជើង ថា ការពិនិត្យលើឋានុក្រមនៃកម្ពុជាប្រជាធិបតេយ្យ និង គណៈអចិន្ត្រៃយ៍, **D3** ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧, កថាខ័ណ្ឌ ៦ និង ១១-១៣, ERN 00185898-00186167 (ភាសាអង់គ្លេស)។

[9] សំដីរបស់ អៀង សារី ហៅ វ៉ាន់, **IS Annex C No. 20.8** ថ្ងៃទី ៦ ដល់ ១៩ ខែកញ្ញា ឆ្នាំ១៩៩៦, ត្រង់ទំព័រ ៦, ERN 00078605-00078618 (ភាសាអង់គ្លេស) ("គឺមានគណៈកម្មាធិការ ដែលពិនិត្យលើរាល់បញ្ហាអំពីសន្តិសុខ")។

[10] តួនាទីរបស់គណៈមជ្ឈិមបក្សកុម្មុយនិស្តកម្ពុជា មានបញ្ជាក់នៅក្នុងផ្នែកនៃដីកាសន្និដ្ឋានបញ្ជូន រឿងឱ្យស៊ើបសួររបស់ការិយាល័យសហព្រះរាជអាជ្ញា ដែលមានចំណងជើងថា បក្សកុម្មុយនិស្ត កម្ពុជា និង គណៈអចិន្ត្រៃយ៍បក្សកុម្មុយនិស្តកម្ពុជា និងមន្ទីរ ៨៧០, **D3** ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧, កថាខ័ណ្ឌ ២៤-២៨, ERN 00185898-00186167 (ភាសាអង់គ្លេស)។ សូមមើល ផងដែរផ្នែកនៃ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ របស់ការិយាល័យសហព្រះរាជអាជ្ញា ដែលមានចំណងជើងថា ការពិនិត្យលើឋានុក្រមនៃកម្ពុជា ប្រជាធិបតេយ្យ និង គណៈអចិន្ត្រៃយ៍, **D3** ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ ២០០៧, កថាខ័ណ្ឌ ៦ និង ១១-១៣, ERN 00185898-00186167 (ភាសាអង់គ្លេស)។

[11] នៅក្នុងសេចក្ដីសម្រេចចុះថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧៥ របស់គណៈអចិន្ត្រៃយ៍, ប៉ុល ពត ត្រូវបានប្រគល់ការទទួលខុសត្រូវទូទៅលើកងទ័ព។ កំណត់ហេតុប្រជុំគណៈអចិន្ត្រៃយ៍នៃ បកក, **IS Annex C No. 13.2** ថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧៥, DCCN D00677, ត្រង់ទំព័រ ១, ERN 00019108-00019126 (ភាសាខ្មែរ)។

[12] ក្នុងខែមិនា ឆ្នាំ១៩៧៦, សុន សេន ត្រូវបានតែងតាំងជា ឧបនាយករដ្ឋមន្ត្រីទទួលបន្ទុក ការពារជាតិ។ សារាចរណែនាំ របស់គណៈមជ្ឈិមបក្សកុម្មុយនិស្តកម្ពុជា ដែលមានចំណងជើងថា សេចក្ដីសម្រេចរបស់គណៈមជ្ឈិមទាក់ទងនឹងបញ្ហាមួយ ចំនួន, **IS Annex C No. 6.3**, ថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦, DCCN D00693, ERN 00003136-00003142 (ភាសាខ្មែរ)។ សូមមើលផងដែរ កំណត់ហេតុប្រជុំរបស់សភាប្រជាជននៃកម្ពុជាប្រជាធិបតេយ្យ ដែលមានចំណងជើងថា ឯកសារ ស្ដីអំពីសម័យប្រជុំលើកទី១ នីតិកាលទី១ របស់សភាតំណាងប្រជាជនកម្ពុជា, ថ្ងៃទី១១-១៣ ខែមេសា ឆ្នាំ១៩៧៦, **IS Annex C No. 13.13**, DCCN D21227, ត្រង់ទំព័រ ៤៨-៤៩, ERN 00053603-00053645 (ភាសាខ្មែរ)។ សុន សេន ក៏ជាសមាជិកនៃគណៈមជ្ឈិមបក្សកុម្មុយនិស្តកម្ពុជាដែរ ។ សំដី របស់ ខៀវ សំផន ស្រង់ដោយ កសចស, **D46** ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៧, ត្រង់ទំព័រ ១០, ERN 00156741-00156751 (ភាសាខ្មែរ)។

[13] សំដីរបស់ អៀង សារី ហៅ វ៉ាន់, **IS Annex C No. 20.8** ថ្ងៃទី៦ ដល់ ១៩ ខែកញ្ញា ឆ្នាំ១៩៩៦, ត្រង់ទំព័រ ៦, ERN 00078605-00078618 (ភាសាអង់គ្លេស) (អៀង សារី និយាយថា គឺគណៈកម្មាធិការដែលដោះស្រាយរាល់បញ្ហាសន្តិសុខ "ដែលមានមនុស្ស៤នាក់: ប៉ុល ពត, នួន ជា, សុន សេន និង ទីប្រឹក្សា សុន សេន ឈ្មោះ យុន យ៉ាត")។

[14] កំណត់ហេតុប្រជុំគណៈអចិន្ត្រៃយ៍នៃ បកក, **IS Annex C No. 13.2** ថ្ងៃទី ៩ ខែតុលា ឆ្នាំ១៩៧៥, DCCN D00677, ត្រង់ទំព័រ ១, ERN 00019108-00019126 (ភាសាខ្មែរ) (ដែលផ្តល់ឱ្យ សុន សេន នូវការទទួលខុសត្រូវលើអគ្គសេនាធិការ និងសន្តិសុខ), កំណត់ហេតុប្រជុំកងទ័ពកម្ពុជា ប្រ ជាធិបតេយ្យ, **D83-0009** ដែលមានចំណងជើងថា ជូនគណៈកម្មាធិការកងពល និងវរសេនាធំ, DCCN D01782, ERN 00033314-00033314 (ភាសាខ្មែរ) (ដែលនៅក្នុងនោះ សុន សេន ចេញការ ណែនាំពីអគ្គសេនាធិការទៅ កងពល និង វរសេនាធំ); សំដីរបស់ កាំង ហ្គេច អ៊ាវ ហៅ ឌុច ស្រង់ដោយ កសចស, **D11** ថ្ងៃទី៧ ខែសីហា ឆ្នាំ២០០៧, ERN 00147518, ERN 00147517-00147527 (ភាសាអង់គ្លេស)។

[15] កំណត់ហេតុប្រជុំកងទ័ពកម្ពុជាប្រជាធិបតេយ្យ ដែលមានចំណងជើងថា សេចក្តីរាយការណ៍ ពីស្ថានភាពនៅកងពល ៣១០ ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ១៩៧៦, DCCN L0000237, ERN 00160067-00160067 (ភាសាខ្មែរ) (សេចក្តីរាយការណ៍របស់មន្ទីរអគ្គសេនាធិការដែលចុះហត្ថលេខា ដោយឈ្មោះ រ៉ែន); របាយការណ៍កងទ័ពកម្ពុជាប្រជាធិបតេយ្យ ដែលមានចំណងជើងថា សេចក្តី រាយការណ៍ពីស្ថានភាពនៅកងពល៤៥០ ថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៧៦, DCCN L0000258, ERN 00052338-00052340 (ភាសាខ្មែរ) (សេចក្តីរាយការណ៍របស់មន្ទីរអគ្គសេនាធិការដែលចុះហត្ថលេខា ដោយឈ្មោះ រ៉ែន)។ កំណត់ហេតុប្រជុំកងទ័ពកម្ពុជាប្រជាធិបតេយ្យ ដែលមានចំណងជើងថា ការប្រជុំនៅកន្លែងរបស់កងពល ១៧០ ថ្ងៃទី១ ខែតុលា ឆ្នាំ១៩៧៦, DCCN L0001493, ERN 00160137-00160141 (ភាសាខ្មែរ) (កំណត់ហេតុប្រជុំអគ្គសេនាធិការជាមួយកងពល១៧០ចុះហត្ថ-លេខាដោយឈ្មោះ រ៉ែន)។

[16] របាយការណ៍កងទ័ពកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ២៩ ខែមីនា ឆ្នាំ១៩៧៧, DCCN L0000056, ERN 00052314-00052314 (ភាសាខ្មែរ) (ឯកសារពីគណៈកម្មាធិការភ័ស្តុភារសេនា ធិការ ជូនចំពោះ បង ៨៩ និង បង ៨១ ចុះហត្ថលេខាដោយឈ្មោះ ទាញ); របាយការណ៍កងទ័ពកម្ពុជាប្រជាធិបតេយ្យ ដែលមានចំណងជើងថា ស្ថិតិអាវុធ និងគ្រាប់រំសេវដែលស្នើដោយ កងពល ៤៥០ និង ៥០២ ថ្ងៃទី២៧ ខែឧសភា ឆ្នាំ១៩៧៦, DCCN L0001253, ERN 00160097-00160097 (ភាសាខ្មែរ) (ឯកសារអគ្គសេនាធិការដែលចុះហត្ថលេខាដោយឈ្មោះ ទាញ); របាយការណ៍កងទ័ពកម្ពុជាប្រជាធិបតេយ្យ ដែលមានចំណងជើងថា ផែនការប្រើប្រាស់អង្ករ សម្រាប់ឆ្នាំ១៩៧៦ ដោយអង្គភាព ថ្ងៃទី៤ ខែមករា ឆ្នាំ១៩៧៦, DCCN L0001069, ERN 00160081-00160081 (ភាសាខ្មែរ) (របាយការណ៍កងទ័ពកម្ពុជាប្រជាធិបតេយ្យដែលចុះហត្ថលេខា ដោយឈ្មោះ ទាញ)។

[17] អគ្គសេនាធិការមានមន្ទីរក្រោមចំណុះ២ទៀត: មន្ទីរ ៦២ និងមន្ទីរ ៦៣។ មន្ទីរ ៦២ មាន ការិយាល័យក្រោមចំណុះចំនួនទៀត: ក-១៥, ក-១៦, ក-១៨, ក-២៧, ក-២៨, ពទ៨, វ-៦៦, ត្រាកទ័រ និង ឡានទឹក។ មន្ទីរ ៦២ មានបុគ្គលិក ១.៣៨៥ នាក់, ចំណែកឯមន្ទីរ ៦៣ មានបុគ្គលិក ៣.២០១ នាក់។ របាយការណ៍កងទ័ពកម្ពុជាប្រជាធិបតេយ្យ ដែលមានចំណងជើង ថា របាយការណ៍កងទ័ពកម្ពុជាប្រជាធិបតេយ្យស្តីពីស្ថិតិកម្លាំងកងទ័ពទូទៅ, **IS Annex C No. 18.30** ថ្ងៃទី៧ ខែមេសា ឆ្នាំ១៩៧៧, DCCN L0000065, ERN 00052319-00052319 (ភាសាខ្មែរ)។ ឯកសារមួយផ្សេងទៀតនិយាយយោងដល់មន្ទីរជាច្រើននៅក្នុងអគ្គសេនាធិការ រួមមាន "ភស្តុភារកង ទ័ព", "អង្គភាពរថក្រោះ", "អង្គភាពកាំភ្លើងធំ" និង "មន្ទីរសេនាធិការ"។ ទាំងនេះអាចថាជាឈ្មោះ ផ្សេងទៀតរបស់មន្ទីរ ៦២ និង ៦៣ និង មន្ទីរក្រោមចំណុះជាច្រើន"។ របាយការណ៍កងទ័ព កម្ពុជាប្រជាធិបតេយ្យ ដែលមានចំណងជើងថា ផែនការប្រើប្រាស់អង្ករសម្រាប់ឆ្នាំ១៩៧៦ដោយ អង្គភាព ថ្ងៃទី៤ ខែមករា ឆ្នាំ១៩៧៦, DCCN L0001069, ERN 00160081-00160081 (ភាសាខ្មែរ)។

[18] កំណត់ហេតុប្រជុំកងទ័ពកម្ពុជាប្រជាធិបតេយ្យ ដែលមានចំណងជើងថា កំណត់ហេតុប្រជុំ ដកពិសោធន៍លើការឃាមកាមការពារទីក្រុង ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៧៦, DCCN L0000255, ERN 00162477-00162479 (ភាសាខ្មែរ) (កំណត់ហេតុប្រជុំអគ្គសេនាធិការរៀបរាប់ពីស្ថានភាពខ្មាំងបង្កប់នៅក្នុងប្រទេស និងនៅតាមព្រំដែន); កំណត់ហេតុប្រជុំកងទ័ពកម្ពុជាប្រជាធិបតេយ្យ ដែលមានចំណង ជើងថា សេចក្តីសង្ខេបពីស្ថានភាពខាងក្នុងប្រទេស និងនៅតាមព្រំដែន យោងតាមទូរលេខពី ១ ដល់ ៣១ ខែធ្នូ ឆ្នាំ១៩៧៦ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៦, DCCN L0000268, ERN 00160073-00160077 (ភាសាខ្មែរ) (ឯកសារអគ្គសេនាធិការផ្តល់នូវសេចក្តីសង្ខេបពីសកម្មភាពដែលកើតឡើងនៅ

ក្នុងប្រទេស និងនៅតាមព្រំដែន); កំណត់ហេតុប្រជុំកងទ័ពកម្ពុជាប្រជាធិបតេយ្យ ដែលមានចំណង ជើងថា ប្រជុំនៅកន្លែងកងពល១៧០ ថ្ងៃទី១ ខែតុលា ឆ្នាំ១៩៧៦, DCCN L0001493, ERN 00160137-00160141 (ភាសាខ្មែរ) (រៀបរាប់ពី "ចំពោះមុខ"ក្នុងការការពារប្រទេស ហើយនិយាយថា សមមិត្តណាដែលមាន "និន្នាការនយោបាយមិនល្អ" ត្រូវតែដកចេញ ដើម្បីការពារសន្តិសុខផ្ទៃក្នុង)។

[19] សារាចរណែនាំរបស់គណៈមជ្ឈិមបក្សកុម្មុយនិស្តកម្ពុជា ដែលមានចំណងជើងថា សេចក្តី សម្រេចរបស់គណៈមជ្ឈិមអំពីបញ្ហាផ្សេងៗ, **IS Annex C No. 6.3** ថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦, DCCN D00693, ERN 00003136-00003142 (ផ្តល់សិទ្ធិឱ្យអគ្គសេនាធិការ "កម្ទេច" បុគ្គលនៅក្នុង "កងទ័ពមជ្ឈិម")។

[20] ស-២១ គឺជាមន្ទីរសន្តិសុខសំខាន់របស់ បកក នៅក្នុងក្រុងភ្នំពេញ។ មានការរៀបរាប់ពីមន្ទីរ នេះយ៉ាងលម្អិតបន្ថែមទៀតនៅក្នុង ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា ដែល មានចំណងជើងថា ភ្នំពេញ-មន្ទីរស-២១, **D3** ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧, កថាខ័ណ្ឌ ៤៩-៥៥, ERN 00185898-00186167 (ភាសាអង់គ្លេស)។

[21] សូមមើល, ឧទាហរណ៍, បញ្ជីអ្នកទោស ស-២១ ដែលមានឈ្មោះរបស់អ្នកទោសមកពី មន្ទីរអគ្គសេនាធិការ, ពេទ្យកងទ័ព និង អង្គភាពផ្សេងៗទៀត, **D57-00038** ឆ្នាំ១៩៧៧, DCCN D10961, ERN 00021118-00021120 (បញ្ជីឈ្មោះ៣៧នាក់ដែលត្រូវបានចាប់ខ្លួន, ១៣នាក់មកពី អគ្គសេនាធិការ); បញ្ជីអ្នកទោស ស-២១ ដែលមានឈ្មោះរបស់អ្នកទោសមកពីអគ្គសេនាធិការ ឆ្នាំ១៩៧៧, DCCN D14269, ERN 00021222-00021229 (ភាសាខ្មែរ) (ចុះបញ្ជីឈ្មោះមនុស្ស ៧៦នាក់ មកពីមន្ទីរអគ្គសេនាធិការ, ៥នាក់បានបញ្ជាក់ថា "កម្ទេច")។ បញ្ជីអ្នកទោស ស-២១ ដែលមានចំណងជើងថា របាយការណ៍របស់ ចាន់ អំពីអ្នកទោស១៣នាក់បញ្ជូនមក ស-២១ ថ្ងៃ២១ ឧសភា ១៩៧៧, **D57-00075,** DCCN D06928, ERN 00088738-00088739 (ភាសាខ្មែរ) (មានឈ្មោះអ្នកទោសមួយចំនួនមកពីភស្តុភារសេនាធិការ)។ បញ្ជីអ្នកទោស ស-២១ ដែលមាន ចំណងជើងថា របាយការណ៍របស់ ចាន់ អំពីអ្នកទោស ១៨នាក់បញ្ជូនមក ស-២១ ថ្ងៃ២២ ឧសភា ១៩៧៧, **D57-00076,** DCCN D06927, ERN 00088736-00088737 (ភាសាខ្មែរ) (មានឈ្មោះអ្នក ទោសមួយចំនួនមកពីសេនាធិការ)។ បញ្ជីអ្នកទោស ស-២១, **IS Annex C No. 16.58** ថ្ងៃ២៨ ឧសភា ១៩៧៧ DCCN D06924, ERN 00072579-00072581 (ភាសាខ្មែរ) (មានឈ្មោះអ្នកទោស ៣០នាក់ ក្នុងនោះមានទាំងអ្នកទោសមកពីអគ្គសេនាធិការដែរ); បញ្ជីអ្នកទោស ស-២១, **IS Annex C No. 16.60** ខែធ្នូ ១៩៧៧, DCCN D10937, ERN 00040237-00040237 (ភាសាខ្មែរ) (មានឈ្មោះអ្នកទោស ៨នាក់); បញ្ជីអ្នកទោស ស-២១ ដែលមានឈ្មោះអ្នកទោសមកពីសេនា ធិការ និងស-២១, **D57-00102** ខែតុលា ១៩៧៧, DCCN D06185, ERN 00021100-00021102 (ភាសាខ្មែរ) (មានបញ្ជីឈ្មោះមនុស្ស ៥៥នាក់មកពីសេនាធិការ និង ស-២១) ។ បញ្ជីអ្នកទោស ស-២១ ដែលមានឈ្មោះអ្នកទោស មកពីមន្ទីរអគ្គសេនាធិការ, **D57-00140** ខែមករា ១៩៧៨, DCCN D05893, ERN 00021090-00021091 (ភាសាខ្មែរ) (មានឈ្មោះមនុស្ស ៦៦នាក់មកពីសេនា ធិការដែលក្នុងនោះ ២៣នាក់ត្រូវបានបញ្ជាក់ថា បានចាប់ខ្លួនរួចហើយ); បញ្ជីអ្នកទោស ស-២១, **D57-00141** ថ្ងៃ១៨ មករា ១៩៧៨, DCCN D14397, ERN 00021241-00021243 (ភាសាខ្មែរ) (បញ្ជីឈ្មោះ ១៣នាក់ ដែល៥នាក់មកពីមន្ទីរសេនាធិការ)។ បញ្ជីអ្នកទោស ស-២១, **IS Annex C No. 16.78** ខែឧសភា ១៩៧៨, DCCN D05909, ERN 00019233-00019249 (មានឈ្មោះអ្នក ទោស ២៧០នាក់ ដែលខ្លះមកពីសេនាធិការ); បញ្ជីអ្នកទោស ស-២១ ដែលមានឈ្មោះអ្នកទោស មកពីមន្ទីរចំណុះសេនាធិការ, ខែកក្កដា ១៩៧៨, **D57-00156,** DCCN D05915, ERN 00021092-00021093 (មានឈ្មោះមនុស្ស ២២នាក់ដែលចាប់មកពីសេនាធិការ); បញ្ជីអ្នកទោស ស-២១ ថ្ងៃ៣០ មីនា ១៩៧៨, **D57-00166,** DCCN D02669, ERN 00086721-00086724 (ភាសាខ្មែរ) (មានឈ្មោះអ្នកទោស ៨៤នាក់ ដែលអ្នកទោសខ្លះមកពីសេនាធិការ; បញ្ជីអ្នកទោស ស-២១, ថ្ងៃទី២ មេសា ១៩៧៨, **D57-00170,** DCCN D01580, ERN 00088616-00088630 (ភាសាខ្មែរ) (ដែលមានឈ្មោះអ្នកទោស ១៤៤នាក់, ខ្លះមកពីសេនាធិការ); បញ្ជីអ្នកទោស ស-២១, **D57-00171** ថ្ងៃទី៣ ខែមេសា ឆ្នាំ១៩៧៨, DCCN D01575, ERN 00088602-00088611 (ភាសាខ្មែរ) (មានឈ្មោះអ្នកទោស ៨៨នាក់ ដែលអ្នកទោសខ្លះមកពីសេនាធិការ); បញ្ជីអ្នកទោស ស-២១ ដែលមានឈ្មោះអ្នកទោសសួរចម្លើយដោយ "ក្រុមត្រជាក់", **D57-00180** ថ្ងៃទី១០ ខែមេសា ឆ្នាំ១៩៧៨, DCCN D06017, ERN 00086873-00086873 (ភាសាខ្មែរ) (រួមមានអ្នកទោសមកពីសេនា ធិការ)។ បញ្ជីអ្នកទោស ស-២១ ដែលមានឈ្មោះអ្នកទោសសួរចម្លើយដោយ "ក្រុមឯកសារ", **D57-00179** ថ្ងៃទី១០ ខែមេសា ឆ្នាំ១៩៧៨, D06035, ERN 00086894-00086898 (ភាសាខ្មែរ) បញ្ជីអ្នកទោស ៧៦នាក់ដែលមានអ្នកខ្លះមក ពីសេនាធិការ); បញ្ជីអ្នកទោស ស-២១, **D57-00181**

ថ្ងៃទី២៣ ខែមេសា ឆ្នាំ១៩៧៨, DCCN D01569, ERN 00088586-00088593 (ភាសាខ្មែរ) (បញ្ជីអ្នកទោស ៩៩នាក់ដែលអ្នកខ្លះមកពីសេនាធិការ); បញ្ជីអ្នកទោស ស-២១, **D57-00182** ថ្ងៃ ទី២៤ ខែមេសា ឆ្នាំ១៩៧៨, DCCN D01568, ERN 00088568-00088585 (ភាសាខ្មែរ) (បញ្ជីអ្នក ទោស ១១០នាក់ ដែលអ្នកខ្លះមកពីសេនាធិការ); បញ្ជីអ្នកទោស ស-២១, **D57-00183** ថ្ងៃទី២៥ ខែមេសា ឆ្នាំ១៩៧៨, DCCN D01567, ERN 00039788-00039811 (ភាសាខ្មែរ) (មាន ឈ្មោះអ្នកទោស ៣០៧នាក់ដែលអ្នកខ្លះមកពីសេនាធិការ); បញ្ជីអ្នកទោស ស-២១ ដែលមាន ឈ្មោះអ្នកទោសសួរចម្លើយដោយ "ក្រុមត្រជាក់", **D57-00184** ថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៧៨, DCCN D06018, ERN 00086874-00086874 (ភាសាខ្មែរ) (បញ្ជីអ្នកទោស ៥នាក់ ដែលក្នុងនោះមាន ១នាក់មកពីសេនាធិការ); បញ្ជីអ្នកទោស ស-២១ ដែលមានឈ្មោះអ្នកទោសសួរចម្លើយដោយ "ក្រុមត្រជាក់", **D57-00189** ថ្ងៃទី២៩ ខែមេសា ឆ្នាំ១៩៧៨, DCCN D06016, ERN 00086872-00086872 (ភាសាខ្មែរ) (បញ្ជីអ្នកទោស ៥នាក់ ដែលក្នុងនោះមាន ១នាក់មកពីសេនាធិការ); បញ្ជីអ្នកទោស ស-២១ ដែលមានឈ្មោះអ្នកទោសសួរចម្លើយដោយ "ក្រុមត្រជាក់", **D57-00198** ថ្ងៃទី១ ខែឧសភា ឆ្នាំ១៩៧៨, DCCN D06020, ERN 00086875-00086875 (ភាសាខ្មែរ) (បញ្ជីអ្នកទោស ៥នាក់ ដែលក្នុងនោះមាន ១នាក់មកពីសេនាធិការ); បញ្ជីអ្នកទោស ស-២១ ដែលមានឈ្មោះអ្នកទោសសួរចម្លើយដោយ "ក្រុមត្រជាក់", **D57-00199** ថ្ងៃទី២ ខែឧសភា ឆ្នាំ១៩៧៨, DCCN D06023, ERN 00086876-00086876 (ភាសខ្មែរ) (បញ្ជីអ្នកទោស ៥នាក់ ដែលក្នុងនោះមាន ១នាក់មកពីសេនាធិការ); បញ្ជីអ្នកទោស ស-២១ ដែលមានឈ្មោះអ្នកទោស សួរចម្លើយថ្ងៃទី២ ខែឧសភា ឆ្នាំ១៩៧៨, **D57-00201,** DCCN D01604, ERN 00088656-00088662 (ភាសាខ្មែរ) (បញ្ជីអ្នកទោស ៨៩នាក់ ដែលអ្នកខ្លះមកពីសេនាធិការ); បញ្ជីអ្នកទោស ស-២១, **IS Annex C No. 16.132,** DCCN D06022, ERN 00040144-00040146 (ភាសាខ្មែរ) (បញ្ជីអ្នកទោស ២៧នាក់ ដែលអ្នកខ្លះមកពីសេនាធិការ); បញ្ជីអ្នកទោស ស-២១ ដែលមានឈ្មោះអ្នកទោសសួរចម្លើយដោយ "ក្រុមក្តៅ", **D57-00216** ខែមិថុនា ឆ្នាំ១៩៧៨, DCCN D06013, ERN 00086865-00086867 (ភាសាខ្មែរ) (បញ្ជីអ្នកទោស ៣៥នាក់ ដែលអ្នកខ្លះមកពីអង្គភាព រថក្រោះសេនាធិការ); បញ្ជីអ្នកទោស ស-២១, **IS Annex C No. 16.150** ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ១៩៧៨, DCCN D02665, ERN 00040015-00040016 (ភាសាខ្មែរ) (បញ្ជីអ្នកទោស ១៨នាក់ ដែលអ្នកខ្លះមកពីអង្គភាពរថក្រោះសេនាធិការ); បញ្ជីអ្នកទោស ស-២១, **D57-00269** ខែធ្នូ ១៩៧៨, DCCN D05929, ERN 00086822-00086823 (ភាសាខ្មែរ) (បញ្ជីអ្នកទោស ២២នាក់ ដែលអ្នកខ្លះមកពីសេនាធិការ); បញ្ជីអ្នកទោស ស-២១ ដែលមានឈ្មោះអ្នកទោសឃុំនៅក្នុងគុក ពិសេស, **D57-00270** ខែធ្នូ ១៩៧៨, DCCN D01180, ERN 00088520-00088521 (ភាសាខ្មែរ) (បញ្ជីអ្នកទោស ដែលអ្នកខ្លះមកពីសេនាធិការ); បញ្ជីអ្នកទោស ស-២១, **D57-00273** ខែធ្នូ ១៩៧៨, DCCN D05865, ERN 00086763-00086768 (ភាសាខ្មែរ) (បញ្ជីអ្នកទោស ៦០នាក់ ដែលអ្នកខ្លះមកពីមន្ទីរសេនាធិការ); បញ្ជីអ្នកទោស ស-២១, **D57-00280** ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៧៨, DCCN D05933, ERN 00086824-00086836 (ភាសាខ្មែរ) (បញ្ជីអ្នកទោស ៤៦នាក់ ដែលអ្នកខ្លះមកពីសេនាធិការ)។

នៅពេលដែលបញ្ជីអ្នកទោសមួយចំនួន ចង្អុលបង្ហាញយ៉ាងច្បាស់ថា អ្នកទោសត្រូវបានសម្លាប់, កាំង ហ្គេកអ៊ាវ ហៅ ឌុច ដែលជាប្រធានគុក ស-២១អស់រយៈពេលស្ទើរតែពេញមួយរបបនៃ កម្ពុជាប្រជាធិបតេយ្យ, បានបញ្ជាក់ថា នៅទីបំផុត អ្នកដែលបានចូលមកដល់ ស-២១ ត្រូវបាន សម្លាប់។ សំដីរបស់ កាំង ហ្គេកអ៊ាវ ហៅ ឌុច ដែលស្រង់ដោយ កសចស, **D11** ថ្ងៃទី៧ ខែ សីហា ឆ្នាំ២០០៧ តាម ERN 00147524, ERN 00147517-00147527 (ភាសាអង់គ្លេស) (ឌុច និយាយដល់ការសម្លាប់នៅ ស-២១ ជាលក្ខណៈប្រព័ន្ធ ហើយនិយាយថា: "សម្រាប់ជនដែលត្រូវ បាន បញ្ជូនទៅ ស-២១ គឺត្រូវបានសម្រេចរួចជាស្រេចឱ្យកម្ទេចទាំងអស់... ពុំមានសិទ្ធិដោះលែង ឡើយនៅ ស-២១); សំដីរបស់ កាំង ហ្គេកអ៊ាវ ហៅ ឌុច ដែលស្រង់ដោយ កសចស, **D16** ថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០០៧ តាម ERN 00147582, ERN 00147579-00147585 (ភាសាអង់គ្លេស) (ឌុច រៀបរាប់ពីរបៀបដែល នួន ជា ប្រាប់ទៅគាត់ថា "គ្រប់អ្នកដែលត្រូវបានបញ្ជូនទៅ ស-២១ ត្រូវតែសម្លាប់ចោល-ដូចដែលខ្ញុំជាអ្នកគ្រប់គ្រង ស-២១, ខ្ញុំអនុវត្តតាមបញ្ជារបស់គាត់"។); សំដីរបស់ កាំង ហ្គេកអ៊ាវ ហៅ ឌុច ដែលស្រង់ដោយ កសចស, **D13** ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០៧ តាម ERN 00147565, ERN 00147563-00147573 (ភាសាអង់គ្លេស) (ឌុច រៀបរាប់ពីការទទួល "បញ្ជាដាច់ខាត" នៅថ្ងៃទី២ ឬ ៣ ខែមករា ឆ្នាំ១៩៧៩ ពី នួន ជា ឱ្យ "កម្ទេច" អ្នកទោសនៅ ស-២១ទាំងអស់); សំដីរបស់ កាំង ហ្គេកអ៊ាវ ហៅ ឌុច ដែលស្រង់ដោយ កសចស, **D21** ថ្ងៃទី៣ ខែតុលា ឆ្នាំ២០០៧ តាម ERN 00149911, ERN 00149907-00149919 (ភាសាអង់គ្លេស) (ឌុច និយាយថា: "អ្នកទោសដែលជាប់ឃុំឃាំងទាំងអស់ត្រូវ

00291975



តែកម្ទេចចោល។ នៅពេលដំបូង ការសម្លាប់ធ្វើឡើងនៅភ្នំពេញ, ខាងលិច ស-២១។ ក្រោយមក ដោយសារតែខ្លាចមានជម្ងឺឆ្លង ការសម្លាប់ត្រូវធ្វើឡើងនៅជើងឯកវិញ")។

អ្នកផ្សេងទៀតដែលធ្លាប់ធ្វើការនៅ ស-២១ ក៏បានគូសបញ្ជាក់ផងដែរថា អ្នកទោសទាំងអស់ នៅ ស-២១ ត្រូវបានសម្លាប់។ សំដីរបស់ ប៊ូម៉េង ដែលស្រង់ដោយសហព្រះរាជអាជ្ញា, **IS Annex C No. 23.1** ថ្ងៃទី២៤ ខែសីហា ឆ្នាំ២០០៦, ERN 00080529-00080539 (ភាសាខ្មែរ) (សាក្សីបញ្ជាក់ថា ក្នុងករណីខ្លះ អ្នកជាប់ឃុំត្រូវបានសម្លាប់នៅ ស-២១); សំដីរបស់ គង់ ថៃ ដែលស្រង់ដោយសហព្រះរាជអាជ្ញា, **IS Annex C No. 23.5** ថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០០៦, ERN 00078666-00078675 (ភាសាខ្មែរ)។ សំដីរបស់ សុខ សុផាត ដែលស្រង់ដោយមជ្ឈមណ្ឌលឯកសារ កម្ពុជា, **IS Annex C No. 19.184** ថ្ងៃទី២២ ខែមករា ឆ្នាំ២០០២, ERN 00008163-00008248 (ភាសាខ្មែរ); សំដីរបស់ សោម ម៉ុន ដែលស្រង់ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា, **IS Annex C No. 19.168** ថ្ងៃទី១៣ ខែសីហា ឆ្នាំ២០០៣, ERN 00053936-00053961 (ភាសាខ្មែរ)។ សំដីរបស់ ហម សេង ហៅ អ៊ិក ប៊ុនសេង ដែលស្រង់ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា, **IS Annex C No. 19.43** ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០៣, DCCN KDI0249/K00147, ERN 00008904-00008904 (ភាសាខ្មែរ) (រៀបរាប់ពីរបៀបបញ្ជូនមនុស្សទៅ ស-២១ ហើយពុំដែលឃើញត្រឡប់មកវិញទៅ ហើយហៅ ស-២១ ថាជាកន្លែងសម្លាប់)។ សំដីរបស់ សោម ម៉េត ដែលស្រង់ដោយមជ្ឈមណ្ឌល ឯកសារកម្ពុជា, **IS Annex C No. 19.167** ថ្ងៃទី២៥ ខែមករា ឆ្នាំ២០០៣, DCCN KDI0155/K05435, ERN 00051644-00051751 (ភាសាខ្មែរ) (ម៉េត និយាយថា អ្នកទោសត្រូវសម្លាប់ បន្ទាប់ពីសួរចម្លើយរួច)។ សំដីរបស់ ប្រាក់ ខន ដែលស្រង់ដោយសហព្រះរាជអាជ្ញា, **IS Annex C No. 23.8** ថ្ងៃទី១២ ខែតុលា ឆ្នាំ២០០៦, ERN 00078625-00078639 (ភាសាខ្មែរ)។

[22] សមមិត្ត វ៉ែន នៅសេនាធិការ ត្រូវបានបញ្ជូនទៅកងពលជាច្រើន ដើម្បីចុះទៅធ្វើការ ព្រមទាំងជួយដល់កងទ័ពបដិវត្តកម្ពុជា ក្នុងការចាប់ចង និង បោសសម្អាត។ កំណត់ហេតុប្រជុំរបស់ កងទ័ពកម្ពុជាប្រជាធិបតេយ្យ ដែលមានចំណងជើងថា ការប្រជុំនៅកន្លែងកងពល ១៧០, ថ្ងៃ១ តុលា ១៩៧៦, DCCN L0001493, ERN 00160137-00160141 (ភាសាខ្មែរ) (សមមិត្ត វ៉ែន និយាយថា "វាអាចអនុវត្តវិន័យរបស់បក្ស និងអាចដើរតាមការសម្រេចរបស់បក្ស ដូចជា ដកសមមិត្តណាដែល មាននិន្នាការនយោបាយមិនល្អ។ សមមិត្ត តាត ក៏និយាយដោយដល់សារៈសំខាន់នៃការបោសសម្អាត "សមាសភាពដែលបង្កឱ្យមានគ្រោះថ្នាក់") ។ កំណត់ហេតុប្រជុំរបស់ កងទ័ពកម្ពុជាប្រជាធិបតេយ្យ ដែលមានចំណងជើងថា របាយការណ៍អំពីស្ថានភាពនៅកងពល ៤៥០ ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ១៩៧៦, DCCN L0000258, ERN 00052338-00052340 (ភាសាខ្មែរ) (រៀបរាប់ពីរបៀប ដែលឈ្មោះ វ៉ែន ពីមន្ទីរសេនាធិការទៅកងពល ៤៥០ ដើម្បីស៊ើបរកខ្មែរក្បត់របស់ ឆើត។ រួមបញ្ចូលឈ្មោះ មនុស្ស ២៥នាក់ មកពីកងពល ៤៥០, កងពល ៣១០, ខាងរោងចក្រ និងខាងពាណិជ្ជកម្ម ដែលមានចង្អុលបង្ហាញឈ្មោះនៅក្នុងចម្លើយសារភាពរបស់ ឆើត)។ កំណត់ហេតុប្រជុំរបស់កងទ័ព កម្ពុជាប្រជាធិបតេយ្យ ដែលមានចំណងជើងថា របាយការណ៍អំពីស្ថានភាពនៅកងពល ៣១០ ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ១៩៧៦, DCCN L0000237, ERN 00160067-00160067 (ភាសាខ្មែរ) (ពិភាក្សាពីមនុស្ស២នាក់ នៅក្នុងកងពល ៣១០ដែលមានចង្អុលបង្ហាញនៅក្នុងចម្លើយសារភាព។ វ៉ែន និយាយ ថា មនុស្សទាំងពីរនាក់នេះ "ចាប់រួចហើយ" ដោយកងពល); របាយការណ៍របស់កងទ័ព កម្ពុជាប្រជាធិបតេយ្យ ដែលមានចំណងជើងថា របាយការណ៍អំពីស្ថានភាពនៅកងពល ៤៥០ ថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៧៦, DCCN L0000258, ERN 00052338-00052340 (ភាសាខ្មែរ) (វ៉ែន រាយការណ៍ ត្រឡប់ទៅសេនាធិការអំពីសមមិត្ត ឡុម ហើយស្នើ "ដក"គាត់ចេញពីកងពល ៤៥០)។

[23] សូមមើលកំណត់សំគាល់ទី៧០ ខាងក្រោម។

[24] កំណត់ហេតុប្រជុំរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ដែលមានចំណងជើងថា ការប្រជុំ នៅកន្លែងកងពល១៧០ ថ្ងៃទី១ ខែតុលា ឆ្នាំ១៩៧៦, DCCN L0001493, ERN 00160137-00160141 (ភាសាខ្មែរ) (កត់សំគាល់ថា មនុស្សជាច្រើនបានបញ្ជូនទៅ "រៀនសូត្រ" ដោយកងពល)។ របាយ ការណ៍របស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ដែលមានចំណងជើងថា គណៈភស្តុភារសេនាធិការ គោរពជូនបង ៨៩ និង ៨១, ថ្ងៃទី២៩ ខែមីនា ឆ្នាំ១៩៧៧, DCCN L0000056, ERN 00052314-00052314 (ភាសាខ្មែរ) (បញ្ជីឈ្មោះពួកជាប់ "ខ្សែក្បត់" នៅភស្តុភារសេនាធិការ។ ចង្អុលបង្ហាញថា "វិធានការខាងចាត់តាំង" ត្រូវបានធ្វើឡើងប្រឆាំងនឹងពួកនោះ)។

